១៩-វរសេនីយ៍ទោ **ស្វ ផៃមុន្នី** អត្តលេខ ០៣៨០៣៧ គ្រូភាសាបរទេស មុខវិជ្ជាគ្រូសិល្បៈនិងមនុស្សសាស្ត្រ យោធាចារ្យ វិទ្យាសាស្ត្រសង្គមនិងចំណេះដឹងទូទៅ មជ្ឈមណ្ឌលយោធាចារ្យ វិទ្យាស្ថានទ័ពជើងគោក

២០-វរសេនីយ៍ទោ **ម៉េង ហេង** អត្តលេខ ០៨៨៧៤៧ នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស

២១-វរសេនីយ៍ទោ **លី សារ៉ុន** អត្តលេខ ០៣៧៧៣៨ ជំនួយការ ឯកឧត្តម នាយឧត្តមសេនីយ៍ គន់ គីម

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៤ រោច ខែ បុស្ស ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៤ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

## សម្រេច

**មាត្រា១** : តែងតាំង និងផ្តល់ឋានៈលោកស្រី **ហ៊ុន សុភា** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយករង ដោយពុំទទួលប្រាក់បំណាច់មុខងារ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤ រោច ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.-** បំពាក់មេដាយ**សហមេត្រី** ថ្នាក់ អស្សឫទ្ធិ ជូននាយទាហាន ចំនួន ៤រូប នៃសាធារណរដ្ឋសង្គមនិយមវៀតណាមដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការជាមួយកងយោធពលខេមរភូមិន្ទកន្លងមក ដូចមានរាយនាមខាងក្រោម៖

១-វរសេនីយ៍ឯក ហ្វាម វ៉ាន់ហ័រ មេបញ្ជាការរង កងទ័ពព្រំដែនខេត្តប៊ិញហ្វឿក

២-វរសេនីយ៍ឯក ហ្វាម ហ៊្វហាយ ប្រធានមន្ទីរកិច្ចការបរទេស យោធភូមិភាគទី៧

៣-វរសេនីយ៍ទោ ឌ័ន ស៊ុនជៀង ជំនួយការសេនាធិការយោធាស្រុកឡុកនិញយោធាខេត្តប៊ិញហ្វឿក

៤-វរសេនីយ៍ទោ ង្វៀន វ៉ាន់សយ ប្រធានក្រុមស៊ើបការណ៍ចល័តមន្ទីរស៊ើបការណ៍កងទ័ពព្រំដែនខេត្តប៊ិញហ្វឿក

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៤ រោច ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១.** -បំពាក់មេដាយ**មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងសុខាភិបាល ចំនួន ១៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

| | | |
|---|---|---|
| ១-ឯកឧត្តមវេជ្ជបណ្ឌិត | **លី សូវ៉ាន់** | ទីប្រឹក្សាក្រសួងសុខាភិបាល និងជាប្រធាននាយកដ្ឋានប្រយុទ្ធនិងជំងឺឆ្លង |
| ២-ឯកឧត្តមសាស្ត្រាចារ្យជំនួយ | **ប៊ុត សុខល់** | ទីប្រឹក្សាឋានៈស្មើអនុរដ្ឋលេខាធិការ |
| ៣-ឯកឧត្តមវេជ្ជបណ្ឌិត | **កែវ រដ្ឋា** | ទីប្រឹក្សាឋានៈស្មើអនុរដ្ឋលេខាធិការ |
| ៤-ឯកឧត្តមវេជ្ជបណ្ឌិត | **ឃ្លោក ហួត** | ទីប្រឹក្សាឋានៈស្មើអគ្គនាយក |
| ៥-ឯកឧត្តមវេជ្ជបណ្ឌិត | **អ៊ឹង សូវៀត** | ទីប្រឹក្សាឋានៈស្មើអគ្គនាយក |
| ៦-ឯកឧត្តមវេជ្ជបណ្ឌិត | **អ៊ឹង រតនា** | ទីប្រឹក្សាឋានៈស្មើអគ្គនាយក |

| | | |
|---|---|---|
| ៧-ឯកឧត្តមវេជ្ជបណ្ឌិត | **ខូយ ឌី** | ទីប្រឹក្សាឋានៈស្មើអគ្គនាយក |
| ៨-ឯកឧត្តមវេជ្ជបណ្ឌិត | **គួង ឡូ** | ទីប្រឹក្សាឋានៈស្មើអគ្គនាយក |
| ៩-ឯកឧត្តមវេជ្ជបណ្ឌិត | **ប៊ុន សួរ** | ទីប្រឹក្សាឋានៈស្មើអគ្គនាយក |
| ១០-លោកវេជ្ជបណ្ឌិត | **សុខ ស្រ៊ុន** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ |
| ១១-លោកឱសថការី | **ឌុក ឆវេទ** | នាយកសាលភូមិភាគបាត់ដំបង |

ខ-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

| | | |
|---|---|---|
| ១-ឯកឧត្តមវេជ្ជបណ្ឌិត | **អៀន បូរ៉ាវុឌ្ឍន៍** | រដ្ឋលេខាធិការ |
| ២-លោកជំទាវវេជ្ជបណ្ឌិត | **ចាន់ សុខា** | អនុរដ្ឋលេខាធិការ |
| ៣-លោកវេជ្ជបណ្ឌិត | **គី សន់ទី** | ប្រធានមន្ទីរពេទ្យគន្ធបុប្ផា |

គ-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

| | | |
|---|---|---|
| ១-លោកវេជ្ជបណ្ឌិត | **ឈិត សុផល** | ប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន |
| ២-លោក | **ប៊ុន រ៉ិ** | ប្រធាននាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ |
| ៣-លោកវេជ្ជបណ្ឌិត | **យ៉ៃ ចន្ទនា** | ប្រធានមន្ទីរពេទ្យជ័យវរ្ម័នទី៧ |
| ៤-លោកឱសថការី | **ថន ខៃលី** | ប្រធានឃ្លាំងឱសថកណ្តាល |
| ៥-លោកវេជ្ជបណ្ឌិត | **មិន ជាតិ** | នាយកសាលាភូមិភាគកំពត |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤ រោច ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២២ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបញ្ចូលកីឡាករ-កីឡាការិនីក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ :** អនុញ្ញាតឲ្យក្រសួងការពារជាតិ បញ្ចូលកីឡាករ-កីឡាការិនីក្នុងក្របខ័ណ្ឌ កងយោធពលខេមរភូមិន្ទ ប្រគល់ឋានន្តរស័ក្តិថ្នាក់ពលបាលត្រី និងផ្តល់អត្តលេខដល់នាយទាហានរង ចំនួន៨០ (ប៉ែតសិប)នាក់ សម្រាប់បំពេញក្របខ័ណ្ឌឲ្យមជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ ។

**ប្រការ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ៨ កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៣ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំកិច្ចប្រជុំការងារទេសចរណ៍ លើកទី៥១ និងវេទិកាទេសចរណ៍មេគង្គ ឆ្នាំ២០២៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំកិច្ចប្រជុំការងារទេសចរណ៍លើកទី៥១ និងវេទិកាទេសចរណ៍មេគង្គ ឆ្នាំ២០២៣ (51st GMS Tourism Working Group Meeting and 2023 Mekong Tourism Forum-MTF) ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ នៅខេត្តព្រះសីហនុ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២.ឯកឧត្តម **គួច ចំរើន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣.ឯកឧត្តម | **ឌិត ចន្ថា** | រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤.ឯកឧត្តម | **ជា ម៉ូរ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៥.ឯកឧត្តម | **សាន់ សាច់អី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៦.ឯកឧត្តម | **ស៊ុំ ម៉ាប់** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៧.ឯកឧត្តម | **ស៊ិន ចាន់សិរីវុត្ថា** | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| ៨.ឯកឧត្តម | **ថោង រដ្ឋសក្តិ** | អគ្គនាយក នៃអគ្គនាយកដ្ឋានអភិវឌ្ឍទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៩.នាយឧត្តមសេនីយ៍ | **ហ៊ឹម យ៉ាន** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១០.ឧត្តមសេនីយ៍ឯក | **គៀន សុភារក្ខា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ១១.ឧត្តមសេនីយ៍ឯក | **ម៉ន សាម៉ុន** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១២.ឧត្តមសេនីយ៍ឯក | **ជុំ សាវុឌ្ឍ** | ប្រធាននាយកដ្ឋានអង្គរក្ស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៣.ឧត្តមនាវីទោ | **រស់ វណ្ណា** | មេបញ្ជាការរងមូលដ្ឋានសមុទ្រ នៃកងទ័ពជើងទឹក | សមាជិក។ |

**ប្រការ២** : គណៈកម្មការអន្តរក្រសួងនេះ មានតួនាទី និងភារកិច្ចដឹកនាំ ចាត់ចែង និងត្រួតពិនិត្យដំណើរការរៀបចំកិច្ចប្រជុំការងារទេសចរណ៍លើកទី៥១ និងវេទិកាទេសចរណ៍មេគង្គ ឆ្នាំ២០២៣ នៅខេត្តព្រះសីហនុ ឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។

**ប្រការ៣** : គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាសេនាធិការ និងអនុគណៈកម្មការមួយចំនួនតាមការចាំបាច់ ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៤** : គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ថវិការបស់ក្រសួងទេសចរណ៍ និងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន និងមានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍន៍ ឬផ្នែកឯកជន ដើម្បីជួយទ្រទ្រង់ និងឧបត្ថម្ភដល់ដំណើរការរៀបចំកិច្ចប្រជុំការងារទេសចរណ៍លើកទី៥១ និងវេទិកាទេសចរណ៍មេគង្គ ឆ្នាំ២០២៣។

**ប្រការ៥** : គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ដើម្បីដំណើរការការងាររបស់ខ្លួន។

អនុប្រធាន អនុប្រធានអចិន្ត្រៃយ៍ និងសមាជិកនៃគណៈកម្មការអន្តរក្រសួង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មការអន្តរក្រសួងអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងអ្នកជំនាញពាក់ព័ន្ធផ្សេងៗទៀត ចូលរួមកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួង។

**ប្រការ៦** : គណៈកម្មការអន្តរក្រសួងនេះ នឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច។

**ប្រការ៧** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មីនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.....[illegible].............សហវ.[illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២[illegible].

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ខេត្តរតនគិរី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ
- បានឃើញប្រកាសលេខ ៧៨៤ សហវ.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើអចលនទ្រព្យខេត្តរតនគិរី

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
N.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

**សម្រេច**

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ខេត្តរតនគិរី ដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ញ៉ែម សំអឿន** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. | ឯកឧត្តម **មួង ម៉ាង** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣. | លោក **ផាត់ កែវមុនី** | ប្រធានសាខាពន្ធដារខេត្ត | អនុប្រធានប្រចាំការ |
| ៤. | លោក **លី ខុសតា** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | អនុប្រធាន |
| ៥. | លោក **នាង សំអាត** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៦. | លោក **ដួច ម៉ុនណា** | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៧. | លោក **សយ សុណា** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | សមាជិក |
| ៨. | **លោកអភិបាល នៃគណៈអភិបាល គ្រប់ក្រុង/ស្រុក** | | សមាជិក |
| ៩. | លោក **ធ្លាក់ សាច់ន្ត** | អនុប្រធានសាខាពន្ធដារខេត្ត | សមាជិក |
| ១០. | លោក **ទឹម មុន្នីរ័ត្ន** | អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | សមាជិក |
| ១១. | លោក **ម៉ិច សុតក្តិ** | ប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ នៃសាខាពន្ធដារខេត្ត | សមាជិក |
| ១២. | លោកស្រី **មូ ស៊ីវតាន** | តំណាងវិស័យឯកជនផ្នែកអចលនទ្រព្យ | សមាជិក |

**ប្រការ ២.-**

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ មានភារកិច្ច ដូចខាងក្រោម ÷

- រៀបចំបញ្ជីសរុបអចលនទ្រព្យ និងរៀបចំតម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់ នៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចខេត្ត និងបញ្ជូនមកគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយ ណែនាំ និងអប់រំក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយជាសាធារណៈ រួមទាំងបិទប្រកាសផ្សាយតម្លៃអចលនទ្រព្យ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យនៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចខេត្ត
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- សម្របសម្រួល និងសហការជាមួយរដ្ឋបាលសារពើពន្ធ ក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន ត្រួតពិនិត្យ រំលឹក ជំរុញការអនុវត្តភារកិច្ចរបស់ក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់
- សមាជិកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមការអញ្ជើញរបស់ប្រធានអនុគណៈកម្មការ។

**ប្រការ ៣.-**

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ មានសិទ្ធិបង្កើតក្រុមការងារអចលនទ្រព្យឃុំ- សង្កាត់ ជាជំនួយការ។

ក្រុមការងារឃុំ- សង្កាត់ មានភារកិច្ច ដូចខាងក្រោម ÷

- ចូលរួមផ្តល់យោបល់ក្នុងការកំណត់តម្លៃអចលនទ្រព្យតាមប្រភេទ និងទីតាំងក្នុងដែនសមត្ថកិច្ច

- សហការផ្សព្វផ្សាយ ណែនាំ និងអប់រំអ្នកជាប់ពន្ធអំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- សហការជាមួយរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំបញ្ជីលម្អិតអចលនទ្រព្យក្នុងដែនសមត្ថកិច្ច ហើយបញ្ជូនមកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- សហការផ្តល់ស្ថិតិ និងទិន្នន័យសម្រាប់ការចុះបញ្ជីអចលនទ្រព្យ ដល់រដ្ឋបាលសារពើពន្ធ
- សហការការងារដទៃទៀតតាមការស្នើសុំរបស់រដ្ឋបាលសារពើពន្ធ
- សមាជិកក្រុមការងារត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានក្រុមការងារ
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ។

**ប្រការ ៤.-**

សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

ឯកឧត្តម អស់លោក លោកស្រី ដែលជាសមាសភាពដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ប្រធានគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ**

**បណ្ឌិតសភាចារ្យ ជូ ចិជិត្ត**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តរតនគិរី
  "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...[illegible]...សហវ.[illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២៣.

# សេចក្ដីសម្រេច
## ស្ដីពី
## ការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ខេត្តកំពង់ធំ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ និងវិសោធនកម្មបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការប្រមូលពន្ធលើអចលនទ្រព្យ
- បានឃើញប្រកាសលេខ ៧៨៤ សហវ.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើអចលនទ្រព្យខេត្តកំពង់ធំ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ខេត្តកំពង់ធំ ដូចខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **ងួន រតនៈ** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. | លោកជំទាវ | **លិំ គន្ធារី** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣. | លោក | **ជឹម សុវណ្ណ** | ប្រធានសាខាពន្ធដារខេត្ត | អនុប្រធានប្រចាំការ |
| ៤. | លោក | **អ៊ឹម សុឌីណា** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | អនុប្រធាន |
| ៥. | លោក | **យ៉ុច សេងគុណា** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៦. | លោក | **សុខ សុផល** | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៧. | លោក | **ម៉ែន ចណ្ណារិទ្ធ** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | សមាជិក |
| ៨. | **លោកអភិបាល នៃគណៈអភិបាល គ្រប់ក្រុង/ស្រុក** | | | សមាជិក |
| ៩. | លោក | **អ៊ុំ គីមសុទ្ធ** | អនុប្រធានសាខាពន្ធដារខេត្ត | សមាជិក |
| ១០. | លោកស្រី | **ហួច ដាលីនាថ** | អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | សមាជិក |
| ១១. | លោក | **សៅ ស៊ីម** | ប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ នៃសាខាពន្ធដារខេត្ត | សមាជិក |
| ១២. | លោកស្រី | **លី ម៉ារ៉ុម** | អនុប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ នៃសាខាពន្ធដារខេត្ត | សមាជិក |

**ប្រការ ២.-**

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ មានភារកិច្ច ដូចខាងក្រោម ÷

- រៀបចំបញ្ជីសរុបអចលនទ្រព្យ និងរៀបចំតម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់ នៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចខេត្ត និងបញ្ជូនមកគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយ ណែនាំ និងអប់រំក្រុមការងារអចលនទ្រព្យឃុំ- សង្កាត់ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្ដីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយជាសាធារណៈ រួមទាំងបិទប្រកាសផ្សាយតម្លៃអចលនទ្រព្យ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យនៅតាមមូលដ្ឋាន ក្នុងដែនសមត្ថកិច្ចខេត្ត
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- សម្របសម្រួល និងសហការជាមួយរដ្ឋបាលសារពើពន្ធ ក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន ត្រួតពិនិត្យ រំលឹក ជំរុញការអនុវត្តភារកិច្ចរបស់ក្រុមការងារអចលនទ្រព្យឃុំ- សង្កាត់
- សមាជិកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមការអញ្ជើញរបស់ប្រធានអនុគណៈកម្មការ។

**ប្រការ ៣.-**

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ មានសិទ្ធិបង្កើតក្រុមការងារអចលនទ្រព្យឃុំ- សង្កាត់ ជាជំនួយការ។

ក្រុមការងារឃុំ-សង្កាត់ មានភារកិច្ច ដូចខាងក្រោម ÷

- ចូលរួមផ្តល់យោបល់ក្នុងការកំណត់តម្លៃអចលនទ្រព្យតាមប្រភេទ និងទីតាំងក្នុងដែនសមត្ថកិច្ច
- សហការផ្សព្វផ្សាយ ណែនាំ និងអប់រំអ្នកជាប់ពន្ធអំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- សហការជាមួយរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំបញ្ជីលម្អិតអចលនទ្រព្យក្នុងដែនសមត្ថកិច្ច ហើយបញ្ជូនមកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- សហការផ្តល់ស្ថិតិ និងទិន្នន័យសម្រាប់ការចុះបញ្ជីអចលនទ្រព្យ ដល់រដ្ឋបាលសារពើពន្ធ
- សហការការងារដទៃទៀតតាមការស្នើសុំរបស់រដ្ឋបាលសារពើពន្ធ
- សមាជិកក្រុមការងារត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានក្រុមការងារ
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ។

**ប្រការ ៤.-**

សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលជាសមាសភាពដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ**

**បណ្ឌិតសភាចារ្យ ជុំ ចិន្ដា**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពង់ធំ

  "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.....[illegible].............សហវ.[illegible]

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២៣.

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ខេត្តប៉ៃលិន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ
- បានឃើញប្រកាសលេខ ៧៨៤ សហវ.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើអចលនទ្រព្យខេត្តប៉ៃលិន

ផ្ទះលេខ ៩២ មហាវិថីតេជោសែន សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
N°92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ខេត្តប៉ៃលិន ដូចខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១. | លោកជំទាវ | **បាន ស្រីមុំ** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. | លោក | **ចេង ញ៉ាន់** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣. | លោក | **ផាចឌី ណារិន** | ប្រធានសាខាពន្ធដារខេត្ត | អនុប្រធានប្រចាំការ |
| ៤. | លោក | **ស្វ សុខុន** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | អនុប្រធាន |
| ៥. | លោក | **រស់ ឡឿន** | នាយករងរដ្ឋបាលសាលាខេត្ត | សមាជិក |
| ៦. | លោក | **សាយ សុផាត** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | សមាជិក |
| ៧. | លោក | **គីម សុខា** | ប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ៨. | **លោកអភិបាល នៃគណៈអភិបាល គ្រប់ក្រុង/ស្រុក** | | | សមាជិក |
| ៩. | លោកស្រី | **កែវ ស្រីរ័ត្ន** | អនុប្រធានមន្ទីរ ដ.ន.ស.ស ខេត្ត | សមាជិក |
| ១០. | លោក | **សែត ទិចិត្រ** | នាយកទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត | សមាជិក |
| ១១. | លោក | **ធឿន អ៊ី** | អនុប្រធានសាខាពន្ធដារខេត្ត | សមាជិក |
| ១២. | លោក | **ស្រេង គុនឡាយ** | ប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ នៃសាខាពន្ធដារខេត្ត | សមាជិក |
| ១៣. | លោកស្រី | **ណុប ផល្លា** | អនុប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ នៃសាខាពន្ធដារខេត្ត | សមាជិក |
| ១៤. | លោក | **សែម សុខន** | អនុប្រធានការិ.សុរិយោដី និងភូមិសាស្ត្រ នៃមន្ទី ដ.ន.ស.ស ខេត្ត | សមាជិក |

**ប្រការ ២.-**

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ មានភារកិច្ច ដូចខាងក្រោម ÷

- រៀបចំបញ្ជីសរុបអចលនទ្រព្យ និងរៀបចំតម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់ នៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចខេត្ត និងបញ្ជូនមកគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយ ណែនាំ និងអប់រំក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយជាសាធារណៈ រួមទាំងបិទប្រកាសផ្សាយតម្លៃអចលនទ្រព្យ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យនៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចខេត្ត
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- សម្របសម្រួល និងសហការជាមួយរដ្ឋបាលសារពើពន្ធ ក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន ត្រួតពិនិត្យ រំលឹក ជំរុញការអនុវត្តភារកិច្ចរបស់ក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់
- សមាជិកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមការអញ្ជើញរបស់ប្រធានអនុគណៈកម្មការ។

**ប្រការ ៣.-**

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ មានសិទ្ធិបង្កើតក្រុមការងារអចលនទ្រព្យឃុំ- សង្កាត់ ជាជំនួយការ។

ក្រុមការងារឃុំ- សង្កាត់ មានភារកិច្ច ដូចខាងក្រោម ÷

- ចូលរួមផ្តល់យោបល់ក្នុងការកំណត់តម្លៃអចលនទ្រព្យតាមប្រភេទ និងទីតាំងក្នុងដែនសមត្ថកិច្ច
- សហការផ្សព្វផ្សាយ ណែនាំ និងអប់រំអ្នកជាប់ពន្ធអំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- សហការជាមួយរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំបញ្ជីលម្អិតអចលនទ្រព្យក្នុងដែនសមត្ថកិច្ច ហើយបញ្ជូនមកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- សហការផ្តល់ស្ថិតិ និងទិន្នន័យសម្រាប់ការចុះបញ្ជីអចលនទ្រព្យ ដល់រដ្ឋបាលសារពើពន្ធ
- សហការការងារផ្សេងទៀតតាមការស្នើសុំរបស់រដ្ឋបាលសារពើពន្ធ
- សមាជិកក្រុមការងារត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានក្រុមការងារ
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ។

**ប្រការ ៤.-**

សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

លោកជំទាវ អស់លោក លោកស្រី ដែលជាសមាសភាពដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ប្រធានគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ**

**បណ្ឌិតសភាចារ្យ វង្ស វិសុទ្ធ**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង- ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តប៉ៃលិន
  "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ០៣២ ប្រ.ក

ថ្ងៃព្រហស្បតិ៍ ៥កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០២៣

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពី ការទទួលស្គាល់គុណភាពបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ១ ._**

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការទទួលស្គាល់គុណភាពបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍ ដើម្បីជាអភិក្រមណែនាំរួមសម្រាប់ធ្វើការវាយតម្លៃ និងបញ្ជាក់គុណភាពបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ ព្រមទាំងទទួលស្គាល់សមត្ថភាពជំនាញ និងគុណវុឌ្ឍិរបស់អ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរផងដែរ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣. _**

នាយកខុទ្ទកាល័យ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន នាយិកាវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ ប្រធាននាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត គ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញទេសចរណ៍ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ វិទ្យាស្ថានបណ្តុះបណ្តាលជំនាញទេសចរណ៍ ដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុន ស្ថាប័នទេសចរណ៍ អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព មូលដ្ឋានអាជីវកម្មទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ អ្នកជំនាញទេសចរណ៍ សមាគមឧស្សាហកម្មទេសចរណ៍ និងភាគីពាក់ព័ន្ធ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

**ថោង ខុន**

<u>**កន្លែងទទួលៈ**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលសាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- គ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច
- សាលាបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច
- មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព
- សមាគមឧស្សាហកម្មទេសចរណ៍
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ

# ស្តីពី

# ការទទួលស្គាល់គុណភាពបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញ ក្នុងវិស័យទេសចរណ៍

រៀបចំដោយ

នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍

ឆ្នាំ២០២២

# មាតិកា


មតិស្វាគមន៍របស់ ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីនៃក្រសួងទេសចរណ៍

វាក្យស័ព្ទ

I. សេចក្តីផ្តើម ១

II. គោលបំណង ៣

III. អត្ថប្រយោជន៍ ៤

IV. ស្ថានភាពទូទៅនៃការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍ ៥

V. គោលការណ៍ណែនាំស្តីពីការទទួលស្គាល់ការបណ្តុះបណ្តាល ការវាយតម្លៃ
និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍ ៩

VI. ការវាយតម្លៃ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ ១០

៦.១. ការវាយតម្លៃ និងទទួលស្គាល់វគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍
របស់អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ១០

៦.២. លក្ខណវិនិច្ឆ័យវាយតម្លៃ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាល
របស់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ១៤

៦.៣. ដំណើរការវាយតម្លៃ និងបញ្ជាក់គុណភាពបណ្តុះបណ្តាល
ជំនាញទេសចរណ៍សម្រាប់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ២៩

៦.៤ វិញ្ញាបនបត្របញ្ជាក់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍
សម្រាប់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ៣០

VII. ការវាយតម្លៃ និងទទួលស្គាល់គុណភាពវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ ៣០

៧.១. ការបញ្ជាក់ និងទទួលស្គាល់ការវាយតម្លៃជំនាញទេសចរណ៍
របស់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ៣០

៧.២. លក្ខណវិនិច្ឆ័យវាយតម្លៃ និងទទួលស្គាល់គុណភាពវាយតម្លៃ
របស់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ៣០

៧.៣. ដំណើរការវាយតម្លៃ និងបញ្ជាក់គុណភាពវាយតម្លៃលើជំនាញទេសចរណ៍សម្រាប់មជ្ឈមណ្ឌល
វាយតម្លៃសមត្ថភាព ៤១

៧.៤ វិញ្ញាបនបត្របញ្ជាក់គុណភាពវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍
សម្រាប់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ៤២

VIII. ការវាយតម្លៃ និងទទួលស្គាល់សមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍ ៤២

៨.១. ការវាយតម្លៃ និងទទួលស្គាល់សមត្ថភាពអ្នកជំនាញទេសចរណ៍ ៤២

៨.២. លក្ខណវិនិច្ឆ័យវាយតម្លៃ និងទទួលស្គាល់សមត្ថភាពមូលដ្ឋាន សម្រាប់អ្នកជំនាញទេសចរណ៍ ៤៤

៨.៣. ការបន្សុី និងវាយតម្លៃសមត្ថភាពអ្នកជំនាញទេសចរណ៍ ៤៤

៨.៤. ដំណើរការវាយតម្លៃ និងបញ្ជាក់សមត្ថភាពអ្នកជំនាញទេសចរណ៍ ៤៦

៨.៥. វិញ្ញាបនបត្របញ្ជាក់សមត្ថភាព និងលិខិតបញ្ជាក់សមត្ថភាពមូលដ្ឋាន ៤៧

IX. យន្តការអនុវត្ត ៤៧

ឧបសម្ព័ន្ធ ៤៨



# មតិស្វាគមន៍
# ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍

តាងនាមឱ្យក្រសួងទេសចរណ៍ និងរូបខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយ សូមជម្រាបជូនអ្នកជំនាញទេសចរណ៍ បុគ្គលិកក្រុមហ៊ុន និងធុរកិច្ចក្នុងវិស័យទេសចរណ៍ ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងសាធារណជនទាំងអស់ ឱ្យបានជ្រាបថា ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាបច្ចុប្បន្នមានសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់ពេញលេញ និងមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ក្នុងនោះវិស័យទេសចរណ៍មានការរីកចម្រើនគួរឱ្យកត់សម្គាល់នារយៈពេលជាងមួយទស្សវត្សរ៍ចុងក្រោយនេះ។

វិស័យទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាវិស័យអាទិភាពដើរតួនាទីជា "**មាសបៃតង**" រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម តាមរយៈការបង្កើត និងបង្កើនឱកាសការងារ បង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋដោយផ្ទាល់ និងដោយប្រយោល ជំរុញការនាំចេញនៅនឹងកន្លែង ជំរុញកំណើនសេដ្ឋកិច្ច បង្កើនចំណូលជាតិ ចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ ពិសេសចូលរួមដល់ការឆ្លើយតបនឹងបំរែបំរួលអាកាសធាតុ។ ដើម្បីចូលរួមជំរុញ និងលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍ ឈានទៅសម្រេចការអភិវឌ្ឍទេសចរណ៍ប្រកបដោយគុណភាព បរិយាបន្ន និងការទទួលខុសត្រូវ ក្រសួងទេសចរណ៍ បាននឹងកំពុងយកចិត្តទុកដាក់ខ្ពស់លើការលើកកម្ពស់ការបណ្តុះបណ្តាលជំនាញ និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ តាមរយៈពង្រឹងគុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ និងជំរុញការទទួលស្គាល់សមត្ថភាពអ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ឱ្យមានសមត្ថភាពនិងគុណវុឌ្ឍិ ទាំងនៅក្នុងកម្រិតមូលដ្ឋាន និងកម្រិតវិជ្ជាជីវៈជំនាញក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ។

ដើម្បីជាអភិក្រមរួម នៅក្នុងការវាយតម្លៃ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ ព្រមទាំងសមត្ថភាពមូលដ្ឋាន ដែលតម្រូវសម្រាប់អ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរស្របតាមស្ថានភាពវិវត្តន៍នៃវិស័យទេសចរណ៍ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការរីកចម្រើននៃបដិវត្តន៍ឧស្សាហកម្ម ៤.០ ក្រសួងទេសចរណ៍បានដាក់ចេញ "**គោលការណ៍ណែនាំស្តីពីការទទួលស្គាល់គុណភាពបណ្តុះបណ្តាល និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍**" ដែលជាឯកសារគោលសម្រាប់ធ្វើការវាយតម្លៃ និងបញ្ជាក់គុណភាព បណ្តុះបណ្តាលជំនាញទេសចរណ៍ និងទទួលស្គាល់សមត្ថភាព ជំនាញ និងគុណវុឌ្ឍិ បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរផងដែរ។

ក្នុងនាមក្រសួងទេសចរណ៍ និងរូបខ្ញុំផ្ទាល់ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អ្នកជំនាញទេសចរណ៍ បុគ្គលិកក្រុមហ៊ុន និងធុរកិច្ចក្នុងវិស័យទេសចរណ៍ ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងសាធារណជនទាំងអស់ នឹងចូលរួមចំណែកក្នុងការជំរុញផ្សព្វផ្សាយ គាំទ្រ និងអនុវត្តគោលការណ៍ណែនាំស្តីពីការទទួលស្គាល់គុណភាពបណ្តុះបណ្តាល និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍ នេះឱ្យទទួលបានជោគជ័យប្រកបដោយស្មារតីសហប្រតិបត្តិការ និងទទួលខុសត្រូវខ្ពស់ ដើម្បីលើកកម្ពស់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ និងការអភិវឌ្ឍសមត្ថភាព ជំនាញ និងគុណវុឌ្ឍិរបស់បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍ ក្នុងការផ្តល់សេវាកម្មប្រកបដោយភាពស្ទាត់ជំនាញ គុណភាព ភាពជឿជាក់ និងភាពពេញចិត្តដល់ភ្ញៀវទេសចរនៅក្នុងទីកដីនៃប្រទេស**កម្ពុជាៈ ព្រះរាជាណាចក្រអច្ឆរិយៈ និងផ្តល់ភាពកក់ក្តៅ**។

ថ្ងៃ សុក្រ ១២ រោច ខែ មាឃ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២៣

**ថោង ខុន**
**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**វាក្យស័ព្ទ**

**អ្នកជំនាញទេសចរណ៍/អ្នកជំនាញក្នុងវិស័យទេសចរណ៍** សំដៅលើអ្នកបម្រើការងារនៅក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ។

**ជំនាញទេសចរណ៍** សំដៅលើជំនាញវិជ្ជាជីវៈនៃវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ។

**គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍** សំដៅលើស្ថាប័នអប់រំបណ្តុះបណ្តាលដែលមានផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៃវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ។

**សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍** សំដៅលើសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៃវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ។

**អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍** សំដៅលើអង្គភាព-ស្ថាប័នរដ្ឋ មន្ទីរទេសចរណ៍ មូលដ្ឋានអាជីវកម្មទេសចរណ៍ គ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច វិទ្យាស្ថានបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច ដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុន/ស្ថាប័នឯកជន ដែលមានផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ទាំងតាមរយៈការបណ្តុះបណ្តាលនៅនឹងកន្លែង និងតាមប្រព័ន្ធអនឡាញ។

**ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍** សំដៅលើគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច វិទ្យាស្ថានបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ចទាំងរដ្ឋ និងឯកជន ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ក្រុមហ៊ុន/ស្ថាប័នដែលមានផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍។

**មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព** សំដៅលើអង្គភាព-ស្ថាប័នគ្រប់គ្រងដោយរដ្ឋ និងឯកជន ដែលមានផ្តល់សេវាវាយតម្លៃសមត្ថភាពលើជំនាញវិជ្ជាជីវៈនៃវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ។

**មូលដ្ឋានអាជីវកម្មទេសចរណ៍** សំដៅលើអាជីវកម្មទាំងឡាយដែលប្រកបរបរនៅក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ។

**ឧស្សាហកម្មទេសចរណ៍** សំដៅលើសេវាកម្មផ្សេងៗ នៃវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ។

ស

## I. សេចក្ដីផ្ដើម

ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាបច្ចុប្បន្នមានសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្ដាប់ធ្នាប់ពេញលេញ និងមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ក្នុងនោះវិស័យទេសចរណ៍មានការរីកចម្រើនគួរជាទីមោទនៈ។ វិស័យទេសចរណ៍កម្ពុជា ត្រូវបានចាត់ទុកជាវិស័យអាទិភាពមួយដើរតួជា **"មាសបៃតង"** រួមចំណែកដល់**ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម** និង**ការការពារបរិស្ថាន** ពោលគឺចូលរួមដល់ការកសាងសេដ្ឋកិច្ចបៃតងនៅកម្ពុជា ដែលជាផ្នែកគាំទ្រដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ (UN)។

ប្រទេសកម្ពុជា ក៏ដូចជាបណ្ដាប្រទេសផ្សេងៗ នៅក្នុងពិភពលោក បានប្រឈមនឹងវិបត្តិនៃការរីករាលដាលជំងឺឆ្លងកូវីដ-១៩ ដែលបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សកម្មភាពកម្សាន្តទេសចរណ៍ និងការប្រកបអាជីវកម្មទេសចរណ៍របស់ប្រតិបត្តិករទេសចរណ៍ ក៏ដូចជាធ្វើឱ្យប៉ះពាល់ដល់ការងាររបស់អ្នកបម្រើការក្នុងវិស័យទេសចរណ៍ ដែលជាកត្តាបង្កឱ្យមានការបង្អាក់ខ្សែចង្វាក់សេដ្ឋកិច្ចទេសចរណ៍ និយាយដោយឡែក និងដល់ការអភិវឌ្ឍទេសចរណ៍និយាយជារួម។ តែជាភ័ព្វសំណាងរបស់កម្ពុជា ដែលមាន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខដឹកដ៏ឆ្នើមរបស់កម្ពុជា** បានគិតគូរស្វែងរកវ៉ាក់សាំងជាបន្តបន្ទាប់ដើម្បីចាក់ជូនប្រជាពលរដ្ឋកម្ពុជា ដែលធ្វើឱ្យកម្ពុជាឈានដល់ការបង្កើតភាពស៊ាំនៅក្នុងសហគមន៍ និងឈានដល់ការបើកសកម្មភាពសេដ្ឋកិច្ច សង្គម និងទេសចរណ៍នៅក្នុងគន្លងប្រក្រតីភាពថ្មីឡើងវិញ រហូតឈានដល់ការទទួលចំណាត់ថ្នាក់ជាប្រទេសដែលអាចបើកសកម្មភាពសេដ្ឋកិច្ច សង្គមលឿនជាងគេ និងជាប្រទេសដែលមានសុវត្ថិភាពសម្រាប់ការទស្សនាទេសចរណ៍ផងដែរ។

ការបើកដំណើរការសេដ្ឋកិច្ច សង្គមឡើងវិញនេះ បានជំរុញឱ្យមានការកម្សាន្តទេសចរណ៍នៅតាមគោលដៅទេសចរណ៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជាជាច្រើនឡើងវិញ។ ក្នុងបរិការណ៍នៃការងើបឡើងវិញនៃវិស័យទេសចរណ៍នេះ ក្រសួងទេសចរណ៍ បានគិតគូរ និងយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងគុណភាពសេវាកម្មប្រកបដោយគុណភាព និងសុវត្ថិភាពជូនភ្ញៀវទេសចរតាមគន្លងថ្មី និងបន្តជំរុញផ្សព្វផ្សាយទាក់ទាញទេសចរណ៍ទាំងទេសចរណ៍អន្តរជាតិ និងទេសចរណ៍ក្នុងស្រុកផងដែរ។

ពិតណាស់ថា ការពង្រឹងគុណភាពសេវាកម្មទេសចរណ៍ ចាំបាច់ទាមទារឱ្យមានការគិតគូរដល់ការបណ្ដុះបណ្ដាល និងអភិវឌ្ឍសមត្ថភាពអ្នកជំនាញ ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ និងវិជ្ជាជីវៈខ្ពស់នៅក្នុងការផ្ដល់សេវាកម្មដល់ទេសចរឱ្យបានកាន់តែប្រសើរ និងប្រកបដោយភាពពេញចិត្តដល់ភ្ញៀវដែលធ្វើដំណើរកម្សាន្តនៅតាមគោលដៅទេសចរណ៍។ ក្នុងក្របខណ្ឌនៃការងារបណ្ដុះបណ្ដាល និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ ក្រសួងទេសចរណ៍ បាននឹងកំពុងយកចិត្តទុកដាក់ខ្ពស់ដល់ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ (ទាំងផ្នែកសាធារណៈ និងឯកជន) និងបានដាក់ចេញនូវចក្ខុវិស័យ **"បុគ្គលិកម្នាក់ ជំនាញមួយ"** និង **"អ្នកជំនាញទេសចរណ៍ត្រូវមានការទទួលស្គាល់ និងមានវិញ្ញាបនបត្របញ្ជាក់សមត្ថភាពគ្រប់ៗរូប ត្រឹមឆ្នាំ**

**២០២៥** សំដៅពង្រឹងគុណភាពសេវាកម្មទេសចរណ៍ប្រកបដោយវិជ្ជាជីវៈ និងស្របតាមស្តង់ដាសមត្ថភាពជាតិ តំបន់ អន្តរជាតិ និងពិភពលោក។ ជាមួយគ្នានោះផងដែរ ក្រសួងទេសចរណ៍ បាននឹងកំពុងសហការជាមួយ **គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍** អង្គភាព ស្ថាប័ន រដ្ឋ និងឯកជន ដែលមានផ្តល់សេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀតជំរុញការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ទាំងជំនាញថ្មី និងជំនាញបន្ថែម និងទាំងរយៈពេលខ្លី មធ្យម និងវែង សំដៅធានាឱ្យបាននូវការបណ្តុះបណ្តាលជំនាញទេសចរណ៍ប្រកបដោយគុណភាព និងការកសាងធនធានមនុស្ស ដែលមានសមត្ថភាព ជំនាញ និងគុណវុឌ្ឍិ ឆ្លើយតបទៅនឹងទីផ្សារតម្រូវការក្នុងវិស័យទេសចរណ៍ទាំងបរិមាណ និងគុណភាព។

លើសពីនេះទៅទៀត ដើម្បីជំរុញការបណ្តុះបណ្តាលជំនាញទេសចរណ៍ និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារទេសចរណ៍ទាំងបរិមាណ និងគុណភាព ក្រសួងទេសចរណ៍ បានមើលឃើញច្បាស់ពីសារៈសំខាន់នៅក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ដើម្បីជួយតាមដានតម្រូវការទីផ្សារជំនាញ និងសមត្ថភាពរបស់អ្នកបម្រើការងារនៅក្នុងវិស័យទេសចរណ៍ ជាពិសេសជួយដល់ការរៀបចំបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាពអ្នកជំនាញទេសចរណ៍តាមរយៈប្រព័ន្ធអនឡាញ ដែលអាចឱ្យអ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ យុវជន សិស្ស និស្សិត និងសាធារណជន ដែលមានបំណងចង់អភិវឌ្ឍសមត្ថភាព និងចាប់យកអាជីពជាអ្នកជំនាញនៅក្នុងវិស័យទេសចរណ៍ អាចធ្វើការសិក្សាបានគ្រប់ពេលវេលា គ្រប់ទីកន្លែង និងអាចពង្រឹងសមត្ថភាពជំនាញពេញមួយជីវិត។ ក្នុងនោះ ក្រសួងទេសចរណ៍ ដែលមាន**នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍** ជាសេនាធិការបានបង្កើត**ប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍អនឡាញ** (Online Tourism Professional Training Management System) www.tptd.org ដែលជាប្រព័ន្ធមួយត្រូវបានរៀបចំឡើងសម្រាប់ជួយដល់វិស័យអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍រយៈពេលវែង ហើយជាប្រព័ន្ធមួយ ដែលអាចប្រើប្រាស់ក្នុងការរក្សាទិន្នន័យអ្នកជំនាញទេសចរណ៍សម្រាប់តាមដានសមត្ថភាព និងជំនាញ និងជួយដល់ការវាយតម្លៃ និងបញ្ជាក់សមត្ថភាពអ្នកជំនាញទេសចរណ៍ និងការបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍តាមអនឡាញ ប្រកបដោយគុណភាព និងប្រសិទ្ធភាព ជាពិសេសជួយសម្រួលដល់ការផ្សារភ្ជាប់ទីផ្សារការងាររវាងការផ្គត់ផ្គង់ និងតម្រូវការជំនាញ និងកម្លាំងពលកម្មក្នុងវិស័យទេសចរណ៍ទៀតផង។ ជាពិសេសប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នេះ ត្រូវបានរៀបចំឡើងចំពេលវេលា និងស្របតាមគោលនយោបាយថ្មីរបស់រដ្ឋាភិបាលឌីជីថល (E-Government) ក្នុងការបន្សីនឹងការអនុវត្តថ្នាលអនឡាញ (CamDX)។

ដើម្បីចូលរួមសម្រេចការអនុវត្តថ្នាលអនឡាញនេះ ក្រសួងទេសចរណ៍ បាននឹងកំពុងយកចិត្តទុកដាក់ខ្ពស់លើកិច្ចការចម្បងពីររួមមាន៖

**១** ការជំរុញការទទួលស្គាល់ និងបញ្ជាក់សមត្ថភាពអ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ដើម្បីប្រាកដថាអ្នកបម្រើការងារនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់មានសមត្ថភាពជាមូលដ្ឋាននៅក្នុងការផ្តល់សេវាកម្មដល់ភ្ញៀវទៅតាមមុខជំនាញរបស់ខ្លួន ពោលគឺ

អ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរទាំងអស់ ត្រូវឆ្លងកាត់ការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាព។ ជាពិសេស មូលដ្ឋានអាជីវកម្មទេសចរណ៍ ដែលស្នើសុំបើក ឬបន្តអាជ្ញាបណ្ណអាជីវកម្មទេសចរណ៍ ត្រូវបំពេញលក្ខខណ្ឌតម្រូវ យ៉ាងហោចណាស់ ៣០% នៃបុគ្គលិកបម្រើការងារក្នុងមូលដ្ឋានអាជីវកម្មទេសចរណ៍របស់ខ្លួនឆ្លងកាត់ការបណ្តុះបណ្តាលសមត្ថភាពជំនាញមូលដ្ឋាន ឬមានវិញ្ញាបនបត្របញ្ជាក់សមត្ថភាព ដែលមានការទទួលស្គាល់ដោយក្រសួងទេសចរណ៍។

២. ការពង្រឹង និងទទួលស្គាល់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ ដើម្បីធានាបានថាវគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ ទាំងតាមរយៈអនឡាញ និងនៅនឹងកន្លែង រយៈពេលខ្លី មធ្យម និងវែង និងគ្រប់ទម្រង់ផ្សេងៗទៀត ដែលរៀបចំឡើងដោយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ មន្ទីរទេសចរណ៍ មូលដ្ឋានអាជីវកម្ម អង្គភាព ស្ថាប័ន រដ្ឋ និងឯកជន និងដៃគូអភិវឌ្ឍន៍ផ្សេងៗ ដែលមានផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ត្រូវធានាបាននូវគុណភាព ដែលមានការវាយតម្លៃ និងទទួលស្គាល់ដោយក្រសួងទេសចរណ៍។

ដើម្បីសម្រេចបាននូវកិច្ចការទាំងពីរខាងលើ សំដៅចូលរួមអនុវត្តថ្នាលអនឡាញ ឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល ក្រសួងទេសចរណ៍ ដែលមាននាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ជាសេនាធិការ បានចងក្រង "**គោលការណ៍ណែនាំស្តីពីការទទួលស្គាល់គុណភាពបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍**" ដែលជាឯកសារគោលសម្រាប់ធ្វើការវាយតម្លៃ និងបញ្ជាក់គុណភាពបណ្តុះបណ្តាល និងការវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ ព្រមទាំងទទួលស្គាល់សមត្ថភាព ជំនាញ និងគុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ផងដែរ។

## II. គោលបំណង

**គោលការណ៍ណែនាំស្តីពីការទទួលស្គាល់គុណភាពបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍** ត្រូវបានដាក់ចេញក្នុងគោលបំណងដូចខាងក្រោម៖

១.បញ្ជាក់ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាល**ជំនាញទេសចរណ៍**

២. បញ្ជាក់ និងទទួលស្គាល់គុណភាពវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍

៣. បញ្ជាក់ និងទទួលស្គាល់សមត្ថភាពមូលដ្ឋានរបស់អ្នកជំនាញទេសចរណ៍ ដើម្បីគាំទ្រដល់ការអនុវត្តថ្នាលអនឡាញ CamDx

៤ វាយតម្លៃ និងបន្សុីសមត្ថភាពអ្នកជំនាញទេសចរណ៍ឱ្យស្របតាមស្តង់ដាសមត្ថភាពអ្នកជំនាញទេសចរណ៍ជាតិ តំបន់ អាស៊ាន និងអន្តរជាតិ

៥. តម្រង់ទិសការអភិវឌ្ឍជំនាញសម្រាប់អ្នកជំនាញទេសចរណ៍

៦. ជំរុញមូលដ្ឋានអាជីវកម្មទេសចរណ៍បង្កើនការយកចិត្តទុកដាក់លើការបណ្តុះបណ្តាលបុគ្គលិកឱ្យបានជាប់ជាប្រចាំ

៧. សម្រួលដល់ការដាក់ចេញផែនការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពដល់អ្នកជំនាញទេសចរណ៍

III. អត្ថប្រយោជន៍

ការទទួលស្គាល់គុណភាពបណ្ដុះបណ្ដាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍ ផ្ដល់អត្ថប្រយោជន៍ដោយផ្ទាល់ និងប្រយោលយ៉ាងច្រើនដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យទេសចរណ៍ មានដូចខាងក្រោម៖

**១. សម្រាប់គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលជំនាញទេសចរណ៍ សាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ ក្រុមហ៊ុន អង្គការ ស្ថាប័នរដ្ឋ និងឯកជន ដៃគូអភិវឌ្ឍន៍ ដែលមានផ្ដល់សេវាបណ្ដុះបណ្ដាលជំនាញទេសចរណ៍**

- ទទួលបានការទទួលស្គាល់គុណភាពបណ្ដុះបណ្ដាលជំនាញទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ
- បង្កើនភាពជឿជាក់ដល់យុវជន សិស្ស និស្សិត និងសាធារណជនក្នុងការផ្ដល់សេវាបណ្ដុះបណ្ដាលជំនាញទេសចរណ៍
- ទទួលបានការតម្រង់ទិសនៅក្នុងការរៀបចំវគ្គបណ្ដុះបណ្ដាលជំនាញឱ្យស្របទៅនឹងតម្រូវការជំនាញនៅក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ
- ធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្ដុះបណ្ដាលរបស់ខ្លួនឱ្យឆ្លើយតបទៅនឹងស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ។

**២. សម្រាប់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព**

- ទទួលបានការទទួលស្គាល់គុណភាពវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍
- បង្កើនភាពជឿជាក់ដល់អ្នកជំនាញទេសចរណ៍ យុវជន សិស្ស និស្សិត និងសាធារណជនក្នុងការផ្ដល់សេវាវាយតម្លៃ និងបញ្ជាក់សមត្ថភាពលើជំនាញទេសចរណ៍
- ទទួលបានការតម្រង់ទិសនៅក្នុងការរៀបចំវគ្គវាយតម្លៃសមត្ថភាព ឱ្យស្របទៅនឹងតម្រូវការជំនាញនៅក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ
- ធ្វើបច្ចុប្បន្នភាពវិធីសាស្ត្រ និងឧបករណ៍វាយតម្លៃសមត្ថភាពរបស់ខ្លួនឱ្យឆ្លើយតបទៅនឹងស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ។

**៣. សមាគមឧស្សាហកម្មទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ មូលដ្ឋានអាជីវកម្មទេសចរណ៍ និងផ្នែក ពាក់ព័ន្ធ**

- ធានាបានថាអ្នកបម្រើការងារនៅតាមមូលដ្ឋានអាជីវកម្មរបស់ខ្លួនធ្លាប់ឆ្លងកាត់ការបណ្ដុះបណ្ដាល និងមានសមត្ថភាពយ៉ាងហោចណាស់កម្រិតមូលដ្ឋាននៅក្នុងការបំពេញការងារជាអ្នកជំនាញទេសចរណ៍
- តម្រង់ទិសក្នុងការបណ្ដុះបណ្ដាល និងពង្រឹងសមត្ថភាព និងជំនាញដល់បុគ្គលិកបម្រើការងារនៅតាមមូលដ្ឋានអាជីវកម្មរបស់ខ្លួន

- ទទួលបានជំនឿទុកចិត្តពីអតិថិជនលើការផ្តល់សេវារបស់អ្នកបម្រើការងារក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួន។

**៤. អ្នកជំនាញទេសចរណ៍**

- ទទួលបានការបញ្ជាក់ និងទទួលស្គាល់សមត្ថភាព
- ទទួលបានការតម្រង់ទិសក្នុងការអភិវឌ្ឍសមត្ថភាព និងជំនាញបន្ថែម
- ទទួលបានការបណ្តុះបណ្តាលជំនាញជាប្រចាំ
- មានឱកាសបន្ថែមនៅក្នុងការទទួលបានមុខងារកាន់តែប្រសើរ។

**៥.ក្រសួងទេសចរណ៍**

- រក្សាទិន្នន័យអ្នកជំនាញទេសចរណ៍
- សម្រួលលើការវាយតម្លៃ និងបញ្ជាក់សមត្ថភាពអ្នកជំនាញទេសចរណ៍
- បង្កើនការបណ្តុះបណ្តាលជំនាញ និងសមត្ថភាពដល់យុវជន សិស្ស និស្សិត និងអ្នកជំនាញទេសចរណ៍
- រក្សាគុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍
- ធានាបានថាអ្នកជំនាញទេសចរណ៍គ្រប់រូបទទួលបានការបណ្តុះបណ្តាល។

**៦. រាជរដ្ឋាភិបាល និងសង្គមជាតិ**

- សម្រេចគោលនយោបាយរដ្ឋាភិបាល
- សម្រេចការអនុវត្តថ្នាលអនឡាញ
- សម្រេចផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលលើមុំនៃការអភិវឌ្ឍធនធានមនុស្ស។

**IV. *ស្ថានភាពទូទៅនៃការបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពអ្នកជំនាញទេសចរណ៍***

ទន្ទឹមនឹងការរីកចម្រើននៃវិស័យទេសចរណ៍ ជាមួយនឹងការចូលរួមបង្កើតការងារដោយផ្ទាល់ និងប្រយោលយ៉ាងច្រើនដល់យុវជន សិស្ស និស្សិត និងប្រជាជនទូទៅ ការគិតគូរលើការធានាគុណភាពសេវាកម្ម ការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពដល់អ្នកបម្រើការងារក្នុងវិស័យនេះ ជាកត្តាសំខាន់ ដោយក្នុងនោះ ក្រសួងទេសចរណ៍ បាននឹងងកំពុងខិតខំជំរុញការបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យនេះ តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលទាំងជំនាញបន្ថែម និងជំនាញថ្មី (Upskilling and Reskilling) សំដៅសម្រេចបាន **"បុគ្គលិកម្នាក់ ជំនាញមួយ"** និងបានកំពុងសហការជាមួយដៃគូអភិវឌ្ឍន៍ជាច្រើនដើម្បីជំរុញការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ និងបានដាក់ចេញគោលដៅយុទ្ធសាស្ត្ររួមមាន៖

**-ឆ្នាំ២០២៣:** អ្នកជំនាញទេសចរណ៍ **៥០%** ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញថ្មី និងបន្ថែម

-**ឆ្នាំ២០២៥**: អ្នកជំនាញទេសចរណ៍ **៧០%** មានវិញ្ញាបនបត្រ ឬសញ្ញាបត្របញ្ជាក់សមត្ថភាពស្រប តាមស្តង់ដាជាតិ និងអាស៊ាន។

-**ឆ្នាំ២០២៨**: សម្រេចឱ្យបានយុទ្ធនាការ **"បុគ្គលិកម្នាក់ ជំនាញមួយ"** ពោលគឺជំរុញឱ្យអ្នកជំនាញ ទេសចរណ៍ទាំងអស់ (**១០០%**) មានវិញ្ញាបនបត្រ ឬសញ្ញាបត្របញ្ជាក់សមត្ថភាពស្របតាមស្តង់ដា ជាតិ និងអាស៊ាន។

-**ឆ្នាំ២០៣០**: សម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព SDG4: **"ធានាឱ្យបាននូវ ការអប់រំបណ្តុះបណ្តាលប្រកបដោយគុណភាព សមធម៌ និងបរិយាប័ន្ន ព្រមទាំងលើកកម្ពស់ ឱកាសសិក្សាពេញមួយជីវិតដល់ជនគ្រប់រូប**" និង SDG8: **"ជំរុញកំណើនសេដ្ឋកិច្ច និងការងារសម រម្យដល់ជនគ្រប់រូប**" ក្នុងវិស័យទេសចរណ៍កម្ពុជាតាមរយៈការអភិវឌ្ឍមូលធនមនុស្សទាំងក្នុងប រិបទជាតិ និងតំបន់។

-**ឆ្នាំ២០៣៥**: សម្រេចឱ្យបានការអប់រំ និងបណ្តុះបណ្តាលជំនាញទេសចរណ៍ឆ្លាតវៃ (Smart Training) សំដៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច និងទេសចរណ៍ឆ្លាតវៃ (Smart Economy and Tourism)។

ដើម្បីចូលរួមសម្រេចឱ្យបាននូវចក្ខុវិស័យនៃការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ កន្លង មកដោយមានការឯកភាពពីរាជរដ្ឋាភិបាល ក្រសួងទេសចរណ៍ បានទទួលកម្ចីហិរញ្ញប្បទានពីទីភ្នាក់ងារបារាំង ដើម្បីការអភិវឌ្ឍ AFD ដើម្បីសាងសង់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ជាតិចំនួនពីរ (មួយនៅ រាជធានីភ្នំពេញ និងមួយទៀតនៅខេត្តព្រះសីហនុ)។ តែដោយសារការរីកចម្រើននៃវិស័យទេសចរណ៍ សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ជាតិទាំងពីរនេះ នៅពុំទាន់អាចធ្វើការបណ្តុះបណ្តាលអ្នក ជំនាញទេសចរណ៍ឱ្យមានចំនួនគ្រប់គ្រាន់ ឆ្លើយតបទៅនឹងតម្រូវការសេវាកម្មក្នុងឧស្សាហកម្មទេសចរណ៍ នៅឡើយ។ ដូច្នេះ ក្រសួងទេសចរណ៍ បានខិតខំស្វែងរកអ្នកវិនិយោគជាច្រើនដើម្បីមកវិនិយោគលើការ សាងសង់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងបដិសណ្ឋារកិច្ចបន្ថែមនៅកម្ពុជា។

ពិតណាស់ថា នៅតាមគោលដៅទេសចរណ៍នៅបណ្តាខេត្តមួយចំនួន ជាពិសេសនៅតាមគោលដៅ សហគមន៍ទេសចរណ៍ នៅមិនទាន់មានសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៅឡើយ។ យុវជន សិស្ស និស្សិត និងអ្នកបម្រើការងារក្នុងវិស័យទេសចរណ៍នៅតាមបណ្តាខេត្តមួយចំនួន បានចូលរួមវគ្គ បណ្តុះបណ្តាលខ្លីៗ ដែលរៀបចំដោយមន្ទីរទេសចរណ៍ ក៏ដូចជាដៃគូអភិវឌ្ឍន៍ និងអង្គភាព ស្ថាប័ន ដែលមាន ផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ហើយមួយចំនួនទៀត ជាពិសេសយុវជន សិស្ស និស្សិត ដែល មានបំណងចាប់យកអាជីពក្នុងវិស័យទេសចរណ៍ និងបានចូលបម្រើការងារក្នុងវិស័យទេសចរណ៍ភាគច្រើន មិនបានឆ្លងកាត់ការបណ្តុះបណ្តាល។

គួរកត់សម្គាល់ផងដែរថា ការបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលបានធ្វើពីសំណាក់គ្រឹះស្ថាន អប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ក្រុមហ៊ុនប្រឹក្សា យោបល់ និងបណ្តុះបណ្តាលជំនាញទេសចរណ៍ មន្ទីរទេសចរណ៍ មូលដ្ឋានអាជីវកម្មទេសចរណ៍ ដៃគូអភិវឌ្ឍន៍

និងអង្គភាព ស្ថាប័នរដ្ឋ និងឯកជន ដែលមានផ្តល់សេវាបណ្តុះបណ្តាល រៀបចំឡើងគ្រប់ទម្រង់ និងលើសមត្ថភាព និងជំនាញចម្រុះ ហើយមួយចំនួនមិនទាន់ឆ្លើយតបទៅនឹងគុណភាព និងតម្រូវការបណ្តុះបណ្តាលនៅឡើយ ដែលនេះជាកត្តាចាំបាច់ ដែលក្រសួងទេសចរណ៍ ចាំបាច់ត្រូវធ្វើការពង្រឹងគុណភាពផងដែរ។

លើសពីនេះទៅទៀតនៅក្នុងស្ថានភាពប្រឈមនឹងវិបត្តិជំងឺឆ្លងកូវីដ-១៩នេះ ការបណ្តុះបណ្តាលជំនាញទេសចរណ៍ ក៏ដូចជាវិស័យអប់រំបណ្តុះបណ្តាលទូទៅ បានប្រឈមនឹងភាពរអាក់រអួលដល់សកម្មភាពបណ្តុះបណ្តាលយ៉ាងខ្លាំង។ ដើម្បីជាដំណោះស្រាយ ជាមួយនឹងទិសដៅយុទ្ធសាស្ត្រជំរុញការបណ្តុះបណ្តាលច្បាស់លាស់របស់ក្រសួងទេសចរណ៍ ក្រសួងទេសចរណ៍ បានប្រែក្លាយស្ថានភាពពីវិបត្តិទៅជាកាលានុវត្តភាពក្នុងការជំរុញការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្ស ក្នុងទម្លាប់ថ្មីនៃវិស័យអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា និងព័ត៌មាន(ICT) ដើម្បីគាំទ្រដល់ការសិក្សាអប់រំ និងបណ្តុះបណ្តាលជំនាញទេសចរណ៍ពេញមួយជីវិត។ ក្នុងនោះ ក្រសួងទេសចរណ៍ បានដាក់ចេញ**ប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍អនឡាញ** (Online Tourism Professional Training Management System) www.tptd.org ដែលជាប្រព័ន្ធមួយត្រូវបានរៀបចំឡើងសម្រាប់ជួយដល់វិស័យអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍រយៈពេលវែង ហើយក៏ជាប្រព័ន្ធមួយ ដែលអាចប្រើប្រាស់ក្នុងការរក្សាទិន្នន័យអ្នកជំនាញទេសចរណ៍សម្រាប់តាមដានសមត្ថភាព និងជំនាញ និងជួយដល់ការវាយតម្លៃ និងបញ្ជាក់សមត្ថភាពអ្នកជំនាញទេសចរណ៍ និងការបើកវគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍តាមអនឡាញ ប្រកបដោយគុណភាព និងប្រសិទ្ធភាព ជាពិសេសជួយសម្រួលដល់ការផ្សារភ្ជាប់ទីផ្សារការងាររវាងការផ្គត់ផ្គង់ និងតម្រូវការជំនាញ និងកម្លាំងពលកម្មក្នុងវិស័យទេសចរណ៍ទៀតផង។ ជាពិសេសប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នេះ ជាប្រព័ន្ធមួយដែលត្រូវបានរៀបចំឡើងចំពេលវេលា និងស្របតាមគោលនយោបាយថ្មីរបស់រដ្ឋាភិបាលឌីជីថល (E-Government) ក្នុងការបន្សីនឹងការអនុវត្តថ្នាលអនឡាញ(CamDX)។

លើសពីនេះទៅទៀត នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដែលជាសេនាធិការរបស់ក្រសួងទេសចរណ៍ បានដាក់ចេញនូវផែនការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ក្នុងដំណាក់កាល និងក្រោយវិបត្តិជំងឺឆ្លងកូវីដ-១៩ សម្រាប់រយៈពេល ០៥ ឆ្នាំ (២០២១-២០២៥) ដែលផែនការនេះជាត្រីវិស័យបង្ហាញផ្លូវសម្រាប់ជំរុញបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានអ្នកជំនាញទេសចរណ៍ឱ្យឆ្លើយតបទាំងបរិមាណ និងគុណភាព ជាពិសេសចូលរួមលើកកម្ពស់គុណភាពសេវាកម្ម និងអភិវឌ្ឍន៍ជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ចប្រកបដោយបរិមាណ និងគុណភាព សំដៅចូលរួមសម្រេចផែនការស្តារ និងអភិវឌ្ឍន៍វិស័យទេសចរណ៍ឆ្នាំ ២០២០-២០២៥ និងឆ្លើយតបទៅនឹងគោលនយោបាយអនុវត្តថ្នាលអនឡាញរបស់រាជរដ្ឋាភិបាលផងដែរ។ ផែនការបណ្តុះបណ្តាល នេះបង្ហាញនូវសកម្មភាពយុទ្ធសាស្ត្រធំៗ ចំនួន **០៩** រួមមាន៖

**១.** ជំរុញការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រី និងភាគីពាក់ព័ន្ធក្នុងការផ្តល់សេវាកម្មទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ អ្នកជំនាញទេសចរណ៍ទាំងជំនាញថ្មី និងជំនាញបន្ថែមសម្រាប់រយៈពេលខ្លី មធ្យម និងវែង និងតាមរយៈការបណ្តុះបណ្តាលដោយផ្ទាល់នៅនឹងកន្លែង និងការបណ្តុះបណ្តាលតាមអនឡាញ (Onsite Training and Online Training)។ ជាពិសេសជំរុញការបណ្តុះបណ្តាលពង្រឹងសមត្ថភាព

ដល់បុគ្គលិក មូលដ្ឋានអាជីវកម្ម និងភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍លើការប្រើប្រាស់បច្ចេកវិទ្យា និងការបង្កើតថ្មី និងអក្សរកម្មឌីជីថល

**២.** ជំរុញការវាយតម្លៃសមត្ថភាពអ្នកជំនាញទេសចរណ៍តាមរយៈការវាយតម្លៃផ្ទាល់នៅនឹងកន្លែង និងតាមរយៈការវាយតម្លៃតាមអនឡាញ (Onsite Assessment and Online Assessment) សំដៅបង្កើនជំនាញដល់បុគ្គលិក

**៣.** ជំរុញការចុះឈ្មោះរបស់អ្នកជំនាញទេសចរណ៍ និងផ្តល់ទិន្នន័យទាក់ទងនឹងកម្មវិធីបណ្តុះបណ្តាលរបស់ភាគីពាក់ព័ន្ធទៅក្នុងប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ www.tptd.org សំដៅលើកកម្ពស់គុណភាពបណ្តុះបណ្តាល និងបញ្ជាក់សមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងការបន្ស៊ីនឹងការអនុវត្តថ្នាលអនឡាញ CamDX

**៤.** អភិវឌ្ឍ និងចងក្រងឯកសារទ្រទ្រង់ការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាពទាំងនៅនឹងកន្លែង និងតាមអនឡាញ

**៥.** អភិវឌ្ឍស្តង់ដាសមត្ថភាពអ្នកជំនាញទេសចរណ៍ឆ្លើយតបនឹងទីផ្សារការងារក្នុងវិស័យទេសចរណ៍

**៦.** ជំរុញធ្វើទំនើបកម្មប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ការបណ្តុះបណ្តាលជំនាញទេសចរណ៍ និងវាយតម្លៃសមត្ថភាព សំដៅធានាជនគ្រប់រូបនៅគ្រប់ទីកន្លែងអាចទទួលបានការបណ្តុះបណ្តាលពេញមួយជីវិតក្នុងបរិបទការសិក្សាជំនាញក្នុងទម្លាប់ថ្មី

**៧.** ជំរុញលើកកម្ពស់ការអភិវឌ្ឍជំនាញ និងទីផ្សារការងារក្នុងវិស័យទេសចរណ៍ និងការបង្កើតមូលនិធិទ្រទ្រង់ការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍

**៨.** ជំរុញការរៀបចំការប្រឡងប្រណាំងសមត្ថភាពអ្នកជំនាញទេសចរណ៍ និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីក្នុងវិស័យទេសចរណ៍

**៩.** ជំរុញការចូលរួម និងបង្កើនកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធជំរុញការបណ្តុះបណ្តាល និងអភិវឌ្ឍជំនាញទេសចរណ៍

ដើម្បីចូលរួមសម្រេចនូវផែនការខាងលើ ចាំបាច់ត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងការគាំទ្រ អនុវត្ត និងសហការជំរុញសកម្មភាពបណ្តុះបណ្តាលឱ្យកាន់តែមានគុណភាព និងបរិមាណឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ។ សកម្មភាពបណ្តុះបណ្តាលត្រូវបានធ្វើឡើងដោយផ្តោតលើគោលដៅពីរពោលគឺ **ទី១.** ការបណ្តុះបណ្តាលដល់អ្នកដែលបាននឹងកំពុងបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ដោយប្រមាណជាង ៥០% បានឆ្លងកាត់ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពទាំងជំនាញបន្ថែម និងជំនាញថ្មី ដែលរៀបចំដោយមន្ទីរទេសចរណ៍ ឬសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញទេសចរណ៍ ឬអង្គភាព ស្ថាប័នរដ្ឋ និងឯកជន និងដៃគូអភិវឌ្ឍន៍ ដែលមានផ្តល់សេវាបណ្តុះបណ្តាលជំនាញ និង **ទី២.** ការបណ្តុះបណ្តាលសមត្ថភាព និងជំនាញមូលដ្ឋានពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ដល់យុវជន សិស្ស និស្សិត និងសាធារណជន ដែលមានបំណងចូលរួមចាប់យកអាជីពជាអ្នកជំនាញទេសចរណ៍ ដែលជាកម្លាំងពលកម្ម

ជំនាញថ្មីបន្ថែមសម្រាប់វិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ដោយភាគច្រើននៃយុវជន សិស្ស និស្សិត ទាំងអស់នោះ មិនទាន់មានជំនាញ និងមិនធ្លាប់បានឆ្លងកាត់ការបណ្តុះបណ្តាលជំនាញ និងពង្រឹងសមត្ថភាពមូលដ្ឋាននៅឡើយ។ ជាពិសេស ដើម្បីឱ្យមានការទទួលស្គាល់លើគុណភាពបណ្តុះបណ្តាល និងការវាយតម្លៃសមត្ថភាព ក៏ដូចជាដើម្បីធានាឱ្យបាននូវភាពសមមូលនៃសមត្ថភាព ជំនាញ និងកម្រិតវិញ្ញាបនបត្រ និងសញ្ញាបត្រជំនាញវិជ្ជាជីវៈទេសចរណ៍ ចាំបាច់ត្រូវមានការណែនាំរួមលើការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ ដែលរៀបចំដោយអង្គភាព ស្ថាប័ន ដែលមានការទទួលស្គាល់ត្រឹមត្រូវ និងច្បាស់លាស់។

ក្នុងន័យនេះ ជាការអនុវត្តដើម្បីឆ្លើយតបទៅនឹងការអនុវត្តការងារប្រកបដោយគុណភាព និងវិជ្ជាជីវៈ ក្រសួងទេសចរណ៍ ចាំបាច់ត្រូវរៀបចំ**គោលការណ៍ណែនាំស្តីពីការទទួលស្គាល់គុណភាពបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍** ដែលជាអភិក្រមរួមដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការធានាគុណភាពនៃការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ ជាពិសេសដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃ និងបញ្ជាក់សមត្ថភាពអ្នកជំនាញទេសចរណ៍ទាំងអស់។

## V. គោលការណ៍ណែនាំស្តីពីការទទួលស្គាល់ការបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍

គោលការណ៍ណែនាំស្តីពីការទទួលស្គាល់គុណភាពបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍ នឹងប្រើប្រាស់ជាគោលការណ៍សម្រាប់វាយតម្លៃ និងទទួលស្គាល់ការបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញទេសចរណ៍ ដូចខាងក្រោម៖

១ផ្តល់ការវាយតម្លៃ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាលគ្រប់ទម្រង់ និងគ្រប់កម្រិត ដែលធ្វើឡើងដោយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ មន្ទីរទេសចរណ៍ អង្គភាព ស្ថាប័នរដ្ឋ និងឯកជន មូលដ្ឋានអាជីវកម្មទេសចរណ៍ ក្រុមហ៊ុន និងដៃគូអភិវឌ្ឍន៍ ដែលមានផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍

២ផ្តល់ការវាយតម្លៃ និងទទួលស្គាល់គុណភាពវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍គ្រប់ទម្រង់ និងគ្រប់កម្រិត ដែលធ្វើឡើងដោយមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព

៣. ដើម្បីទទួលបានការទទួលស្គាល់គុណភាពបណ្តុះបណ្តាល និងការវាយតម្លៃសមត្ថភាព អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវស្នើសុំការវាយតម្លៃ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាល និងការវាយតម្លៃសមត្ថភាព ជាកាតព្វកិច្ច

៤. ផ្តល់ការទទួលស្គាល់ និងបញ្ជាក់សមត្ថភាពរបស់អ្នកជំនាញទេសចរណ៍ ដែលចាំបាច់ជាមូលដ្ឋានក្នុងការបំពេញការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ

៥. ការស្នើសុំទទួលស្គាល់សមត្ថភាពមូលដ្ឋាន ជាកាតព្វកិច្ចរបស់អ្នកជំនាញទេសចរណ៍

## VI. ការវាយតម្លៃ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍

### ៦.១. ការវាយតម្លៃ និងទទួលស្គាល់វគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍របស់អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍

ដើម្បីបង្កើតឱ្យមានប្រព័ន្ធមួយសម្រាប់ត្រួតពិនិត្យ តាមដាន និងទទួលស្គាល់វគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ និងវគ្គបណ្តុះបណ្តាលដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ និងពង្រឹងគុណភាពនៃការបណ្តុះបណ្តាលជំនាញទេសចរណ៍ និងជំនាញដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ ពិសេសធានាប្រសិទ្ធភាព និងការទទួលខុសត្រូវរបស់អ្នកផ្តល់ការបណ្តុះបណ្តាលជំនាញទេសចរណ៍ និងជំនាញដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ក្នុងការផ្តល់ការបណ្តុះបណ្តាល និងចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សាប្រកបដោយគុណភាព តម្លាភាព និងសុក្រឹតភាព អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ទាំងតាមរយៈការបណ្តុះបណ្តាលនៅនឹងកន្លែង និងតាមប្រព័ន្ធអនឡាញទាំងអស់ (ដែលរួមមាន **អង្គភាព-ស្ថាប័នរដ្ឋ មន្ទីរទេសចរណ៍ មូលដ្ឋានអាជីវកម្មទេសចរណ៍ គ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច វិទ្យាស្ថានបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច ដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុន/ស្ថាប័នឯកជន ដែលមានផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍**) ត្រូវអនុវត្តដូចខាងក្រោម៖

**១.** អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលមិនទាន់មានការទទួលស្គាល់ពីក្រសួងទេសចរណ៍ក្នុងការបើកវគ្គបណ្តុះបណ្តាលលើជំនាញទេសចរណ៍ និងវគ្គបណ្តុះបណ្តាលដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ទាំងអស់ ត្រូវធ្វើការស្នើសុំការទទួលស្គាល់វគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍ តាមរយៈការទំនាក់ទំនងមកកាន់នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៃក្រសួងទេសចរណ៍ ដើម្បីទទួលបានការអនុញ្ញាត និងការទទួលស្គាល់លើវគ្គបណ្តុះបណ្តាលរបស់ខ្លួន។

**២.** អ្នកផ្តល់ការបណ្តុះបណ្តាល ដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍ទាំងអស់ អាចធ្វើការស្នើសុំកិច្ចសហការ និងជំនួយបច្ចេកទេសបន្ថែមពីនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៃក្រសួងទេសចរណ៍ ដើម្បីធានាឱ្យបានថា វគ្គបណ្តុះបណ្តាលលើជំនាញទេសចរណ៍ និងវគ្គបណ្តុះបណ្តាលដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ ធ្វើឡើងប្រកបដោយគុណភាពស្របតាមស្តង់ដាជាតិ និងអាស៊ាន។

**៣.** ដើម្បីទទួលបានការទទួលស្គាល់វគ្គបណ្តុះបណ្តាលលើជំនាញទេសចរណ៍ និងវគ្គបណ្តុះបណ្តាលដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ អ្នកផ្តល់សេវាបណ្តុះបណ្តាលទាំងអស់ត្រូវ**រៀបចំផែនការបណ្តុះបណ្តាលលម្អិត រួមមានកម្មវិធីបណ្តុះបណ្តាល សមាសភាពគ្រូឧទ្ទេស និងឯកសារបណ្តុះបណ្តាល និងឯកសារពាក់ព័ន្ធផ្សេងៗ** រួចផ្ញើមកនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៃក្រសួងទេសចរណ៍ មុនពេលបើកវគ្គបណ្តុះបណ្តាល។ **នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នឹងធ្វើការកត់ត្រាការទទួលស្គាល់វគ្គបណ្តុះបណ្តាលដែលស្នើសុំ និងជូនដំណឹងដល់អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលបានស្នើសុំអំពីការទទួលស្គាល់វគ្គបណ្តុះបណ្តាលនោះផងដែរ។**

៤ អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ត្រូវរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលផ្សេងៗ ដែលមានភាពចាំបាច់ និងចូលរួមដល់ការអភិវឌ្ឍសមត្ថភាពលើជំនាញទេសចរណ៍ ស្របតាមស្តង់ដាសមត្ថភាពអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន ជាមួយការកំណត់តម្លៃសិក្សាសមរម្យ និងមានភាពអនុគ្រោះឈរលើគោលការណ៍ទីផ្សារ និងសមធម៌។

៥ អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ត្រូវធានាឱ្យបានថា ការចុះឈ្មោះចូលរៀនក្នុងវគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ នឹងត្រូវបានធ្វើឡើងដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត ដោយមិនមានបង្ខិតបង្ខំនោះឡើយ។

៦ អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញទាំងរយៈពេលខ្លី មធ្យម និងវែង ដែលអាចធ្វើការបន្សុីទៅនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ និងអាស៊ាន និងអាចជាច្រកបន្តការសិក្សាសម្រាប់សិក្ខាកាម។

៧ វិញ្ញាបនបត្របញ្ជាក់ការសិក្សា ត្រូវចេញដោយអ្នកផ្តល់សេវាបណ្តុះបណ្តាលសម្រាប់វគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ និងវគ្គបណ្តុះបណ្តាលដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ តាមកម្រិតដូចខាងក្រោម៖

**១. កម្រិតក្រសួងទេសចរណ៍**

ក.ក្រសួងទេសចរណ៍ ចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សាចំពោះវគ្គបណ្តុះបណ្តាលដែលរៀបចំដោយក្រសួងទេសចរណ៍ផ្ទាល់ តាមរយៈនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍។

ខ.ក្រសួងទេសចរណ៍នឹងបញ្ជាក់ទទួលស្គាល់លើវិញ្ញាបនបត្របញ្ជាក់ការសិក្សាចំពោះវគ្គបណ្តុះបណ្តាលដូចខាងក្រោម៖

- វគ្គបណ្តុះបណ្តាលរៀបចំឡើងក្រោមកិច្ចសហការជាមួយក្រសួងទេសចរណ៍
- វគ្គបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រជំនាញវិជ្ជាជីវៈរៀបចំអ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍។

**២. កម្រិតមន្ទីរទេសចរណ៍រាជធានី ខេត្ត**

ក.មន្ទីរទេសចរណ៍រាជធានី ខេត្ត ចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សាចំពោះវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មិនលើសពី **០១ សប្តាហ៍** ដែលរៀបចំដោយមន្ទីរទេសចរណ៍រាជធានី ខេត្ត។

ខ.មន្ទីរទេសចរណ៍រាជធានី ខេត្ត នឹងបញ្ជាក់ទទួលស្គាល់លើវិញ្ញាបនបត្របញ្ជាក់ការសិក្សាចំពោះវគ្គបណ្តុះបណ្តាលរយៈពេលខ្លីមិនលើសពី **០១ សប្តាហ៍** ដែលរៀបចំឡើងក្រោមកិច្ចសហការជាមួយមន្ទីរទេសចរណ៍រាជធានី ខេត្ត។

**៣. កម្រិតស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ និងមូលដ្ឋានអាជីវកម្ម**

ក.ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ (រួមមានគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជំនាញទេសចរណ៍ មជ្ឈមណ្ឌលបណ្តុះ

បណ្តុះបណ្តាលជំនាញទេសចរណ៍ វិទ្យាស្ថានបណ្តុះបណ្តាលជំនាញទេសចរណ៍ ទាំងរដ្ឋ និងឯកជន ដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុន/ស្ថាប័ន ដែលមានផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍) ដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍ និងមូលដ្ឋានអាជីវកម្មទេសចរណ៍ ដែលមានការទទួលស្គាល់វគ្គបណ្តុះបណ្តាលខាងក្នុងពីក្រសួងទេសចរណ៍ អាចចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សាចំពោះវគ្គបណ្តុះបណ្តាល ដែលរៀបចំដោយស្ថាប័នខ្លួនផ្ទាល់។

ខ.ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ និងមូលដ្ឋានអាជីវកម្មទេសចរណ៍ ដែលមានរៀបចំវគ្គបណ្តុះបណ្តាលខាងក្នុង នឹងទទួលបានការបញ្ជាក់ទទួលស្គាល់លើវិញ្ញាបនបត្របញ្ជាក់ការសិក្សាពីក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី ខេត្តចំពោះវគ្គបណ្តុះបណ្តាលដូចខាងក្រោមៈ

- វគ្គបណ្តុះបណ្តាលរយៈពេលខ្លីដែលរៀបចំឡើងក្រោមកិច្ចសហការជាមួយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី ខេត្ត
- វគ្គបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រជំនាញវិជ្ជាជីវៈរៀបចំដោយស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ត្រូវទទួលការបញ្ជាក់ទទួលស្គាល់ពីក្រសួងទេសចរណ៍។

៨ វិញ្ញាបនបត្របញ្ជាក់ការសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលលើជំនាញទេសចរណ៍ និងវគ្គបណ្តុះបណ្តាលដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ ដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍ទាំងអស់ តម្រូវឱ្យប្រើប្រាស់តាមគំរូវិញ្ញាបនបត្រ ដែលចេញ និងទទួលស្គាល់ដោយក្រសួងទេសចរណ៍។

៩. វិញ្ញាបនបត្របញ្ជាក់ការសិក្សាអាចត្រូវបានបញ្ជាក់ជាថ្មីចំនួន ០២ (ពីរ) លើក ក្នុងករណីវិញ្ញាបនបត្រច្បាប់ដើមមានការបាត់បង់ក្នុងប្រការណាមួយ។

១០. វិញ្ញាបនបត្របញ្ជាក់ការសិក្សា នឹងមិនត្រូវចេញជូនតាមការស្នើសុំរបស់អ្នកផ្តល់សេវាបណ្តុះបណ្តាល ក្នុងករណី ក្រសួងទេសចរណ៍រកឃើញថា វគ្គបណ្តុះបណ្តាលដែលរៀបចំឡើងនោះ មិនបានគោរពតាមការណែនាំរបស់ក្រសួងទេសចរណ៍។

១១ ដើម្បីធានាឱ្យមានប្រព័ន្ធមួយសម្រាប់ត្រួតពិនិត្យ តាមដាន និងទទួលស្គាល់វគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ និងវគ្គបណ្តុះបណ្តាល ដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ ព្រមទាំងតាមដាន និងកត់ត្រាអំពីសមត្ថភាព និងគុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ត្រូវបញ្ចូលទិន្នន័យទាក់ទងនឹងវគ្គបណ្តុះបណ្តាលជំនាញ ដែលខ្លួនបានបើកក្រោមទម្រង់ជាវគ្គខ្លី មធ្យម និងវែង និងក្រោមទម្រង់កិច្ចសហប្រតិបត្តិការជាមួយដៃគូសហការផ្សេងៗ ទៅក្នុងប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍របស់ក្រសួងទេសចរណ៍ (ដែលមានអាសយដ្ឋានគេហទំព័រ www.tptd.org) និងត្រូវសហការជាមួយក្រុមការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមត្ថភាពអ្នកជំនាញទេសចរណ៍ ដើម្បីធ្វើការប្រមូល និងបញ្ចូល និងធ្វើបច្ចុប្បន្នភាពទិន្នន័យពាក់ព័ន្ធនឹងសមត្ថភាព ជំនាញ និងចំនួនសិស្ស សិក្ខាកាម ដែលបានសិក្សានៅក្នុងស្ថាប័នរបស់ខ្លួន។

**១២.** ក្រសួងទេសចរណ៍ មានសិទ្ធិបដិសេធទៅនឹងការទទួលស្គាល់អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ក្នុងករណីៈ

ក. អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ មិនបានស្នើសុំការទទួលស្គាល់លើវគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ និងវគ្គបណ្តុះបណ្តាល ដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ជាមុន ពីក្រសួងទេសចរណ៍

ខ. អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ មិនបានគោរពតាមការណែនាំរបស់ក្រសួងទេសចរណ៍

គ. អ្នកផ្តល់សេវាបណ្តុះបណ្តាលផ្តល់ព័ត៌មានមិនពិត ឬក្លែងបន្លំ

ឃ.អ្នកផ្តល់សេវាបណ្តុះបណ្តាលផ្តល់សិទ្ធិឱ្យស្ថាប័ន ឬអង្គភាពផ្សេង ដែលមិនមានការទទួលស្គាល់ពីក្រសួងទេសចរណ៍ធ្វើការបណ្តុះបណ្តាលជំនួសខ្លួន

ង. អ្នកផ្តល់សេវាបណ្តុះបណ្តាលបានប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើមិនស្របច្បាប់ណាមួយ ដែលក្រសួងទេសចរណ៍យល់ថាជាទង្វើមិនសមស្របជាអ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ និងជំនាញដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍។

**១៣.** ក្នុងករណីបដិសេធមិនទទួលស្គាល់ការបណ្តុះបណ្តាល ក្រសួងទេសចរណ៍ នឹងចេញលិខិតជាលាយលក្ខណ៍អក្សរ ដោយមានការបញ្ជាក់ពីមូលហេតុច្បាស់លាស់អំពីការបដិសេធមិនទទួលស្គាល់លើការបណ្តុះបណ្តាល និងបញ្ជូនទៅឱ្យអ្នកផ្តល់សេវាបណ្តុះបណ្តាលនោះ។ បន្ទាប់ពីការបដិសេធមិនទទួលស្គាល់ការបណ្តុះបណ្តាល អ្នកផ្តល់សេវាបណ្តុះបណ្តាល ត្រូវបញ្ឈប់ជាបន្ទាន់នូវសកម្មភាពបណ្តុះបណ្តាល ហើយអស់សិទ្ធិជាអ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលមានការទទួលស្គាល់ដោយក្រសួងទេសចរណ៍។

**១៤.** អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ និងជំនាញដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ ដែលប្រព្រឹត្តល្មើសនឹងគោលការណ៍ណែនាំ ត្រូវទទួលទណ្ឌកម្ម ដូចខាងក្រោមៈ

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្អាក ឬបិទវគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ និងជំនាញ ដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ជាបណ្តោះអាសន្ន
- ការបិទមិនឱ្យបើកវគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ និងជំនាញ ដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ជាស្ថាពរ។

**១៥.** ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ ក្រោយពីការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬក្នុងករណីចាំបាច់ ក្រសួងទេសចរណ៍ មានសិទ្ធិចុះធ្វើការត្រួតពិនិត្យលើដំណើរការបណ្តុះបណ្តាល និងសម្ភារទ្រទ្រង់ការបណ្តុះបណ្តាលផ្សេងៗ រួមទាំងកម្មវិធីបណ្តុះបណ្តាល ដោយមិនកំណត់ពេលវេលា។

**១៦.** អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍ដើម្បីធ្វើការត្រួតពិនិត្យឱ្យមានប្រសិទ្ធភាព។ ក្នុងករណីចាំបាច់ និងដើម្បីពង្រឹងនូវប្រសិទ្ធភាពនៃការគ្រប់គ្រងការបណ្តុះបណ្តាល ក្រសួងទេសចរណ៍អាចនឹងបញ្ជូនភ្នាក់ងារ

ចុះពិនិត្យជាប្រចាំ ឬត្រួតពិនិត្យចៃដន្យទៅលើវគ្គបណ្តុះបណ្តាល ដើម្បីក្រសួងទេសចរណ៍មានលទ្ធភាពក្តាប់អំពីស្ថានភាព និងគុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ និងជំនាញ ដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ផ្សេងៗទៀត។

**១៧.** ភាសាប្រើប្រាស់សម្រាប់ការបណ្តុះបណ្តាល និងវិញ្ញាបនបត្របញ្ជាក់ការសិក្សា នឹងកំណត់តាមប្រភេទនៃមុខជំនាញ ដែលតម្រូវឆ្លើយតបទៅនឹងទីផ្សារការងារក្នុងវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច និងការធ្វើដំណើរ។

**៦.២. លក្ខណវិនិច្ឆ័យវាយតម្លៃ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាលរបស់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍**

ដើម្បីទទួលបានការទទួលស្គាល់លើគុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ និងជំនាញដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ (ដែលរួមមាន **គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញទេសចរណ៍ វិទ្យាស្ថានបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងរដ្ឋ និងឯកជន ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ក្រុមហ៊ុន/ស្ថាប័ន ដែលមានផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍**) ត្រូវបំពេញតាម ស្តង់ដានៃការទទួលស្គាល់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ដូចគ្នា ដែលមានលក្ខណវិនិច្ឆ័យចំនួន **១១** និងសូចនាករចំនួន **៤៦** ដូចមានក្នុងតារាងខាងក្រោម៖

| **ការទទួលស្គាល់គុណភាពបណ្តុះបណ្តាលរបស់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍** | **លក្ខណវិនិច្ឆ័យ/សូចនាករ** | **ភស្តុតាង** | **ពិន្ទុ** |
|---|---|---|---|
| | ការទទួលស្គាល់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ ជាការជំរុញការលើកកម្ពស់ការអភិវឌ្ឍសមត្ថភាព ជំនាញ និងគុណវុឌ្ឍិរបស់អ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរឱ្យឆ្លើយតបទៅនឹងស្តង់ដាជាតិ និងអាស៊ាន ដែលចូលរួមលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍ និងជំរុញការយកចិត្តទុកដាក់លើការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ សំដៅសម្រេចការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយគុណភាព បរិយាប័ន្ន និងការទទួលខុសត្រូវ។ | | |
| | ***១.ចក្ខុវិស័យ បេសកកម្ម និងគោលដៅ*** | | |
| | ១.១.ចក្ខុវិស័យ បេសកកម្ម និងគោលដៅ ឆ្លើយតបទៅនឹងគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងឆ្លើយតបទៅនឹងតម្រូវការថ្នាក់ជាតិ តំបន់ និងអន្តរជាតិ | មាន-មិនមាន | ០២ |
| | ១.២.ការជំរុញអនុវត្តដោយប្រកាន់ខ្ជាប់តាមចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់ស្ថាប័ន | មាន-មិនមាន | ០២ |
| | ***២.អភិបាលកិច្ច និងការគ្រប់គ្រង*** | | |
| | ២.១.មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ | មាន-មិនមាន | ០២ |

| | | | |
|---|---|---|---|
| | ២.២. ភាពទៀងទាត់នៃការវាយតម្លៃប្រសិទ្ធភាពការងារអភិបាលកិច្ច និងការគ្រប់គ្រង | មាន-មិនមាន | ០២ |
| | ***៣. ធនធានរូបវ័ន្ត*** | | |
| | ៣.១. មានការចុះបញ្ជី និងទទួលស្គាល់ការបណ្តុះបណ្តាលពីក្រសួងទេសចរណ៍ | មាន-មិនមាន | ០៤ |
| | ៣.២. មានធនធានរូបវ័ន្តគ្រប់គ្រាន់ | មាន-មិនមាន | ០២ |
| | ៣.៣. មានការគិតគូរពីការរក្សាបរិស្ថានជុំវិញ ផាសុកភាព និងសុវត្ថិភាព | មាន-មិនមាន | ០២ |
| | ៣.៤. មានបុគ្គលិកបម្រើការគ្រប់គ្រាន់ | មាន-មិនមាន | ០២ |
| | ៣.៥. អភិវឌ្ឍរូបវ័ន្តទ្រទ្រង់ការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ | មាន-មិនមាន | ០២ |
| | ៣.៦. មានផែនការអភិវឌ្ឍន៍ធនធានរូបវ័ន្តច្បាស់លាស់ | មាន-មិនមាន | ០២ |
| | ***៤. ការរៀបចំ និងអនុវត្តផែនការបណ្តុះបណ្តាលជំនាញទេសចរណ៍*** | | |
| | ៤.១. មានការរៀបចំផែនការបណ្តុះបណ្តាលជំនាញទេសចរណ៍ប្រចាំឆ្នាំ | មាន-មិនមាន | ០២ |
| | ៤.២. ការសម្រេចបានតាមផែនការបណ្តុះបណ្តាលជំនាញទេសចរណ៍ | មាន-មិនមាន | ០២ |
| | ៤.៣. មានផែនការសហការជាមួយក្រសួងទេសចរណ៍ និងភាគីពាក់ព័ន្ធជំរុញការបណ្តុះបណ្តាលជំនាញទេសចរណ៍ | មាន-មិនមាន | ០២ |
| | ៤.៤. មានការជំរុញបង្កើតមូលនិធិទ្រទ្រង់ការបណ្តុះបណ្តាល | មាន-មិនមាន | ០២ |
| | ***៥. កម្មវិធីបណ្តុះបណ្តាល ឯកសារបណ្តុះបណ្តាល និងធនធានសិក្សា*** | | |
| | ៥.១.មានក្រុមការងារ ឬគណៈកម្មការអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាល និងចងក្រងឯកសារបណ្តុះបណ្តាល | មាន-មិនមាន | ០៣ |
| | ៥.២. កម្មវិធីបណ្តុះបណ្តាលជំនាញទេសចរណ៍មានខ្លឹមសារច្បាស់លាស់ និងស្របតាមស្តង់ដាជាតិ និងអាស៊ាន | មាន-មិនមាន | ០៣ |
| | ៥.៣. មានឯកសារទ្រទ្រង់ការបណ្តុះបណ្តាលគ្រប់គ្រាន់រួមមានឯកសារសម្រាប់គ្រូ និងសិស្ស | មាន-មិនមាន | ០៣ |
| | ៥.៤. មានយន្តការកំណត់ចំនួនសមត្ថភាព ឬចំនួនក្រេឌីតសិក្សា និង | មាន-មិនមាន | ០៣ |

| | | | |
|---|---|---|---|
| | គោលការណ៍នៃការបន្ស៊ីនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ និងអាស៊ាន | | |
| | ៥.៥. មានវិធីសាស្ត្រ និងឧបករណ៍វាយតម្លៃសមត្ថភាពរបស់សិក្ខាកាមច្បាស់លាស់ និងគ្រប់គ្រាន់ | មាន-មិនមាន | ០២ |
| | ៥.៦. មានការត្រួតពិនិត្យ វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាល និងឯកសារបណ្តុះបណ្តាលយ៉ាងទៀងទាត់ស្របតាមតម្រូវការវិវត្តន៍របស់ជំនាញទេសចរណ៍កម្រិតជាតិ និងអាស៊ាន | មាន-មិនមាន | ០២ |
| | ៥.៧. មានធនធានសិក្សា (បណ្ណាល័យ កន្លែងអនុវត្តជំនាញ និងឯកសារសិក្សាផ្សេងៗ) | មាន-មិនមាន | ០២ |
| | ***៦. ការធានាឱ្យមានសាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល និងបុគ្គលិកជំនាញដែលមានសមត្ថភាពគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព*** | | |
| | ៦.១.ចំណេះដឹង ជំនាញ គុណវុឌ្ឍិ និងបទពិសោធន៍របស់សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល ស្របទៅនឹងជំនាញ និងកម្រិតបណ្តុះបណ្តាល | មាន-មិនមាន | ០៣ |
| | ៦.២.មានដំណើរការច្បាស់លាស់ និងតម្លាភាពក្នុងការជ្រើសរើស អភិវឌ្ឍ វាយតម្លៃ លើកទឹកចិត្ត និងរក្សាទុកសាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល | មាន-មិនមាន | ០២ |
| | ៦.៣.បរិមាណសាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលលើជំនាញទេសចរណ៍ មានចំនួនគ្រប់គ្រាន់ដោយធៀបទៅនឹងតម្រូវការបណ្តុះបណ្តាល | មាន-មិនមាន | ០២ |
| | ៦.៤.សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃ បង្គោលមានសមត្ថភាព និងចំណេះដឹងទាក់ទងនឹងនិន្នាការថ្មីៗ នៃការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការអភិវឌ្ឍជំនាញទេសចរណ៍ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ | មាន-មិនមាន | ០៣ |
| | ៦.៥.គរុកោសល្យបណ្តុះបណ្តាលរបស់សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលលើជំនាញទេសចរណ៍ | មាន-មិនមាន | ០២ |
| | ៦.៦.មានការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់បុគ្គលិកទាក់ទងនឹងនិន្នាការថ្មីៗនៃការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការអភិវឌ្ឍជំនាញទេសចរណ៍ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ | មាន-មិនមាន | ០២ |
| | ***៧. ការដំណើរការវគ្គបណ្តុះបណ្តាលប្រកបដោយនិរន្តរភាព និងគុណភាព*** | | |
| | ៧.១. ការរៀបចំសម្ភារបរិក្ខារទ្រទ្រង់ដល់ដំណើរការបណ្តុះបណ្តាល | មាន-មិនមាន | ០២ |

| | | | |
|---|---|---|---|
| | ៧.២. មានសមត្ថភាពរៀបចំដំណើរការវគ្គបណ្តុះបណ្តាលទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស | មាន-មិនមាន | ០២ |
| | ៧.៣. មានរៀបចំនីតិវិធី និងបទបញ្ជាផ្ទៃក្នុងច្បាស់លាស់សម្រាប់វគ្គបណ្តុះបណ្តាល | មាន-មិនមាន | ០២ |
| | ***៨. ការគ្រប់គ្រងវគ្គបណ្តុះបណ្តាលប្រកបដោយនិរន្តរភាព និងគុណភាព*** | | |
| | ៨.១.មានការត្រួតពិនិត្យ និងតាមដានវគ្គបណ្តុះបណ្តាល | មាន-មិនមាន | ០២ |
| | ៨.២. ការធ្វើបច្ចុប្បន្នកម្មវគ្គបណ្តុះបណ្តាល | មាន-មិនមាន | ០២ |
| | ៨.៣. មានការវាយតម្លៃគុណភាព និងលទ្ធផលនៃវគ្គបណ្តុះបណ្តាល | មាន-មិនមាន | ០២ |
| | ៨.៤. មានរៀបចំរបាយការណ៍អំពីវគ្គបណ្តុះបណ្តាលបញ្ជូនមកក្រសួងទេសចរណ៍ | មាន-មិនមាន | ០២ |
| | ***៩. សមត្ថភាពធនធានហិរញ្ញវត្ថុ និងការឧបត្ថម្ភធនសម្រាប់ទ្រទ្រង់ការបណ្តុះបណ្តាល*** | | |
| | ៩.១. មានផ្តល់ជូនការបណ្តុះបណ្តាលក្នុងតម្លៃសិក្សាទាប | មាន-មិនមាន | ០២ |
| | ៩.២. មានផ្តល់ជូនការបណ្តុះបណ្តាលដោយមិនគិតថ្លៃ | មាន-មិនមាន | ០២ |
| | ៩.៣. មានផ្តល់ជូនកម្ចីសិក្សាដល់សិក្ខាកាម | មាន-មិនមាន | ០២ |
| | ៩.៤.មានកញ្ចប់ថវិកាសមស្របសម្រាប់គាំទ្រការអភិវឌ្ឍជំនាញដល់សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល និងបុគ្គលិកជំនាញ | មាន-មិនមាន | ០២ |
| | ៩.៥.មានកញ្ចប់ថវិកាសមស្របសម្រាប់គាំទ្រដល់ការសិក្សាស្រាវជ្រាវអភិវឌ្ឍជំនាញទេសចរណ៍ | មាន-មិនមាន | ០២ |
| | ***១០. ការគិតគូរអំពីការស្វែងរកឱកាសការងារ និងកម្មសិក្សាការងារ និងការផ្តល់សេវាដល់សិក្ខាកាម*** | | |
| | ១០.១. មានការណែនាំការងារសម្រាប់សិក្ខាកាមបន្ទាប់ពីបញ្ចប់វគ្គ | មាន-មិនមាន | ០២ |
| | ១០.២. មានរៀបចំកម្មសិក្សាការងារដល់សិក្ខាកាម | មាន-មិនមាន | ០២ |
| | ១០.៣. មានគោលនយោបាយ និងគោលការណ៍ស្តីពីការផ្តល់អាហារូបករណ៍ | មាន-មិនមាន | ០២ |
| | ១០.៤.មានការណែនាំ និងតម្រង់ទិសការសិក្សា និងការងារដល់សិក្ខាកាម | មាន-មិនមាន | ០២ |

| | | | |
|---|---|---|---|
| | ១០.៥.មានគោលនយោបាយ ឬគោលការណ៍ និងនីតិវិធីច្បាស់លាស់ ក្នុងការដោះស្រាយរាល់បណ្ដឹងតវ៉ាផ្សេងៗ របស់សិក្ខាកាម | មាន-មិនមាន | ០២ |
| | ***១១. ការធានាគុណភាពផ្ទៃក្នុង*** | | |
| | ១១.១.មានប្រព័ន្ធធានាគុណភាពផ្ទៃក្នុងច្បាស់លាស់ | មាន-មិនមាន | ០២ |
| | ១១.២.មានការចូលរួម និងគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធខាងក្នុងស្ថាប័ន លើដំណើរការធានាគុណភាពបណ្ដុះបណ្ដាល | មាន-មិនមាន | ០២ |
| **លក្ខណវិនិច្ឆ័យសរុប ១១ និងសូចនាករសរុប ៤៦ ស្មើនឹង ១០០ ពិន្ទុ** | | | |

**សេចក្ដីអត្ថាធិប្បាយពីលក្ខណៈវិនិច្ឆ័យ និងសូចនាករ**

ដើម្បីទទួលបានការបញ្ជាក់ និងទទួលស្គាល់គុណភាពបណ្ដុះបណ្ដាល ស្ថាប័នបណ្ដុះបណ្ដាលជំនាញទេសចរណ៍ទាំងរដ្ឋ និងឯកជនទាំងអស់ ត្រូវអនុវត្តតាមលក្ខណវិនិច្ឆ័យ និងសូចនាករនៃស្តង់ដាទទួលស្គាល់គុណភាពបណ្ដុះបណ្ដាលជំនាញទេសចរណ៍ ដែលមានដូចខាងក្រោម៖

**ក. លក្ខណវិនិច្ឆ័យទី១. *ចក្ខុវិស័យ បេសកកម្ម និងគោលដៅ***

ស្ថាប័នបណ្ដុះបណ្ដាលជំនាញទេសចរណ៍ទាំងអស់ត្រូវកំណត់ចក្ខុវិស័យ បេសកកម្ម និងគោលដៅឱ្យបានច្បាស់លាស់ និងត្រូវផ្សារភ្ជាប់ទៅនឹងតម្រូវការរបស់ជាតិ តំបន់ និងអន្តរជាតិ ជាពិសេសចូលរួមសម្រេចនូវគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍នៅកម្ពុជា។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន ០២ ដែលស្ថាប័នបណ្ដុះបណ្ដាលជំនាញទេសចរណ៍ទាំងអស់ត្រូវមាន និងអនុវត្តតាម៖

➢ **សូចនាករទី១. ចក្ខុវិស័យ បេសកកម្ម និងគោលដៅ ឆ្លើយតបទៅនឹងគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងឆ្លើយតបទៅនឹងតម្រូវការថ្នាក់ជាតិ តំបន់ និងអន្តរជាតិ**

ស្ថាប័នបណ្ដុះបណ្ដាលជំនាញទេសចរណ៍ ត្រូវបង្ហាញចក្ខុវិស័យ បេសកកម្ម និងគោលដៅ ក្នុងការចូលរួមលើកកម្ពស់ការបណ្ដុះបណ្ដាលជំនាញទេសចរណ៍ឱ្យឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជំនាញ និងធនធានមនុស្សទាំងក្នុងកម្រិតថ្នាក់ជាតិ អាស៊ាន តំបន់ និងអន្តរជាតិ។

➢ **សូចនាករទី២. ការជំរុញអនុវត្តដោយប្រកាន់ខ្ជាប់តាមចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់ស្ថាប័ន**

ស្ថាប័នបណ្ដុះបណ្ដាលជំនាញទេសចរណ៍ ត្រូវជំរុញ និងសហការអនុវត្តការងារដោយប្រកាន់ខ្ជាប់តាមចក្ខុវិស័យ បេសកកម្ម និងគោលដៅ ដែលស្ថាប័នបានកំណត់ និងត្រូវតាមដាន ព្រមទាំងកែតម្រូវការអនុវត្តការងារឱ្យបានត្រឹមត្រូវយ៉ាងទៀងទាត់។

**ខ. លក្ខណៈវិនិច្ឆ័យទី២. *អភិបាលកិច្ច និងការគ្រប់គ្រង***

ការគ្រប់គ្រង និងអភិបាលកិច្ចល្អ នឹងជួយឱ្យស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ទទួលបានជោគជ័យក្នុងការសម្រេចចក្ខុវិស័យ បេសកកម្ម និងគោលដៅប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន **០២** ដែលស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ត្រូវមាន និងអនុវត្តតាម៖

➢ **សូចនាករទី១. រចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់**

ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងបានល្អ នឹងជួយដល់ការកំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អង្គភាពនីមួយៗ រួមទាំងក្រុមប្រឹក្សាភិបាល គណៈកម្មការ និងគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ ក្នុងការសម្រេចតាមផែនការរបស់ស្ថាប័ន។

➢ **សូចនាករទី២. ភាពទៀងទាត់នៃការវាយតម្លៃប្រសិទ្ធភាពការងារអភិបាលកិច្ច និងការគ្រប់គ្រង**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពការងារគ្រប់គ្រង និងអភិបាលកិច្ចឱ្យបានទៀងទាត់។ ការវាយតម្លៃអាចត្រូវបានធ្វើឡើងជាត្រីមាស ឆមាស និងប្រចាំឆ្នាំ និងត្រូវមានកំណត់ហេតុ ឬរបាយការណ៍វាយតម្លៃការងារ។

**គ. លក្ខណៈវិនិច្ឆ័យទី៣. *ធនធានរូបវ័ន្ត***

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលអាចធ្វើការបណ្តុះបណ្តាលត្រូវសុំការទទួលស្គាល់លើការបណ្តុះបណ្តាលជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍ ព្រមទាំងត្រូវរៀបចំធនធានរូបវ័ន្តឱ្យមានភាពគ្រប់គ្រាន់សម្រាប់ធ្វើការបណ្តុះបណ្តាលលើជំនាញនេះ។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន **០៦** ដែលស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

➢ **សូចនាករទី១. មានការចុះបញ្ជី និងទទួលស្គាល់ការបណ្តុះបណ្តាលពីក្រសួងទេសចរណ៍**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវធ្វើការចុះបញ្ជី និងស្នើសុំទទួលស្គាល់លើការបណ្តុះបណ្តាលជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍។ ដើម្បីធានាបាននូវគុណភាពបណ្តុះបណ្តាល ការចុះបញ្ជី និងការស្នើសុំទទួលស្គាល់ការបណ្តុះបណ្តាលជាលក្ខខណ្ឌតម្រូវចាំបាច់ ដែលស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ត្រូវអនុវត្ត។

➢ **សូចនាករទី២. មានធនធានរូបវ័ន្តគ្រប់គ្រាន់**

ដើម្បីបំពេញលក្ខខណ្ឌទទួលស្គាល់លើការបណ្តុះបណ្តាលជំនាញទេសចរណ៍ ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវរៀបចំសម្ភារទ្រទ្រង់ការបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់ ជាពិសេស ទីកន្លែងអាគារសិក្សា បន្ទប់សិក្សាសម្រាប់ធ្វើការបណ្តុះបណ្តាល បន្ទប់ហ្វឹកហាត់ការអនុវត្ត បន្ទប់ប្រជុំ សាលសហសិក្សា ការផ្គត់ផ្គង់អគ្គិសនី និងទឹកគ្រប់គ្រាន់។ ទីតាំងអាគារ និងបន្ទប់សិក្សា ត្រូវមានការរៀបចំមានលក្ខណៈសមស្របទៅនឹងការសិក្សាតាមមុខជំនាញនីមួយៗ។

ៀ

➢ **សូចនាករទី៣. មានការគិតគូរពីការរក្សាបរិស្ថានជុំវិញ ផាសុកភាព និងសុវត្ថិភាព**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវរៀបចំឱ្យមានទីធ្លា បន្ទប់សិក្សា និងបន្ទប់អនុវត្ត ព្រមទាំងធនធានរូបវ័ន្តផ្សេងៗ ទៀត ប្រកបដោយបរិស្ថានល្អ និងផ្តល់ផាសុកភាព និងសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្តដល់សិក្ខាកាម សាស្ត្រាចារ្យ គ្រូឧទ្ទេស និងអ្នកវាយតម្លៃ ព្រមទាំងបុគ្គលិក។

➢ **សូចនាករទី៤. មានបុគ្គលិកបម្រើការគ្រប់គ្រាន់**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវរៀបចំឱ្យមានបុគ្គលិកជំនាញរាប់ទាំងបុគ្គលិកជាសាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល និងបុគ្គលិកការិយាល័យផ្សេងទៀត ឱ្យបានគ្រប់គ្រាន់ដើម្បីបំពេញការងារទៅតាមផ្នែក និងមុខងារនៅក្នុងស្ថាប័ន។

➢ **សូចនាករទី៥. អភិវឌ្ឍរូបវ័ន្តទ្រទ្រង់ការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ**

ដើម្បីចូលរួមជំរុញការបណ្តុះបណ្តាលជំនាញឆ្លើយតបទៅនឹងការវិវត្តន៍នៃបច្ចេកវិទ្យាឌីជីថល ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានការគិតគូររៀបចំឱ្យមានបន្ទប់ ឬមណ្ឌល ដែលមានបំពាក់ឧបករណ៍ និងសម្ភារបច្ចេកទេស និងកុំព្យូទ័រដើម្បីសម្រួលដល់ការបើកវគ្គបណ្តុះបណ្តាលពីចម្ងាយ ឬតាមប្រព័ន្ធអនឡាញ។ ការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ នឹងចូលរួមជួយដល់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ បង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការបណ្តុះបណ្តាល។

➢ **សូចនាករទី៦. មានផែនការអភិវឌ្ឍន៍ធនធានរូបវ័ន្តច្បាស់លាស់**

ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការបណ្តុះបណ្តាលជំនាញ និងស្របតាមការអភិវឌ្ឍរបស់ស្ថាប័នស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានផែនការអភិវឌ្ឍន៍ធនធានរូបវ័ន្ត ដោយរៀបចំឡើងស្របនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ស្ថាប័ន។

**ឃ. លក្ខណៈវិនិច្ឆ័យទី៤** ***ការរៀបចំ និងអនុវត្តផែនការបណ្តុះបណ្តាលជំនាញទេសចរណ៍***

ដើម្បីធានានិរន្តរភាព និងគុណភាពនៃការបណ្តុះបណ្តាល ការរៀបចំផែនការបណ្តុះបណ្តាលជំនាញទេសចរណ៍ ពិតជាមានសារៈសំខាន់ណាស់។ ក្នុងន័យនេះ ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ត្រូវមានផែនការបណ្តុះបណ្តាលជំនាញទេសចរណ៍របស់ខ្លួន សំដៅធានាឱ្យការបណ្តុះបណ្តាលនៅក្នុងស្ថាប័នរបស់ខ្លួនដំណើរការប្រកបដោយនិរន្តរភាព ប្រសិទ្ធភាព និងគុណភាព ឆ្លើយតបទៅនឹងតម្រូវការទីផ្សារជំនាញទេសចរណ៍ និងការវិវត្តន៍ថ្មីៗ នៃទីផ្សារសេវាកម្មទេសចរណ៍។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន ០៤ ដែលស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ត្រូវមាន និងអនុវត្តតាម៖

➢ **សូចនាករទី១. មានការរៀបចំផែនការបណ្តុះបណ្តាលជំនាញទេសចរណ៍ប្រចាំឆ្នាំ**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវរៀបចំផែនការបណ្តុះបណ្តាលរបស់ខ្លួនប្រចាំឆ្នាំ។ ការរៀបចំផែនការបណ្តុះបណ្តាលជំនាញទេសចរណ៍បានល្អ នឹងអាចចូលរួមជួយដល់ការអនុវត្តសកម្មភាពបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពយុវជន សិស្ស និស្សិត និងអ្នកជំនាញទេសចរណ៍ឱ្យមានសមត្ថភាពជំនាញ ចំណេះដឹង ស្របតាមការវិវត្តន៍ថ្មីៗ នៃវិស័យទេសចរណ៍ ជាពិសេសការអភិវឌ្ឍជំនាញថ្មីៗ ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ។

➢ **សូចនាករទី២. ការសម្រេចបានតាមផែនការវគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវខិតខំជំរុញការបណ្តុះបណ្តាលជំនាញទេសចរណ៍ឱ្យបានសកម្ម ស្របតាមផែនការបណ្តុះបណ្តាលរបស់ខ្លួន។ ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ត្រូវសម្រេចឱ្យបានយ៉ាងហោចណាស់ ៧០% នៃសកម្មភាពអនុវត្ត តាមផែនការដែលបានដាក់ចេញរបស់ខ្លួន។

➢ **សូចនាករទី៣. មានផែនការសហការជាមួយក្រសួងទេសចរណ៍ និងភាគីពាក់ព័ន្ធជំរុញការបណ្តុះបណ្តាលជំនាញទេសចរណ៍**

ដើម្បីចូលរួមកាន់តែសកម្មនៅក្នុងបេសកកម្មផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ចាំបាច់ត្រូវអនុវត្តតាមការណែនាំផ្សេងៗ របស់ក្រសួងទេសចរណ៍ទាក់ទងទៅនឹងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍។ ជាពិសេស ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានផែនការសហការជាមួយក្រសួង និងភាគីពាក់ព័ន្ធទាំងអស់ក្នុងការរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលផ្សេងៗ ដល់យុវជន សិស្ស និស្សិត និងអ្នកជំនាញទេសចរណ៍។

➢ **សូចនាករទី៤. មានការជំរុញបង្កើតមូលនិធិទ្រទ្រង់ការបណ្តុះបណ្តាល**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានការគិតគូរឱ្យមានមូលនិធិទ្រទ្រង់ដល់ការបណ្តុះបណ្តាលសម្រាប់ជួយដល់យុវជន សិស្ស និស្សិត ឬសិក្ខាកាមដែលបាន និងកំពុងសិក្សានៅក្នុងស្ថាប័នរបស់ខ្លួន។

**ង. លក្ខណវិនិច្ឆ័យទី៥. *កម្មវិធីបណ្តុះបណ្តាល ឯកសារបណ្តុះបណ្តាល និងធនធានសិក្សា***

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលឱ្យមានភាពច្បាស់លាស់ ដែលនៅក្នុងកម្មវិធីបណ្តុះបណ្តាលទាំងអស់ ត្រូវមានបញ្ជាក់ឱ្យបានច្បាស់អំពីមេរៀន ដែលនឹងត្រូវធ្វើការបណ្តុះបណ្តាល ចំនួនម៉ោងសិក្សា វិធីសាស្ត្រ និងឧបករណ៍ក្នុងការបង្រៀន ជាពិសេសត្រូវមានឯកសារគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ដល់ដំណើរការបណ្តុះបណ្តាលរួមមានឯកសារសម្រាប់គ្រូ ឯកសារសម្រាប់សិស្ស និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ពាក់ព័ន្ធទៅនឹងការវាយតម្លៃបន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល រួមទាំងធនធានសិក្សា ដែលរួមមាន បណ្ណាល័យ និងកន្លែងអនុវត្តជំនាញផងដែរ។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន ០៧ ដែលស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

➢ **សូចនាករទី១.មានក្រុមការងារ ឬគណៈកម្មការអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាល និងចងក្រង ឯកសារបណ្តុះបណ្តាល**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវរៀបចំបង្កើតក្រុមការងារ ឬគណៈកម្មការអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាល និងចងក្រងឯកសារបណ្តុះបណ្តាល សំដៅធ្វើឱ្យមានបច្ចុប្បន្នភាពលើកម្មវិធីបណ្តុះបណ្តាលស្របតាមតម្រូវការនៃការបណ្តុះបណ្តាល និងអភិវឌ្ឍជំនាញស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ។

➢ **ស្តង់ដារទី២. កម្មវិធីបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ចមានខ្លឹមសារច្បាស់លាស់ និងស្របតាមស្តង់ដារជាតិ និងអាស៊ាន**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានកម្មវិធីបណ្តុះបណ្តាលច្បាស់លាស់ ដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍។ កម្មវិធីបណ្តុះបណ្តាលសម្រាប់វគ្គបណ្តុះបណ្តាលលើជំនាញទេសចរណ៍ ត្រូវរៀបចំចងក្រងឡើងដោយផ្អែកលើកម្មវិធីបណ្តុះបណ្តាលស្របតាមស្តង់ដារជាតិ និងអាស៊ាន។

➢ **ស្តង់ដារទី៣. មានឯកសារទ្រទ្រង់ការបណ្តុះបណ្តាលគ្រប់គ្រាន់រួមមានឯកសារសម្រាប់គ្រូ និងសិស្ស**

ដើម្បីអនុវត្តសកម្មភាពបណ្តុះបណ្តាល ស្របតាមកម្មវិធីបណ្តុះបណ្តាលសម្រាប់ជំនាញនីមួយៗឱ្យមានប្រសិទ្ធភាព ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវរៀបចំឯកសារសម្រាប់ទ្រទ្រង់ការបណ្តុះបណ្តាលផ្សេងៗ ក្នុងនោះរួមមានឯកសារសម្រាប់គ្រូ ឯកសារសម្រាប់សិស្ស និងឯកសារសម្រាប់វាយតម្លៃ និងត្រូវគិតគូរលើការរៀបចំឯកសារបណ្តុះបណ្តាលតាមប្រព័ន្ធអេឡិចត្រូនិចបន្ថែម ស្របតាមសភាពការណ៍ និងតម្រូវការជាក់ស្តែងរបស់ស្ថាប័នរបស់ខ្លួន។

➢ **ស្តង់ដារទី៤. មានយន្តការកំណត់ចំនួនសមត្ថភាព ឬចំនួនក្រេឌីតសិក្សា និងគោលការណ៍នៃការបន្ស៊ីនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ និងអាស៊ាន**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ចាំបាច់ត្រូវកំណត់យន្តការសិក្សាតាមឯកតាសមត្ថភាព ឬចំនួនក្រេឌីតសិក្សា តាមរយៈការរៀបចំ និងអភិវឌ្ឍកម្មវិធីសិក្សា ដែលអាចធ្វើការបន្ស៊ីនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ និងអាស៊ាន។

➢ **ស្តង់ដារទី៥. មានវិធីសាស្ត្រ និងឧបករណ៍វាយតម្លៃសមត្ថភាពរបស់សិក្ខាកាមច្បាស់លាស់ និងគ្រប់គ្រាន់**

រាល់វគ្គបណ្តុះបណ្តាល ដែលស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍រៀបចំឡើង ត្រូវមានការកំណត់វិធីសាស្ត្រ និងឧបករណ៍សម្រាប់បណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាពរបស់សិស្ស ឬសិក្ខាកាមឱ្យបានច្បាស់លាស់ និងគ្រប់គ្រាន់ ឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យតម្រូវតាមជំនាញ និងឯកតាសមត្ថភាពនីមួយៗ។

➢ **ស្តង់ដារទី៦. មានការត្រួតពិនិត្យ វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាល និងឯកសារបណ្តុះបណ្តាលយ៉ាងទៀងទាត់ស្របតាមតម្រូវការវិវត្តន៍របស់ជំនាញទេសចរណ៍កម្រិតជាតិ និងអាស៊ាន**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាព និងគុណភាពនៃការបណ្តុះបណ្តាលតាមកម្មវិធីបណ្តុះបណ្តាល និងត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំស្របតាមការវិវត្តន៍ថ្មីៗ នៃស្តង់ដារសមត្ថភាពអ្នកជំនាញទាំងកម្រិតថ្នាក់ជាតិ និងអាស៊ាន។

➢ **សូចនាករទី៧ មានធនធានសិក្សា (បណ្ណាល័យ កន្លែងអនុវត្តជំនាញ និងឯកសារសិក្សាផ្សេងៗ)**

បន្ថែមលើកម្មវិធី និងឯកសារបណ្តុះបណ្តាល ដែលរៀបចំឡើង ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវរៀបចំឱ្យមានធនធានទ្រទ្រង់ការសិក្សាផ្សេងៗ ទៀត រួមមានបណ្ណាល័យ បន្ទប់ពិសោធន៍ ឬកន្លែងអនុវត្តជំនាញ និងឯកសារគាំទ្រផ្សេងៗ ទៀតផងដែរ។

**ច. លក្ខណវិនិច្ឆ័យទី៦.** ***ការធានាឱ្យមានសាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល និងបុគ្គលិកជំនាញ ដែលមានសមត្ថភាពគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព***

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវរៀបចំឱ្យមានសាស្ត្រាចារ្យ ឬគ្រូឧទទ្ទេស ឬ គ្រូបង្គោល និង ឬ អ្នកវាយតម្លៃបង្គោលដែលមានសមត្ថភាព គុណវុឌ្ឍិ ជំនាញ និងចំណេះដឹងទាក់ទងទៅនឹងវិស័យទេសចរណ៍ និងជំនាញទេសចរណ៍ ជាពិសេសចំណេះដឹងលើកម្មវិធីបណ្តុះបណ្តាលស្របតាមស្តង់ដាជាតិ និងអាស៊ាន មានភាពគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន **០៦** ដែលស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមាន និងអនុវត្តតាមៈ

➢ **សូចនាករទី១ ចំណេះដឹង ជំនាញ គុណវុឌ្ឍិ និងបទពិសោធន៍របស់សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល ស្របទៅនឹងជំនាញ និងកម្រិតបណ្តុះបណ្តាល**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវធានាឱ្យបានថា សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលទាំងអស់ ត្រូវមានចំណេះដឹង ជំនាញ គុណវុឌ្ឍិ និងបទពិសោធន៍ ស្របទៅនឹងជំនាញ និងកម្រិតដែលត្រូវបណ្តុះបណ្តាល។

➢ **សូចនាករទី២ មានដំណើរការច្បាស់លាស់ និងតម្លាភាពក្នុងការជ្រើសរើស អភិវឌ្ឍ វាយតម្លៃ លើកទឹកចិត្ត និងរក្សាទុកសាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានរៀបចំឱ្យមានគោលនយោបាយ ឬគោលការណ៍ និងនីតិវិធីសម្រាប់ជ្រើសរើស អភិវឌ្ឍ វាយតម្លៃ លើកទឹកចិត្តដល់សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល ព្រមទាំងត្រូវមានលក្ខខណ្ឌការងារ និងកិច្ចសន្យាការងារច្បាស់លាស់។

➢ **សូចនាករទី៣ បរិមាណសាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលលើជំនាញទេសចរណ៍មានចំនួនគ្រប់គ្រាន់ធៀបទៅនឹងតម្រូវការបណ្តុះបណ្តាល**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវធានាឱ្យបានថារាល់វគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ នឹងមានចូលរួមផ្តល់ការបណ្តុះបណ្តាលពីសំណាក់សាស្ត្រាចារ្យ ឬ គ្រូឧទ្ទេស ឬគ្រូបង្គោល ឬ និងអ្នកវាយតម្លៃបង្គោល ដែលមានជំនាញពាក់ព័ន្ធទៅនឹងវគ្គបណ្តុះបណ្តាលជំនាញនោះ។

➢ **សូចនាករទី៤ សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលមានសមត្ថភាព និងចំណេះដឹងទាក់ទងនឹងនិន្នាការថ្មីៗនៃការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការអភិវឌ្ឍជំនាញទេសចរណ៍ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវលើកទឹកចិត្តឱ្យសាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិក្រឹតការ ឬសិក្ខាសាលាផ្សេងៗ ដែល

ក្រសួងទេសចរណ៍បានរៀបចំ ឱ្យបានម្តងក្នុងមួយឆ្នាំ សំដៅបង្កើនសមត្ថភាព និងចំណេះដឹងទាក់ទងនឹងនិន្នាការថ្មីៗ នៃការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការបណ្តុះបណ្តាល និងអភិវឌ្ឍជំនាញទេសចរណ៍ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ។

**➢ សូចនាករទី៥. គរុកោសល្យបណ្តុះបណ្តាលរបស់សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលលើជំនាញទេសចរណ៍**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវប្រាកដថា សាស្ត្រាចារ្យ ឬ គ្រូឧទ្ទេស ឬ គ្រូបង្គោល ឬ និងអ្នកវាយតម្លៃបង្គោល ដែលនឹងត្រូវជ្រើសរើសយកមកធ្វើការបណ្តុះបណ្តាលនៅក្នុងវគ្គបណ្តុះបណ្តាលនោះ មានគរុកោសល្យគ្រប់គ្រាន់ និងមានបទពិសោធន៍នៅក្នុងការបង្រៀនលើជំនាញនោះ ជាពិសេសមានចំណេះដឹងអំពីវិធីសាស្ត្រក្នុងការប្រើប្រាស់កម្មវិធីបណ្តុះបណ្តាលស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ។

**➢ សូចនាករទី៦. មានការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់បុគ្គលិកទាក់ទងនឹងនិន្នាការថ្មីៗ នៃការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការអភិវឌ្ឍជំនាញទេសចរណ៍ ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ**

បុគ្គលិកទាំងអស់ រាប់ទាំងអ្នកបម្រើការងារនៅក្នុងការិយាល័យរបស់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានចំណេះដឹងអំពីវិស័យទេសចរណ៍ និងទទួលបានការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពទាក់ទងនឹងនិន្នាការថ្មីៗ នៃការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការអភិវឌ្ឍជំនាញទេសចរណ៍ ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិតាមរយៈការចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗ ដែលរៀបចំឡើងដោយក្រសួងទេសចរណ៍។

**ឆ. លក្ខណវិនិច្ឆ័យទី៧.** ***ការដំណើរការវគ្គបណ្តុះបណ្តាលប្រកបដោយនិរន្តរភាព និងគុណភាព***

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវធានាឱ្យមានការរៀបចំវគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ប្រព្រឹត្តទៅប្រកបដោយភាពរលូន និរន្តរភាព ប្រសិទ្ធភាព និងគុណភាព។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន ០៣ ដែលស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

**➢ សូចនាករទី១. ការរៀបចំសម្ភារបរិក្ខារទ្រទ្រង់ដល់ដំណើរការបណ្តុះបណ្តាល**

ដើម្បីធ្វើឱ្យដំណើរការបណ្តុះបណ្តាលប្រកបដោយជោគជ័យ ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវគិតគូររៀបចំឱ្យមានសម្ភារបរិក្ខារសម្រាប់ទ្រទ្រង់ដល់ដំណើរការវគ្គ។ ការដំណើរការវគ្គបណ្តុះបណ្តាលមួយអាចប្រព្រឹត្តទៅបានល្អ លុះត្រាតែមានសម្ភារបរិក្ខារទ្រទ្រង់ដល់ដំណើរការបណ្តុះបណ្តាលគ្រប់គ្រាន់ និងឆ្លើយតបទៅនឹងជំនាញដែលយើងធ្វើការបណ្តុះបណ្តាល។

➢ **សូចនាករទី២. មានសមត្ថភាពរៀបចំដំណើរការវគ្គបណ្តុះបណ្តាលទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវប្រាកដថារាល់វគ្គបណ្តុះបណ្តាលដែលរៀបចំឡើងទាំងអស់ត្រូវដំណើរការបានល្អតាំងពីដើមរហូតដល់ចប់។ មុននឹងដំណើរការវគ្គបណ្តុះបណ្តាលនីមួយៗ ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ត្រូវពិនិត្យលទ្ធភាពហិរញ្ញវត្ថុ និងបច្ចេកទេសជាមុន។

➢ **សូចនាករទី៣. មានរៀបចំនីតិវិធី និងបទបញ្ជាផ្ទៃក្នុងច្បាស់លាស់សម្រាប់វគ្គបណ្តុះបណ្តាល**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវរៀបចំឱ្យមាននីតិវិធី និងបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រងដំណើរការវគ្គនីមួយៗ ឱ្យមានគុណភាព និងប្រសិទ្ធភាពខ្ពស់។

**ឃ. លក្ខណៈវិនិច្ឆ័យទី៤.** ***ការគ្រប់គ្រងវគ្គបណ្តុះបណ្តាលប្រកបដោយនិរន្តរភាព និងគុណភាព***

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានការតាមដាន ត្រួតពិនិត្យរាល់វគ្គបណ្តុះបណ្តាលដែលបានរៀបចំឡើង និងធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពក្នុងការរៀបចំវគ្គបណ្តុះបណ្តាល និងលទ្ធផលពីវគ្គបណ្តុះបណ្តាលទាំងនោះ សំដៅធ្វើការកែតម្រូវឱ្យវគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍កាន់តែមានគុណភាព និងប្រសិទ្ធភាព។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន ០៤ ដែលស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

➢ **សូចនាករទី១. មានការត្រួតពិនិត្យ និងតាមដានវគ្គបណ្តុះបណ្តាល**

រាល់វគ្គបណ្តុះបណ្តាលជំនាញទេសចរណ៍ ត្រូវមានការតាមដាន និងត្រួតពិនិត្យគុណភាព និងដំណើរការនៃវគ្គបណ្តុះបណ្តាល ដោយក្នុងនោះ រាល់ការបញ្ចប់វគ្គត្រូវមានការរៀបចំឱ្យមានការវាយតម្លៃដំណើរការវគ្គបណ្តុះបណ្តាលទាំងមូលរាប់ទាំងការវាយតម្លៃលើសិក្ខាកាម និងគុណភាពបណ្តុះបណ្តាលរបស់សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលផងដែរ។

➢ **សូចនាករទី២. ការធ្វើបច្ចុប្បន្នកម្មវគ្គបណ្តុះបណ្តាល**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ អាចរៀបចំវគ្គបណ្តុះបណ្តាលជំនាញចាំបាច់ថ្មីៗសម្រាប់បម្រើដល់សកម្មភាពផ្តល់សេវាកម្មភ្ញៀវទេសចរ។ រាល់ការបណ្តុះបណ្តាលជំនាញថ្មីចាំបាច់ ត្រូវធ្វើការជម្រាបជូនមកក្រសួងទេសចរណ៍ ដើម្បីទទួលបានការទទួលស្គាល់លើកម្មវិធីបណ្តុះបណ្តាលលើជំនាញថ្មីនោះ។

➢ **សូចនាករទី៣. មានការវាយតម្លៃគុណភាព និងលទ្ធផលនៃវគ្គបណ្តុះបណ្តាល**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវធ្វើការវាយតម្លៃគុណភាព និងលទ្ធផលនៃវគ្គបណ្តុះបណ្តាលនីមួយៗដែលបានរៀបចំឡើងដើម្បីប្រាកដថា វគ្គបណ្តុះបណ្តាលនោះធ្វើឡើងចំគោលដៅ និងផ្តល់ចំណេះដឹង និងជំនាញយ៉ាងពិតប្រាកដដល់សិក្ខាកាម ជាពិសេសដើម្បីរកឱ្យឃើញនូវចំណុចខ្វះខាតទាំងឡាយណា ដែលមាននៅក្នុងការអនុវត្តដំណើរការរៀបចំវគ្គបណ្តុះបណ្តាលនីមួយៗ។

➢ **សូចនាករទី៤. មានរៀបចំរបាយការណ៍អំពីវគ្គបណ្តុះបណ្តាលបញ្ជូនមកក្រសួងទេសចរណ៍**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានការរៀបចំបូកសរុបរបាយការណ៍នៃវគ្គបណ្តុះបណ្តាលនីមួយៗ រួចផ្ញើជូនមកក្រសួងទេសចរណ៍ និងត្រូវបញ្ចូលទិន្នន័យអំពីវគ្គបណ្តុះបណ្តាលដែល

ស្ថាប័នរបស់ខ្លួនបានបើក ទៅក្នុងប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍របស់ក្រសួងទេសចរណ៍ ដែលមានអាសយដ្ឋានគេហទំព័រ www.tptd.org ដើម្បីធ្វើការបូកសរុប និងតាមដានសកម្មភាពអនុវត្តលើការបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច របស់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍នីមួយៗ។

**ឈ. លក្ខណៈវិនិច្ឆ័យទី៩.** ***សមត្ថភាពធនធានហិរញ្ញវត្ថុ និងការឧបត្ថម្ភធនសម្រាប់ទ្រទ្រង់ការបណ្តុះបណ្តាល***

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានការគិតគូររៀបចំឱ្យមានធនធានហិរញ្ញវត្ថុ និងការឧបត្ថម្ភធនសម្រាប់ទ្រទ្រង់ការបណ្តុះបណ្តាលក្នុងការជួយសម្រួលដល់យុវជន សិស្ស និស្សិត និងអ្នកជំនាញទេសចរណ៍ដើម្បីទទួលបានការបណ្តុះបណ្តាលជំនាញទេសចរណ៍។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន **០៥** ដែលស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមាន និងអនុវត្តតាមៈ

➢ **សូចនាករទី១ មានផ្តល់ជូនការបណ្តុះបណ្តាលក្នុងតម្លៃសិក្សាទាប**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានការផ្តល់ការបណ្តុះបណ្តាលនៅក្នុងតម្លៃសិក្សាទាប ដែលអាចជួយសម្រួលដល់យុវជន សិស្ស និស្សិត និងអ្នកជំនាញទេសចរណ៍គ្រប់រូបអាចមានលទ្ធភាពចូលរួមក្នុងវគ្គបណ្តុះបណ្តាលបាន។

➢ **សូចនាករទី២. មានផ្តល់ជូនការបណ្តុះបណ្តាលដោយមិនគិតថ្លៃ**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវបានលើកទឹកចិត្តឱ្យមានផ្តល់ជូនការបណ្តុះបណ្តាលដោយមិនគិតថ្លៃដល់យុវជន សិស្ស និស្សិត និងអ្នកជំនាញទេសចរណ៍។ ការបណ្តុះបណ្តាលដោយមិនគិតថ្លៃនេះ អាចត្រូវបានធ្វើឡើងក្រោមទម្រង់នៃការសហការរវាងស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍នោះ ជាមួយក្រសួងទេសចរណ៍ និងភាគីពាក់ព័ន្ធផ្សេងៗទៀត។

➢ **សូចនាករទី៣. មានផ្តល់ជូនកម្ចីសិក្សាដល់សិក្ខាកាម**

បន្ថែមលើការផ្តល់ការបណ្តុះបណ្តាលក្នុងតម្លៃទាប និងមិនគិតថ្លៃ ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ អាចរៀបចំឱ្យមានគម្រោងផ្តល់កម្ចីសិក្សាដល់សិស្ស និស្សិតសម្រាប់ទ្រទ្រង់ដល់ការសិក្សាលើជំនាញទេសចរណ៍។

➢ **សូចនាករទី៤. មានកញ្ចប់ថវិកាសមស្របសម្រាប់គាំទ្រការអភិវឌ្ឍជំនាញដល់សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល និងបុគ្គលិកជំនាញ**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវគិតគូររៀបចំឱ្យមានកញ្ចប់ថវិកាមួយផ្នែកសម្រាប់គាំទ្រដល់ការពង្រឹងសមត្ថភាពដល់សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល ព្រមទាំងបុគ្គលិកជំនាញនៅក្នុងស្ថាប័នផងដែរ។

➢ **សូចនាករទី៥. មានកញ្ចប់ថវិកាសមស្របសម្រាប់គាំទ្រដល់ការសិក្សាស្រាវជ្រាវអភិវឌ្ឍជំនាញទេសចរណ៍**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ក៏ត្រូវគិតគូរលើជំរុញការសិក្សាស្រាវជ្រាវក្នុងការអភិវឌ្ឍជំនាញថ្មីៗ តាមរយៈរៀបចំឱ្យមានកញ្ចប់ថវិកាមួយផ្នែកសម្រាប់គាំទ្រដល់ការសិក្សាស្រាវជ្រាវផ្សេងៗ ដែលឈានទៅដល់ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពដល់សាស្ត្រាចារ្យ គ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល ព្រមទាំងបុគ្គលិកជំនាញ។

**ញ. លក្ខណៈវិនិច្ឆ័យទី១០. *ការគិតគូរអំពីការស្វែងរកឱកាសការងារ និងកម្មសិក្សាការងារ និងការផ្តល់សេវាដល់សិក្ខាកាម***

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានការជួយតម្រង់ទិសការសិក្សា និងការងារដល់សិស្ស និងសិក្ខាកាម និងត្រូវមានការសហការជាមួយដៃគូ និងភាគីពាក់ព័ន្ធដើម្បីស្វែងរកឱកាសការងារ និងកម្មសិក្សាការងារដល់សិស្ស និងសិក្ខាកាម ដើម្បីអភិវឌ្ឍជំនាញទាំងពេលកំពុងសិក្សា និងពេលបញ្ចប់ការសិក្សា។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន **០៥** ដែលស្ថាប័នផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមាន និងអនុវត្តតាមៈ

➢ **សូចនាករទី១. មានការណែនាំការងារសម្រាប់សិក្ខាកាមបន្ទាប់ពីបញ្ចប់វគ្គ**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ អាចប្រើប្រាស់បណ្តាញរបស់ខ្លួនជួយណែនាំ និងតម្រង់ទិសការងារដល់សិស្ស និងសិក្ខាកាមបន្ទាប់ពីបញ្ចប់ការសិក្សា។

➢ **សូចនាករទី២. មានរៀបចំកម្មសិក្សាការងារដល់សិក្ខាកាម**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ អាចប្រើប្រាស់បណ្តាញរបស់ខ្លួនដើម្បីផ្តល់ឱកាសដល់សិក្ខាកាមទទួលបានឱកាសចុះកម្មសិក្សាការងារអនុវត្តនៅតាមកន្លែងការងារជាក់ស្តែង។ ការចុះកម្មសិក្សាការងារជាក់ស្តែង នឹងឆ្លុះបញ្ចាំងឱ្យឃើញកាន់តែច្បាស់អំពីការយកចិត្តទុកដាក់លើការពង្រឹងគុណភាពបណ្តុះបណ្តាល ជាពិសេសការអភិវឌ្ឍសមត្ថភាពជំនាញរបស់យុវជន សិស្ស និស្សិត និងសិក្ខាកាមដែលទទួលបានការបណ្តុះបណ្តាល របស់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍នោះ។

➢ **សូចនាករទី៣. មានគោលនយោបាយ និងគោលការណ៍ស្តីពីការផ្តល់អាហារូបករណ៍**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានគោលនយោបាយ និងគោលការណ៍គិតគូរលើការផ្តល់អាហារូបករណ៍ ដល់យុវជន សិស្ស និស្សិត និងសាធារណជន ដើម្បីទទួលបានឱកាសបន្តសិក្សាលើជំនាញទេសចរណ៍។ ការផ្តល់អាហារូបករណ៍ អាចត្រូវបានធ្វើឡើងក្រោមទម្រង់ជាការផ្តល់អាហារូបករណ៍ផ្ទាល់របស់សាលា ឬអាហារូបករណ៍ ដែលផ្តល់ក្រោមទម្រង់កិច្ចសហការ ឬគាំទ្រពីដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ។

➢ **សូចនាករទី៤. មានការណែនាំ និងតម្រង់ទិសការសិក្សា និងការងារដល់សិក្ខាកាម**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានអង្គភាព ឬផ្នែកសម្របសម្រួល និងតម្រង់ទិសការសិក្សា និងឱកាសការងារដល់សិស្ស និងសិក្ខាកាមរបស់ខ្លួន។

**➢ សូចនាករទី៥.មានគោលនយោបាយ ឬគោលការណ៍ និងនីតិវិធីច្បាស់លាស់ក្នុងការដោះស្រាយរាល់បណ្តឹងតវ៉ាផ្សេងៗ របស់សិក្ខាកាម**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានយន្តការ គោលនយោបាយ ឬគោលការណ៍ និងនីតិវិធីសម្រាប់ដោះស្រាយ និងសម្របសម្រួលបញ្ហាផ្សេងៗ ដែលកើតចេញពីបណ្តឹងតវ៉ារបស់សិស្ស និងសិក្ខាកាមប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។

**ង. លក្ខណវិនិច្ឆ័យទី១១.** ***ការធានាគុណភាពផ្ទៃក្នុង***

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ក្នុងការធានា និងបន្តលើកកម្ពស់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ តាមរយៈការវាយតម្លៃជាប្រព័ន្ធលើប្រសិទ្ធភាពនៃប្រតិបត្តិការ និងកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន ០២ ដែលស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

**➢ សូចនាករទី១ មានប្រព័ន្ធធានាគុណភាពផ្ទៃក្នុងច្បាស់លាស់**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវមានគោលការណ៍ និងនីតិវិធីសម្រាប់អនុវត្តការធានាគុណភាពផ្ទៃក្នុងច្បាស់លាស់។

**➢ សូចនាករទី២. មានការចូលរួម និងគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធខាងក្នុងស្ថាប័នលើដំណើរការធានាគុណភាពបណ្តុះបណ្តាល**

ដើម្បីធានាគុណភាពផ្ទៃក្នុង ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ទាំងអស់ ត្រូវអនុវត្តយកការទទួលមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធដើម្បីកែលម្អគុណភាព និងកម្មវិធីបណ្តុះបណ្តាល។

***ដើម្បីទទួលបានការទទួលស្គាល់គុណភាពបណ្តុះបណ្តាលទៅតាមកម្រិត ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ទាំងអស់ត្រូវបំពេញគ្រប់លក្ខណវិនិច្ឆ័យទាំង ១១ ពោលគឺ៖***

*១. ទទួលបានពិន្ទុចន្លោះ ១០០-៩០ នៃពិន្ទុសរុប ដើម្បីក្លាយជាស្ថាប័នបណ្តុះបណ្តាលកម្រិតល្អណាស់*

*២. ទទួលបានពិន្ទុចន្លោះ ៨៩-៨០ នៃពិន្ទុសរុប ដើម្បីក្លាយជាស្ថាប័នបណ្តុះបណ្តាលកម្រិតល្អ*

*៣. ទទួលបានពិន្ទុចន្លោះ ៧៩-៧០ នៃពិន្ទុសរុប ដើម្បីក្លាយជាស្ថាប័នបណ្តុះបណ្តាលកម្រិតល្អបង្គួរ*

*៤. ទទួលបានពិន្ទុចន្លោះ ៦៩-៦០ នៃពិន្ទុសរុប ដើម្បីក្លាយជាស្ថាប័នបណ្តុះបណ្តាលកម្រិតមធ្យម*

*៥. ទទួលបានពិន្ទុចន្លោះ ៥៩-៥០ នៃពិន្ទុសរុប ដើម្បីក្លាយជាស្ថាប័នបណ្តុះបណ្តាលកម្រិតខ្សោយ*

សម្គាល់៖

- ការវាយតម្លៃ និងផ្តល់ពិន្ទុ ត្រូវធ្វើឡើងផ្អែកលើតារាងរបាយការណ៍វាយតម្លៃ ដែលមាននៅក្នុងឧបសម្ព័ន្ធ។
- ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលទទួលបានពិន្ទុក្រោម ៥០ នឹងមិនអាចទទួលស្គាល់ជាស្ថាប័នដែលមានសមត្ថភាពក្នុងការផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ និងជំនាញដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍បានឡើយ។

• **ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលទទួលបានការបញ្ជាក់ការទទួលស្គាល់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ និងជំនាញដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ ពីក្រសួងទេសចរណ៍ តាមរយៈនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ អាចធ្វើការបណ្តុះបណ្តាលជំនាញទេសចរណ៍ និងជំនាញដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ ដោយពុំចាំបាច់ធ្វើការស្នើសុំការទទួលស្គាល់លើវគ្គបណ្តុះបណ្តាលនោះទេ។**

**៦.៣. ដំណើរការវាយតម្លៃ និងបញ្ជាក់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍សម្រាប់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍**

ដំណើរការវាយតម្លៃ និងបញ្ជាក់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ នឹងត្រូវធ្វើឡើងតាមដំណាក់កាលដូចខាងក្រោម៖

- ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ត្រូវធ្វើស្វ័យវាយតម្លៃ និងរៀបចំរបាយការណ៍ដោយផ្អែកលើស្តង់ដាបញ្ជាក់ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាលខាងលើ។ ផ្អែកលើសូចនាករ និងលក្ខណវិនិច្ឆ័យនៃស្តង់ដាបញ្ជាក់ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាល ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ អាចមានលទ្ធភាពកែលម្អចំណុចខ្វះខាត ឱ្យមានលក្ខណៈល្អប្រសើរ ដើម្បីក្លាយជាស្ថាប័ន ដែលផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់។
- ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ត្រូវដាក់ពាក្យស្នើសុំការបញ្ជាក់ និងទទួលគុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ មកក្រសួងទេសចរណ៍ ដោយមានភ្ជាប់មកជាមួយនូវរបាយការណ៍ស្វ័យវាយតម្លៃ និងឯកសារគាំទ្រចាំបាច់ដែលពាក់ព័ន្ធ។
- នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ នឹងចាត់មន្ត្រីជំនាញឱ្យពិនិត្យបឋមលើរបាយការណ៍ស្វ័យវាយតម្លៃ និងឯកសារគាំទ្រចាំបាច់ដែលពាក់ព័ន្ធទាំងនោះ និងផ្តល់ការណែនាំបន្ថែមដល់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ដែលបានដាក់ពាក្យស្នើសុំ ក្នុងករណីពិនិត្យឃើញថា នៅមានភាពខ្វះខាតលើចំណុចណាមួយនៃរបាយការណ៍ស្វ័យវាយតម្លៃ និងឯកសារភ្ជាប់ទាំងនោះ។
- បន្ទាប់ពីការវាយតម្លៃបឋមលើរបាយការណ៍ស្វ័យវាយតម្លៃ និងឯកសារគាំទ្រ ដែលស្ថាប័នបញ្ជូនមកនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ នឹងចាត់មន្ត្រីជំនាញចុះពិនិត្យ និងវាយតម្លៃផ្ទាល់នៅស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ដែលស្នើសុំ ដោយជូនដំណឹងដល់ស្ថាប័នស្នើសុំមុនមិនលើសពី **៣០ ថ្ងៃ** បន្ទាប់ពីការវាយតម្លៃបឋមត្រូវបានបញ្ចប់។
- បន្ទាប់ពីការចុះវាយតម្លៃផ្ទាល់ មន្ត្រីជំនាញនៃនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ នឹងធ្វើការបូកសរុបលទ្ធផលនៃការចុះវាយតម្លៃ និងបង្ហាញជូនដល់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ដែលបានស្នើសុំ។
- ក្រសួងទេសចរណ៍ នឹងរៀបចំវិញ្ញាបនបត្របញ្ជាក់ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាលដល់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលបានបំពេញតាមពិន្ទុនៅក្នុងស្តង់ដាទទួលស្គាល់គុណភាពបណ្តុះបណ្តាលខាងលើ។

**៦.៤ វិញ្ញាបនបត្របញ្ជាក់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍សម្រាប់ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍**

ស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលបានបញ្ជាក់ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាលពីក្រសួងទេសចរណ៍ នឹងទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលមានគំរូនៅក្នុងឧបសម្ព័ន្ធ។

VII. **ការវាយតម្លៃ និងទទួលស្គាល់គុណភាពវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍**

**៧.១. ការបញ្ជាក់ និងទទួលស្គាល់ការវាយតម្លៃជំនាញទេសចរណ៍របស់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព**

ដើម្បីបញ្ជាក់សមត្ថភាពលើជំនាញទេសចរណ៍ ជាពិសេស សម្រាប់បម្រើការងារនៅក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ អ្នកជំនាញទេសចរណ៍ យុវជន សិស្ស និស្សិត និងសាធារណជន អាចស្នើសុំការវាយតម្លៃ និងបញ្ជាក់សមត្ថភាព នៅនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៃក្រសួងទេសចរណ៍ ឬ អាចស្វែងរកមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍ ដើម្បីធ្វើការវាយតម្លៃ និងបញ្ជាក់សមត្ថភាពលើជំនាញទេសចរណ៍។

ការវាយតម្លៃសមត្ថភាពសម្រាប់អ្នកជំនាញទេសចរណ៍ មូលដ្ឋានអាជីវកម្មទេសចរណ៍ ក៏អាចស្នើសុំវាយតម្លៃ និងបញ្ជាក់សមត្ថភាពដល់បុគ្គលិកបម្រើការងារក្នុងមូលដ្ឋានអាជីវកម្មទេសចរណ៍របស់ខ្លួនផងដែរ។ ការវាយតម្លៃសមត្ថភាព អាចនឹងធ្វើឡើងនៅនឹងកន្លែង ដែលរួមមាននៅនឹងមូលដ្ឋានអាជីវកម្មផ្ទាល់ ឬនៅមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព និងតាមប្រព័ន្ធអនឡាញ អាស្រ័យលើឯកតាសមត្ថភាព និងជំនាញនីមួយៗ។

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ មានកាតព្វកិច្ចស្នើសុំការវាយតម្លៃ បញ្ជាក់គុណភាព និងទទួលស្គាល់ពីក្រសួងទេសចរណ៍ តាមរយៈនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ មុននឹងមានសិទ្ធិ និងទទួលស្គាល់ជាស្ថាប័នផ្តល់សេវាវាយតម្លៃសមត្ថភាពលើជំនាញនៃវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ។

**៧.២. លក្ខណវិនិច្ឆ័យវាយតម្លៃ និងទទួលស្គាល់គុណភាពវាយតម្លៃរបស់មជ្ឈមណ្ឌលវាយតម្លៃ សមត្ថភាព**

ដើម្បីទទួលបានការទទួលស្គាល់លើគុណភាពវាយតម្លៃលើជំនាញទេសចរណ៍ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ត្រូវបំពេញតាមស្តង់ដានៃការទទួលស្គាល់គុណភាពវាយតម្លៃជំនាញទេសចរណ៍ ដែលមានលក្ខណវិនិច្ឆ័យចំនួន **១០** និងសូចនាករចំនួន **៣៥** ដូចមានក្នុងតារាងខាងក្រោម៖

ការទទួលស្គាល់គុណភាពការវាយតម្លៃរបស់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព

| លក្ខណៈវិនិច្ឆ័យ/សូចនាករ | ការផ្ទៀងផ្ទាត់ | ពិន្ទុ |
|---|---|---|
| ការទទួលស្គាល់គុណភាពវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ នឹងធានាដល់ការអភិវឌ្ឍសមត្ថភាព ជំនាញ និងគុណវុឌ្ឍិរបស់អ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរឱ្យឆ្លើយតប ទៅនឹងស្តង់ដារជាតិ និងអាស៊ាន ដែលចូលរួមជំរុញការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ សំដៅសម្រេចការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយគុណភាព បរិយាប័ន្ន និងការទទួលខុសត្រូវ។ | | |
| ***១.ចក្ខុវិស័យ បេសកកម្ម និងគោលដៅ*** | | |
| ១.១.ចក្ខុវិស័យ បេសកកម្ម និងគោលដៅ ឆ្លើយតបទៅនឹងគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងឆ្លើយតបទៅនឹងតម្រូវការថ្នាក់ជាតិ តំបន់ និងអន្តរជាតិ | មាន-មិនមាន | ០៣ |
| ១.២.ការជំរុញអនុវត្តដោយប្រកាន់ខ្ជាប់តាមចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់ស្ថាប័ន | មាន-មិនមាន | ០៣ |
| ***២.អភិបាលកិច្ច និងការគ្រប់គ្រង*** | | |
| ២.១.មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ | មាន-មិនមាន | ០៣ |
| ២.២. ភាពទៀងទាត់នៃការវាយតម្លៃប្រសិទ្ធភាពការងារអភិបាលកិច្ច និងការគ្រប់គ្រង | មាន-មិនមាន | ០៣ |
| ***៣. ធនធានរូបវន្ត*** | | |
| ៣.១. មានការចុះបញ្ជី និងទទួលស្គាល់ការវាយតម្លៃពីក្រសួងទេសចរណ៍ | មាន-មិនមាន | ០៣ |
| ៣.២. មានធនធានរូបវន្តគ្រប់គ្រាន់ | មាន-មិនមាន | ០៣ |
| ៣.៣. មានការគិតគូរពីការរក្សាបរិស្ថានជុំវិញ ផាសុកភាព និងសុវត្ថិភាព | មាន-មិនមាន | ០៣ |
| ៣.៤. មានបុគ្គលិកបម្រើការគ្រប់គ្រាន់ | មាន-មិនមាន | ០៣ |
| ៣.៥. អភិវឌ្ឍរូបវន្តទ្រទ្រង់ការវាយតម្លៃតាមប្រព័ន្ធអនឡាញ | មាន-មិនមាន | ០៣ |
| ៣.៦. មានផែនការអភិវឌ្ឍន៍ធនធានរូបវន្តច្បាស់លាស់ | មាន-មិនមាន | ០៣ |
| ***៤ ការរៀបចំ និងអនុវត្តផែនការវាយតម្លៃជំនាញទេសចរណ៍*** | | |
| ៤.១. មានការរៀបចំផែនការវាយតម្លៃជំនាញទេសចរណ៍ប្រចាំឆ្នាំ | មាន-មិនមាន | ០៣ |
| ៤.២. ការសម្រេចបានតាមផែនការវាយតម្លៃជំនាញទេសចរណ៍ | មាន-មិនមាន | ០៣ |
| ៤.៣. មានផែនការសហការជាមួយក្រសួងទេសចរណ៍ និងភាគីពាក់ព័ន្ធ | មាន-មិនមាន | ០៣ |

| | | | |
|---|---|---|---|
| | ជំរុញការវាយតម្លៃជំនាញទេសចរណ៍ | | |
| | ***៥. ឯកសារវាយតម្លៃ និងឧបករណ៍វាយតម្លៃ*** | | |
| | ៥.១.មានក្រុមការងារ ឬគណៈកម្មការអភិវឌ្ឍន៍ និងចងក្រងឯកសារវាយតម្លៃ | មាន-មិនមាន | ០៣ |
| | ៥.២. ឯកសារវាយតម្លៃមានខ្លឹមសារច្បាស់លាស់ និងស្របតាមស្តង់ដាជាតិ និងអាស៊ាន | មាន-មិនមាន | ០៣ |
| | ៥.៣. មានវិធីសាស្ត្រ និងឧបករណ៍វាយតម្លៃសមត្ថភាពរបស់សិក្ខាកាមច្បាស់លាស់ និងគ្រប់គ្រាន់ | មាន-មិនមាន | ០៣ |
| | ៥.៤. មានការត្រួតពិនិត្យ វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពឯកសារវាយតម្លៃយ៉ាងទៀងទាត់ | មាន-មិនមាន | ០៣ |
| | ***៦. ការធានាឱ្យមានអ្នកវាយតម្លៃបង្គោល និងបុគ្គលិកជំនាញដែលមានសមត្ថភាពគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព*** | | |
| | ៦.១.ចំណេះដឹង ជំនាញ គុណវុឌ្ឍិ និងបទពិសោធន៍របស់អ្នកវាយតម្លៃបង្គោល ស្របទៅនឹងជំនាញ និងកម្រិតវាយតម្លៃ | មាន-មិនមាន | ០៣ |
| | ៦.២.មានដំណើការច្បាស់លាស់ និងតម្លាភាពក្នុងការជ្រើសរើស អភិវឌ្ឍវាយតម្លៃ លើកទឹកចិត្ត និងរក្សាទុកអ្នកវាយតម្លៃបង្គោល | មាន-មិនមាន | ០៣ |
| | ៦.៣.បរិមាណអ្នកវាយតម្លៃបង្គោលលើជំនាញទេសរណ៍ មានចំនួនគ្រប់គ្រាន់ដោយធៀបទៅនឹងតម្រូវការវាយតម្លៃ | មាន-មិនមាន | ០៣ |
| | ៦.៤. អ្នកវាយតម្លៃបង្គោល មានសមត្ថភាព និងចំណេះដឹងទាក់ទងនឹងនិន្នាការថ្មីៗ នៃការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការអភិវឌ្ឍជំនាញទេសចរណ៍ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ | មាន-មិនមាន | ០៣ |
| | ៦.៥.គរុកោសល្យវាយតម្លៃរបស់ អ្នកវាយតម្លៃបង្គោលលើជំនាញទេសចរណ៍ | មាន-មិនមាន | ០៣ |
| | ៦.៦.មានការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់បុគ្គលិកទាក់ទងនឹងនិន្នាការថ្មីៗនៃការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការអភិវឌ្ឍជំនាញទេសចរណ៍ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ | មាន-មិនមាន | ០៣ |
| | ***៧. ការដំណើរការវាយតម្លៃប្រកបដោយនិរន្តរភាព និងគុណភាព*** | | |
| | ៧.១. ការរៀបចំសម្ភារបរិក្ខារទ្រទ្រង់ដល់ដំណើរការវាយតម្លៃ | មាន-មិនមាន | ០៣ |
| | ៧.២. មានសមត្ថភាពរៀបចំដំណើរការវាយតម្លៃទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស | មាន-មិនមាន | ០៣ |

| | | | |
|---|---|---|---|
| | ៧.៣. មានរៀបចំនីតិវិធី និងបទបញ្ជាផ្ទៃក្នុងច្បាស់លាស់សម្រាប់វាយតម្លៃ | មាន-មិនមាន | ០៣ |
| | *៨. ការគ្រប់គ្រងការវាយតម្លៃប្រកបដោយនិរន្តរភាព និងគុណភាព* | | |
| | ៨.១.មានការត្រួតពិនិត្យ និងតាមដានការវាយតម្លៃ | មាន-មិនមាន | ០៣ |
| | ៨.២. ការធ្វើបច្ចុប្បន្នកម្មការវាយតម្លៃ | មាន-មិនមាន | ០៣ |
| | ៨.៣. មានការវាយតម្លៃគុណភាព និងលទ្ធផលនៃការវាយតម្លៃ | មាន-មិនមាន | ០៣ |
| | ៨.៤. មានរៀបចំរបាយការណ៍អំពីការវាយតម្លៃបញ្ជូនមកក្រសួងទេសចរណ៍ | មាន-មិនមាន | ០៣ |
| | *៩. សមត្ថភាពធនធានហិរញ្ញវត្ថុ និងការឧបត្ថម្ភធនសម្រាប់ទ្រទ្រង់ការវាយតម្លៃ* | | |
| | ៩.១. មានផ្តល់ជូនសេវាវាយតម្លៃក្នុងតម្លៃទាប | មាន-មិនមាន | ០២ |
| | ៩.២. មានផ្តល់ជូនការវាយតម្លៃដោយមិនគិតថ្លៃ | មាន-មិនមាន | ០២ |
| | ៩.៣.មានកញ្ចប់ថវិកាសមស្របសម្រាប់គាំទ្រការអភិវឌ្ឍជំនាញដល់អ្នកវាយតម្លៃបង្គោល និងបុគ្គលិកជំនាញ | មាន-មិនមាន | ០២ |
| | *១០. ការធានាគុណភាពផ្ទៃក្នុង* | | |
| | ១០.១.មានប្រព័ន្ធធានាគុណភាពផ្ទៃក្នុងច្បាស់លាស់ | មាន-មិនមាន | ០២ |
| | ១០.២.មានការចូលរួម និងគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធខាងក្នុងស្ថាប័នលើដំណើរការធានាគុណភាពវាយតម្លៃ | មាន-មិនមាន | ០២ |
| **លក្ខណវិនិច្ឆ័យសរុប ១០ និងសូចនាករសរុប ៣៥ ស្មើនឹង ១០០ ពិន្ទុ** | | | |

### សេចក្តីអត្ថាធិប្បាយពីលក្ខណវិនិច្ឆ័យ និងសូចនាករ

ដើម្បីទទួលបានការបញ្ជាក់ និងទទួលស្គាល់គុណភាពវាយតម្លៃ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងរដ្ឋ និងឯកជនទាំងអស់ ត្រូវអនុវត្តតាមលក្ខណវិនិច្ឆ័យ និងសូចនាករនៃស្តង់ដាទទួលស្គាល់គុណភាពវាយតម្លៃជំនាញនៃវិស័យទេសចរណ៍ បរិសណ្ឋារកិច្ច និងការធ្វើដំណើរ ដែលមានដូចខាងក្រោម៖

**ក. លក្ខណវិនិច្ឆ័យទី១. *ចក្ខុវិស័យ បេសកកម្ម និងគោលដៅ***

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវកំណត់ចក្ខុវិស័យ បេសកកម្ម និងគោលដៅឱ្យបានច្បាស់លាស់ និងត្រូវផ្សារភ្ជាប់ទៅនឹងតម្រូវការរបស់ជាតិ តំបន់ និងអន្តរជាតិ ជាពិសេសចូលរួមសម្រេចនូវគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍នៅកម្ពុជា។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន ០២ ដែលមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

➢ **ស្តូចនាករទី១. ចក្ខុវិស័យ បេសកកម្ម និងគោលដៅ ឆ្លើយតបទៅនឹងគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងឆ្លើយតបទៅនឹងតម្រូវការថ្នាក់ជាតិ តំបន់ និងអន្តរជាតិ**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ត្រូវបង្ហាញចក្ខុវិស័យ បេសកកម្ម និងគោលដៅ ក្នុងការចូលរួមលើកកម្ពស់ការអភិវឌ្ឍជំនាញទេសចរណ៍ ឱ្យឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជំនាញ និងធនធានមនុស្សទាំងក្នុងកម្រិតថ្នាក់ជាតិ អាស៊ាន តំបន់ និងអន្តរជាតិ។

➢ **ស្តូចនាករទី២. ការជំរុញអនុវត្តដោយប្រកាន់ខ្ជាប់តាមចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់ស្ថាប័ន**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ត្រូវជំរុញ និងសហការអនុវត្តការងារដោយប្រកាន់ខ្ជាប់តាមចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលស្ថាប័នបានកំណត់ និងត្រូវតាមដាន ព្រមទាំងកែតម្រូវការអនុវត្តការងារឱ្យបានត្រឹមត្រូវយ៉ាងទៀងទាត់។

**ខ. លក្ខណៈវិនិច្ឆ័យទី២.** ***អភិបាលកិច្ច និងការគ្រប់គ្រង***

ការគ្រប់គ្រង និងអភិបាលកិច្ចល្អ នឹងជួយឱ្យមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ទទួលបានជោគជ័យក្នុងការសម្រេចចក្ខុវិស័យ បេសកកម្ម និងគោលដៅប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ដូច្នេះ យើងបានកំណត់យកស្តូចនាករចំនួន **០២** ដែលមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

➢ **ស្តូចនាករទី១. រចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់**

ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងបានល្អ នឹងជួយដល់ការកំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អង្គភាពនីមួយៗ រួមទាំងក្រុមប្រឹក្សាភិបាល គណៈកម្មការ និងគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ ក្នុងការសម្រេចតាមផែនការរបស់មជ្ឈមណ្ឌល។

➢ **ស្តូចនាករទី២. ភាពទៀងទាត់នៃការវាយតម្លៃប្រសិទ្ធភាពការងារអភិបាលកិច្ច និងការគ្រប់គ្រង**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពការងារគ្រប់គ្រង និងអភិបាលកិច្ចឱ្យបានទៀងទាត់។ ការវាយតម្លៃអាចត្រូវបានធ្វើឡើងជាត្រីមាស ឆមាស និងប្រចាំឆ្នាំ និងត្រូវមានកំណត់ហេតុ ឬរបាយការណ៍វាយតម្លៃការងារ។

**គ. លក្ខណៈវិនិច្ឆ័យទី៣.** ***ធនធានរូបវន្ត***

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលអាចធ្វើការវាយតម្លៃសមត្ថភាពលើជំនាញនៃវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ត្រូវសុំការទទួលស្គាល់លើការវាយតម្លៃជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍ ព្រមទាំងត្រូវរៀបចំធនធានរូបវន្តឱ្យមានភាពគ្រប់គ្រាន់សម្រាប់ធ្វើការវាយតម្លៃលើជំនាញនេះ។ ដូច្នេះ យើងបានកំណត់យកស្តូចនាករចំនួន **០៦** ដែលមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

➢ **សូចនាករទី១. មានការចុះបញ្ជី និងទទួលស្គាល់ការវាយតម្លៃពីក្រសួងទេសចរណ៍**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវធ្វើការចុះបញ្ជី និងស្នើសុំទទួលស្គាល់លើការវាយតម្លៃជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍។ ដើម្បីធានាបាននូវគុណភាពវាយតម្លៃ ការចុះបញ្ជី និងការស្នើសុំទទួលស្គាល់គុណភាពវាយតម្លៃជាលក្ខខណ្ឌតម្រូវចាំបាច់ ដែលមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវអនុវត្ត។

➢ **សូចនាករទី២. មានធនធានរូបវ័ន្តគ្រប់គ្រាន់**

ដើម្បីបំពេញលក្ខខណ្ឌទទួលស្គាល់លើការវាយតម្លៃជំនាញទេសចរណ៍ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវរៀបចំសម្បទាទ្រទ្រង់ការវាយតម្លៃឱ្យបានគ្រប់គ្រាន់ ជាពិសេស ទីកន្លែងវាយតម្លៃ បន្ទប់ សម្រាប់ធ្វើការវាយតម្លៃ បន្ទប់អនុវត្ត ការផ្គត់ផ្គង់អគ្គិសនី និងទឹកគ្រប់គ្រាន់។ ទីកន្លែង និងបន្ទប់សម្រាប់ធ្វើការវាយតម្លៃ ត្រូវមានការរៀបចំមានលក្ខណៈសមស្របទៅនឹងការវាយតម្លៃតាមមុខជំនាញនីមួយៗ។

➢ **សូចនាករទី៣. មានការគិតគូរពីការរក្សាបរិស្ថានជុំវិញ ផាសុកភាព និងសុវត្ថិភាព**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវរៀបចំឱ្យមានទីកន្លែង បន្ទប់វាយតម្លៃ និងបន្ទប់អនុវត្ត ព្រមទាំងធនធានរូបវ័ន្តផ្សេងៗ ទៀត ប្រកបដោយបរិស្ថានល្អ និងផ្តល់ផាសុកភាព និងសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្តដល់សិក្ខាកាម និងអ្នកវាយតម្លៃបង្គោល ព្រមទាំងបុគ្គលិក។

➢ **សូចនាករទី៤. មានបុគ្គលិកបម្រើការគ្រប់គ្រាន់**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវរៀបចំឱ្យមានបុគ្គលិកជំនាញរាប់ទាំងបុគ្គលិកជាអ្នកវាយតម្លៃបង្គោល និងបុគ្គលិកការិយាល័យផ្សេងទៀត ឱ្យបានគ្រប់គ្រាន់ដើម្បីបំពេញការងារទៅតាមផ្នែក និងមុខងារនៅក្នុងមជ្ឈមណ្ឌល។

➢ **សូចនាករទី៥. អភិវឌ្ឍរូបវ័ន្តទ្រទ្រង់ការវាយតម្លៃតាមប្រព័ន្ធអនឡាញ**

ដើម្បីចូលរួមជំរុញការវាយតម្លៃជំនាញឆ្លើយតបទៅនឹងការវិវត្តន៍នៃបច្ចេកវិទ្យាឌីជីថល មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមានការគិតគូររៀបចំឱ្យមានបន្ទប់ ឬមណ្ឌល ដែលមានបំពាក់ឧបករណ៍ និងសម្ភារបច្ចេកទេស និងកុំព្យូទ័រដើម្បីសម្រួលដល់ការវាយតម្លៃសមត្ថភាពពីចម្ងាយ ឬតាមប្រព័ន្ធអនឡាញ។ ការវាយតម្លៃតាមប្រព័ន្ធអនឡាញ នឹងចូលរួមជួយដល់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការវាយតម្លៃសមត្ថភាពលើជំនាញនៃវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ។

➢ **សូចនាករទី៦. មានផែនការអភិវឌ្ឍន៍ធនធានរូបវ័ន្តច្បាស់លាស់**

ដើម្បីឆ្លើយតបទៅនឹងតម្រូវការវាយតម្លៃសមត្ថភាព និងស្របតាមការអភិវឌ្ឍរបស់មជ្ឈមណ្ឌល មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមានផែនការអភិវឌ្ឍន៍ធនធានរូបវ័ន្ត ដោយរៀបចំឡើងស្របនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់មជ្ឈមណ្ឌល។

**ឃ. លក្ខណវិនិច្ឆ័យទី៤** ***ការរៀបចំ និងអនុវត្តផែនការវាយតម្លៃជំនាញទេសចរណ៍***

ដើម្បីធានានិរន្តរភាព និងគុណភាពនៃការវាយតម្លៃ ការរៀបចំផែនការវាយតម្លៃជំនាញទេសចរណ៍ពិតជាមានសារៈសំខាន់ណាស់។ ក្នុងន័យនេះ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមានផែនការវាយតម្លៃជំនាញទេសចរណ៍របស់ខ្លួន សំដៅធានាឱ្យការវាយតម្លៃនៅក្នុងមជ្ឈមណ្ឌលរបស់ខ្លួន ដំណើរការប្រកបដោយ

និរន្តរភាព ប្រសិទ្ធភាព និងគុណភាព ឆ្លើយតបទៅនឹងតម្រូវការវាយតម្លៃជំនាញទេសចរណ៍ និងការវិវត្តន៍ថ្មីៗនៃជំនាញទេសចរណ៍។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន ០៣ ដែលមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ត្រូវមាន និងអនុវត្តតាម៖

➢ **សូចនាករទី១. មានការរៀបចំផែនការវាយតម្លៃជំនាញទេសចរណ៍ប្រចាំឆ្នាំ**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវរៀបចំផែនការវាយតម្លៃរបស់ខ្លួនប្រចាំឆ្នាំ។ ការរៀបចំផែនការវាយតម្លៃជំនាញទេសចរណ៍បានល្អ នឹងអាចចូលរួមជួយដល់ការអនុវត្តសកម្មភាពវាយតម្លៃ និងបញ្ជាក់សមត្ថភាពយុវជន សិស្ស និស្សិត និងអ្នកជំនាញទេសចរណ៍ ស្របតាមការវិវត្តន៍ថ្មីៗ នៃវិស័យទេសចរណ៍ ជាពិសេស ការអភិវឌ្ឍជំនាញថ្មីៗ ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ។

➢ **សូចនាករទី២. ការសម្រេចបានតាមផែនការវាយតម្លៃជំនាញទេសចរណ៍**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវខិតខំជំរុញការវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ឱ្យបានសកម្ម ស្របតាមផែនការវាយតម្លៃរបស់ខ្លួន។ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវសម្រេចឱ្យបានយ៉ាងហោចណាស់ ៧០% នៃសកម្មភាពអនុវត្ត តាមផែនការដែលបានដាក់ចេញរបស់ខ្លួន។

➢ **សូចនាករទី៣. មានផែនការសហការជាមួយក្រសួងទេសចរណ៍ និងភាគីពាក់ព័ន្ធជំរុញការវាយតម្លៃជំនាញទេសចរណ៍**

ដើម្បីចូលរួមកាន់តែសកម្មនៅក្នុងបេសកកម្មផ្តល់សេវាវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ចាំបាច់ត្រូវអនុវត្តតាមការណែនាំផ្សេងៗ របស់ក្រសួងទេសចរណ៍ទាក់ទងទៅនឹងការវាយតម្លៃ បញ្ជាក់ និងទទួលស្គាល់សមត្ថភាពរបស់ធនធានអ្នកជំនាញក្នុងវិស័យទេសចរណ៍។ ជាពិសេស មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមានផែនការសហការជាមួយក្រសួង និងភាគីពាក់ព័ន្ធទាំងអស់ក្នុងការរៀបចំការវាយតម្លៃសមត្ថភាពដល់យុវជន សិស្ស និស្សិត និងអ្នកជំនាញទេសចរណ៍។

**ង. លក្ខណវិនិច្ឆ័យទី៥. *ឯកសារវាយតម្លៃ និងឧបករណ៍វាយតម្លៃ***

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវរៀបចំឯកសារវាយតម្លៃឱ្យមានភាពច្បាស់លាស់ ត្រូវមានបញ្ជាក់ឱ្យបានច្បាស់អំពីវិធីសាស្រ្ត និងឧបករណ៍សម្រាប់វាយតម្លៃ។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន ០៤ ដែលមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

➢ **សូចនាករទី១.មានក្រុមការងារ ឬគណៈកម្មការអភិវឌ្ឍន៍ និងចងក្រងឯកសារវាយតម្លៃ**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវរៀបចំបង្កើតក្រុមការងារ ឬគណៈកម្មការអភិវឌ្ឍន៍ និងចងក្រងឯកសារវាយតម្លៃ សំដៅធ្វើឱ្យមានបច្ចុប្បន្នភាពលើឯកសារវាយតម្លៃស្របតាមតម្រូវការនៃការវាយតម្លៃ និងបញ្ជាក់សមត្ថភាពលើជំនាញនៃវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ។

➢ **សូចនាករទី២. ឯកសារវាយតម្លៃមានខ្លឹមសារច្បាស់លាស់ និងស្របតាមស្តង់ដាជាតិ និងអាស៊ាន**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមានឯកសារវាយតម្លៃច្បាស់លាស់ ដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍។ ឯកសារវាយតម្លៃសម្រាប់វាយតម្លៃលើជំនាញទេសចរណ៍ ត្រូវរៀបចំចងក្រងឡើងដោយផ្អែកលើស្តង់ដាសមត្ថភាពអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន។

➢ **សូចនាករទី៣. មានវិធីសាស្ត្រ និងឧបករណ៍វាយតម្លៃសមត្ថភាពរបស់សិក្ខាកាមច្បាស់លាស់ និងគ្រប់គ្រាន់**

ការវាយតម្លៃសមត្ថភាព ដែលមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពរៀបចំឡើង ត្រូវមានការកំណត់វិធីសាស្ត្រ និងឧបករណ៍សម្រាប់វាយតម្លៃសមត្ថភាព ឱ្យបានច្បាស់លាស់ និងគ្រប់គ្រាន់ឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យតម្រូវតាមជំនាញ និងឯកតាសមត្ថភាពនីមួយៗ។

➢ **សូចនាករទី៤.មានការត្រួតពិនិត្យ វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពឯកសារវាយតម្លៃយ៉ាងទៀងទាត់**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាព និងគុណភាពនៃការវាយតម្លៃ និងត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំស្របតាមការវិវត្តន៍ថ្មីៗ នៃស្តង់ដាសមត្ថភាពអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន។

**ថ. លក្ខណវិនិច្ឆ័យទី៦.** ***ការធានាឱ្យមានអ្នកវាយតម្លៃបង្គោល និងបុគ្គលិកជំនាញដែលមាន សមត្ថភាពគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព***

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវរៀបចំឱ្យមានអ្នកវាយតម្លៃបង្គោល ដែលមានសមត្ថភាព គុណវុឌ្ឍិ ជំនាញ និងចំណេះដឹងទាក់ទងទៅនឹងវិស័យទេសចរណ៍ និងជំនាញទេសចរណ៍ ជាពិសេសចំណេះដឹងលើការវាយតម្លៃសមត្ថភាពស្របតាមស្តង់ដាជាតិ និងអាស៊ាន មានភាពគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន ០៦ ដែលមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

➢ **សូចនាករទី១ ចំណេះដឹង ជំនាញ គុណវុឌ្ឍិ និងបទពិសោធន៍របស់អ្នកវាយតម្លៃបង្គោលស្របទៅនឹងជំនាញ និងកម្រិតវាយតម្លៃ**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវធានាឱ្យបានថា អ្នកវាយតម្លៃបង្គោលទាំងអស់ ត្រូវមានចំណេះដឹង ជំនាញ គុណវុឌ្ឍិ និងបទពិសោធន៍ ស្របទៅនឹងជំនាញ និងកម្រិតដែលត្រូវវាយតម្លៃ។

➢ **សូចនាករទី២. មានដំណើរការច្បាស់លាស់ និងតម្លាភាពក្នុងការជ្រើសរើស អភិវឌ្ឍ វាយតម្លៃ លើកទឹកចិត្ត និងរក្សាទុកអ្នកវាយតម្លៃបង្គោល**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមានរៀបចំឱ្យមានគោលនយោបាយ ឬគោលការណ៍ និងនីតិវិធីសម្រាប់ជ្រើសរើស អភិវឌ្ឍ វាយតម្លៃ លើកទឹកចិត្តដល់អ្នកវាយតម្លៃបង្គោល ព្រមទាំងត្រូវមានលក្ខខណ្ឌការងារ និងកិច្ចសន្យាការងារច្បាស់លាស់។

**➢ សូចនាករទី៣. បរិមាណអ្នកវាយតម្លៃបង្គោលលើជំនាញទេសចរណ៍ មានចំនួនគ្រប់គ្រាន់ធៀបទៅនឹងតម្រូវការវាយតម្លៃសមត្ថភាព**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវធានាឱ្យបានថា រាល់ការវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ នឹងមានចូលរួមផ្តល់ការវាយតម្លៃពីសំណាក់អ្នកវាយតម្លៃបង្គោល ដែលមានជំនាញវាយតម្លៃពាក់ព័ន្ធទៅនឹងជំនាញនោះ។

**➢ សូចនាករទី៤ អ្នកវាយតម្លៃបង្គោលមានសមត្ថភាព និងចំណេះដឹងទាក់ទងនឹងនិន្នាការថ្មីៗនៃការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការអភិវឌ្ឍជំនាញទេសចរណ៍ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវលើកទឹកចិត្តឱ្យអ្នកវាយតម្លៃបង្គោលចូលរួមក្នុងវគ្គពង្រឹងសមត្ថភាពលើការវាយតម្លៃ ឬសិក្ខាសាលាផ្សេងៗ ដែលក្រសួងទេសចរណ៍បានរៀបចំឱ្យបានម្តងក្នុងឆ្នាំ សំដៅបង្កើនសមត្ថភាព និងចំណេះដឹងទាក់ទងនឹងនិន្នាការថ្មីៗ នៃការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការវាយតម្លៃ និងអភិវឌ្ឍជំនាញទេសចរណ៍ស្របតាមស្តង់ដា ជាតិ អាស៊ាន តំបន់ និងអន្តរជាតិ។

**➢ សូចនាករទី៥. គុណវុឌ្ឍិ/កោសល្យវាយតម្លៃរបស់អ្នកវាយតម្លៃបង្គោលលើជំនាញទេសចរណ៍**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវប្រាកដថា អ្នកវាយតម្លៃបង្គោល ដែលនឹងត្រូវជ្រើសរើសយកមកធ្វើជាអ្នកវាយតម្លៃ មានគុណវុឌ្ឍិ/កោសល្យវាយតម្លៃគ្រប់គ្រាន់ និងមានបទពិសោធន៍នៅក្នុងការវាយតម្លៃលើជំនាញនោះ ជាពិសេសមានចំណេះដឹងអំពីវិធីសាស្ត្រក្នុងការប្រើប្រាស់ឯកសារវាយតម្លៃសមត្ថភាពស្របតាមស្តង់ដាជាតិ និងអាស៊ាន តំបន់ និងអន្តរជាតិ។

**➢ សូចនាករទី៦. មានការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់បុគ្គលិកទាក់ទងនឹងនិន្នាការថ្មីៗ នៃការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការអភិវឌ្ឍជំនាញទេសចរណ៍ ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ**

បុគ្គលិកទាំងអស់ រាប់ទាំងអ្នកបម្រើការងារនៅក្នុងការិយាល័យរបស់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមានចំណេះដឹងអំពីវិស័យទេសចរណ៍ និងទទួលបានការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពទាក់ទងនឹងនិន្នាការថ្មីៗ នៃការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការអភិវឌ្ឍជំនាញទេសចរណ៍ និងការវាយតម្លៃសមត្ថភាពស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ តាមរយៈការចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗ ដែលរៀបចំឡើងដោយក្រសួងទេសចរណ៍។

**ឆ. លក្ខណៈវិនិច្ឆ័យទី៧** ***ការដំណើរការវាយតម្លៃប្រកបដោយនិរន្តរភាព និងគុណភាព***

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវធានាឱ្យមានការរៀបចំវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ ប្រព្រឹត្តទៅប្រកបដោយភាពរលូន និរន្តរភាព ប្រសិទ្ធភាព និងគុណភាព។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន ០៣ ដែលមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ត្រូវមាន និងអនុវត្តតាម៖

➢ **សូចនាករទី១ ការរៀបចំសម្ភារបរិក្ខារទ្រទ្រង់ដល់ដំណើរការវាយតម្លៃ**

ដើម្បីធ្វើឱ្យដំណើរការវាយតម្លៃប្រកបដោយជោគជ័យ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវគិតគូររៀបចំឱ្យមានសម្ភារបរិក្ខារសម្រាប់ទ្រទ្រង់ដល់ដំណើរការវាយតម្លៃ។ ការដំណើរការវាយតម្លៃមួយអាចប្រព្រឹត្តទៅបានល្អ លុះត្រាតែមានសម្ភារបរិក្ខារទ្រទ្រង់ដល់ដំណើរការវាយតម្លៃគ្រប់គ្រាន់ និងឆ្លើយតបទៅនឹងជំនាញដែលយើងធ្វើការវាយតម្លៃ។

➢ **សូចនាករទី២ មានសមត្ថភាពរៀបចំដំណើរការវាយតម្លៃទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវប្រាកដថា រាល់ការវាយតម្លៃ ដែលរៀបចំឡើងទាំងអស់ត្រូវដំណើរការបានល្អតាំងពីដើមរហូតដល់ចប់។ មុននឹងដំណើរការវាយតម្លៃនីមួយៗ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ត្រូវពិនិត្យលទ្ធភាពហិរញ្ញវត្ថុ និងបច្ចេកទេសជាមុន។

➢ **សូចនាករទី៣ មានរៀបចំនីតិវិធី និងបទបញ្ជាផ្ទៃក្នុងច្បាស់លាស់សម្រាប់ការវាយតម្លៃ**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវរៀបចំឱ្យមាននីតិវិធី និងបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រងដំណើរការវាយតម្លៃឱ្យមានគុណភាព និងប្រសិទ្ធភាពខ្ពស់។

**ឃ. លក្ខណៈវិនិច្ឆ័យទី៤. *ការគ្រប់គ្រងការវាយតម្លៃប្រកបដោយនិរន្តរភាព និងគុណភាព***

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមានការតាមដាន ត្រួតពិនិត្យរាល់ការវាយតម្លៃដែលបានរៀបចំឡើង និងធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពក្នុងការរៀបចំការវាយតម្លៃ និងលទ្ធផលពីការវាយតម្លៃទាំងនោះ សំដៅធ្វើការកែតម្រូវឱ្យការវាយតម្លៃលើជំនាញទេសចរណ៍កាន់តែមានគុណភាព និងប្រសិទ្ធភាព។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន ០៤ ដែលមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

➢ **សូចនាករទី១ មានការត្រួតពិនិត្យ និងតាមដានការវាយតម្លៃ**

រាល់ការវាយតម្លៃលើជំនាញទេសចរណ៍ ត្រូវមានការតាមដាន និងត្រួតពិនិត្យគុណភាព និងដំណើរការនៃការវាយតម្លៃ ដោយក្នុងនោះ រាល់ការបញ្ចប់ដំណើរការវាយតម្លៃ ត្រូវមានការរៀបចំឱ្យមានការវាយតម្លៃដំណើរការទាំងមូលរាប់ទាំងការវាយតម្លៃលើសិក្ខាកាម និងគុណភាពវាយតម្លៃរបស់អ្នកវាយតម្លៃបង្គោលផងដែរ។

➢ **សូចនាករទី២ ការធ្វើបច្ចុប្បន្នកម្មការវាយតម្លៃ**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ អាចរៀបចំការវាយតម្លៃលើជំនាញចាំបាច់ថ្មីៗ សម្រាប់បម្រើដល់សកម្មភាពផ្តល់សេវាកម្មភ្ញៀវទេសចរ។ រាល់ការវាយតម្លៃជំនាញថ្មីចាំបាច់ ត្រូវធ្វើការជម្រាបជូនមកក្រសួងទេសចរណ៍ ដើម្បីទទួលបានការទទួលស្គាល់លើការរៀបចំការវាយតម្លៃនោះ។

➢ **សូចនាករទី៣ មានការវាយតម្លៃគុណភាព និងលទ្ធផលនៃការវាយតម្លៃ**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវធ្វើការវាយតម្លៃគុណភាព និងលទ្ធផលនៃការវាយតម្លៃនីមួយៗ ដែលបានរៀបចំឡើងដើម្បីប្រាកដថា ការវាយតម្លៃនោះធ្វើឡើងចំគោលដៅ និងបញ្ជាក់ចំណេះដឹង និងជំនាញយ៉ាងពិតប្រាកដដល់សិក្ខាកាម ជាពិសេសដើម្បីរកឱ្យឃើញនូវចំណុចខ្វះខាតទាំងឡាយណា ដែលមាននៅក្នុងការអនុវត្តដំណើរការវាយតម្លៃនីមួយៗ។

**➢ សូចនាករទី៤. មានរៀបចំរបាយការណ៍អំពីការវាយតម្លៃបញ្ជូនមកក្រសួងទេសចរណ៍**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមានការរៀបចំបូកសរុបរបាយការណ៍នៃការងារវាយតម្លៃនីមួយៗ រួចផ្ញើជូនមកក្រសួងទេសចរណ៍ និងត្រូវបញ្ចូលទិន្នន័យអំពីការវាយតម្លៃ ដែលមជ្ឈមណ្ឌលរបស់ខ្លួនបានបើកវាយតម្លៃ ទៅក្នុងប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ របស់ក្រសួងទេសចរណ៍ ដែលមានអាសយដ្ឋានគេហទំព័រ www.tptd.org ដើម្បីធ្វើការបូកសរុប និងតាមដានសកម្មភាពអនុវត្តលើការវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ របស់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពនីមួយៗ។

**ឈ. លក្ខណវិនិច្ឆ័យទី៩.** ***សមត្ថភាពធនធានហិរញ្ញវត្ថុ និងការឧបត្ថម្ភធនសម្រាប់ទ្រទ្រង់ការវាយតម្លៃ***

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមានការគិតគូររៀបចំឱ្យមានធនធានហិរញ្ញវត្ថុ និងការឧបត្ថម្ភធនសម្រាប់ទ្រទ្រង់ការវាយតម្លៃសមត្ថភាពក្នុងការជួយសម្រួលដល់យុវជន សិស្ស និស្សិត និងអ្នកជំនាញទេសចរណ៍ដើម្បីទទួលបានការបញ្ជាក់សមត្ថភាពលើជំនាញទេសចរណ៍។ ដូច្នេះ យើងបានកំណត់យកសូចនាករចំនួន **០៣** ដែលមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

**➢ សូចនាករទី១ មានផ្តល់ជូនសេវាវាយតម្លៃក្នុងតម្លៃទាប**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមានការផ្តល់សេវាវាយតម្លៃក្នុងតម្លៃទាប ដែលអាចជួយសម្រួលដល់យុវជន សិស្ស និស្សិត និងអ្នកជំនាញទេសចរណ៍គ្រប់រូបអាចមានលទ្ធភាពចូលរួមទទួលបានការវាយតម្លៃ និងបញ្ជាក់សមត្ថភាពបាន។

**➢ សូចនាករទី២. មានផ្តល់ជូនការវាយតម្លៃដោយមិនគិតថ្លៃ**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវបានលើកទឹកចិត្តឱ្យមានផ្តល់ជូនការរៀបចំវគ្គវាយតម្លៃសមត្ថភាព ដោយមិនគិតថ្លៃដល់យុវជន សិស្ស និស្សិត និងអ្នកជំនាញទេសចរណ៍។ ការវាយតម្លៃសមត្ថភាពដោយមិនគិតថ្លៃនេះ អាចត្រូវបានធ្វើឡើងក្រោមទម្រង់នៃការសហការជាមួយក្រសួងទេសចរណ៍ ព្រមទាំងដៃគូ និងភាគីពាក់ព័ន្ធផ្សេងៗទៀត។

**➢ សូចនាករទី៣. មានកញ្ចប់ថវិកាសមស្របសម្រាប់គាំទ្រការអភិវឌ្ឍជំនាញដល់អ្នកវាយតម្លៃបង្គោល និងបុគ្គលិកជំនាញ**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវគិតគូររៀបចំឱ្យមានកញ្ចប់ថវិកាមួយផ្នែកសម្រាប់គាំទ្រដល់ការពង្រឹងសមត្ថភាពដល់អ្នកវាយតម្លៃបង្គោល ព្រមទាំងបុគ្គលិកជំនាញនៅក្នុងស្ថាប័នផងដែរ។

**ញ. លក្ខណវិនិច្ឆ័យទី១០.** ***ការធានាគុណភាពផ្ទៃក្នុង***

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ក្នុងការធានា និងបន្តលើកកម្ពស់គុណភាពវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ តាមរយៈការវាយតម្លៃជាប្រព័ន្ធលើប្រសិទ្ធភាពនៃប្រតិបត្តិការ និងឯកសារវាយតម្លៃរបស់ខ្លួន។ ដូច្នេះ យើងបានកំណត់យកលក្ខណវិនិច្ឆ័យចំនួន **០២** ដែលមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមាន និងអនុវត្តតាម៖

ᨀ

➢ **ស្តូចនាករទី១ មានប្រព័ន្ធធានាគុណភាពផ្ទៃក្នុងច្បាស់លាស់**

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវមានគោលការណ៍ និងនីតិវិធីសម្រាប់អនុវត្តការធានាគុណភាពផ្ទៃក្នុងច្បាស់លាស់។

➢ **ស្តូចនាករទី២. មានការចូលរួម និងគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធខាងក្នុងស្ថាប័នលើដំណើរការធានាគុណភាពវាយតម្លៃ**

ដើម្បីធានាគុណភាពផ្ទៃក្នុង មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវអនុវត្តយកការទទួលមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធដើម្បីកែលម្អគុណភាព និងផែនការវាយតម្លៃ។

***ដើម្បីទទួលបានការទទួលស្គាល់គុណភាពវាយតម្លៃទៅតាមកម្រិត មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំងអស់ ត្រូវបំពេញគ្រប់លក្ខណៈវិនិច្ឆ័យទាំង ១០ ពោលគឺ៖***

*១. ទទួលបានពិន្ទុចន្លោះ ១០០-៩០ នៃពិន្ទុសរុប ដើម្បីក្លាយជាមជ្ឈមណ្ឌលវាយតម្លៃកម្រិតល្អណាស់*

*២. ទទួលបានពិន្ទុចន្លោះ ៨៩-៨០ នៃពិន្ទុសរុប ដើម្បីក្លាយជាមជ្ឈមណ្ឌលវាយតម្លៃកម្រិតល្អ*

*៣. ទទួលបានពិន្ទុចន្លោះ ៧៩-៧០ នៃពិន្ទុសរុប ដើម្បីក្លាយជាមជ្ឈមណ្ឌលវាយតម្លៃកម្រិតល្អបង្គួរ*

*៤. ទទួលបានពិន្ទុចន្លោះ ៦៩-៦០ នៃពិន្ទុសរុប ដើម្បីក្លាយជាមជ្ឈមណ្ឌលវាយតម្លៃកម្រិតមធ្យម*

*៥. ទទួលបានពិន្ទុចន្លោះ ៥៩-៥០ នៃពិន្ទុសរុប ដើម្បីក្លាយជាមជ្ឈមណ្ឌលវាយតម្លៃកម្រិតខ្សោយ*

***<u>សម្គាល់៖</u>***

• ការវាយតម្លៃ និងផ្តល់ពិន្ទុ ត្រូវធ្វើឡើងផ្អែកលើតារាងរបាយការណ៍វាយតម្លៃមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលមាននៅក្នុងឧបសម្ព័ន្ធ។

• មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលទទួលបានពិន្ទុក្រោម ៥០ នឹងមិនអាចទទួលស្គាល់ជាមជ្ឈមណ្ឌល ដែលមានសមត្ថភាពក្នុងការផ្តល់សេវាវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ និងជំនាញដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍បានឡើយ។

• មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលទទួលបានការបញ្ជាក់ការទទួលស្គាល់គុណភាពវាយតម្លៃលើជំនាញទេសចរណ៍ និងជំនាញដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ ពីក្រសួងទេសចរណ៍តាមរយៈនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ អាចធ្វើការវាយតម្លៃ និងបញ្ជាក់សមត្ថភាពលើជំនាញទេសចរណ៍ និងជំនាញដែលមានឧបនិស្ស័យនឹងឧស្សាហកម្មទេសចរណ៍ ដោយពុំចាំបាច់ធ្វើការស្នើសុំការទទួលស្គាល់លើវគ្គវាយតម្លៃសមត្ថភាពទៀតនោះទេ។

**៧.៣. ដំណើរការវាយតម្លៃ និងបញ្ជាក់គុណភាពវាយតម្លៃលើជំនាញទេសចរណ៍សម្រាប់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព**

ដំណើរការវាយតម្លៃ និងបញ្ជាក់គុណភាពវាយតម្លៃលើជំនាញទេសចរណ៍ នឹងត្រូវធ្វើឡើងតាមដំណាក់កាលដូចខាងក្រោម៖

- មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ត្រូវធ្វើស្វ័យវាយតម្លៃ និងរៀបចំរបាយការណ៍ ដោយផ្អែកលើស្តង់ដារបញ្ជាក់ និងទទួលស្គាល់គុណភាពវាយតម្លៃខាងលើ។ ផ្អែកលើស្តូចនាករ និងលក្ខណៈវិនិច្ឆ័យនៃ

ស្តង់ដាបញ្ជាក់ និងទទួលស្គាល់គុណភាពវាយតម្លៃ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពអាចមានលទ្ធភាពកែលម្អចំណុចខ្វះខាតឱ្យមានលក្ខណៈល្អប្រសើរ ដើម្បីក្លាយជាមជ្ឈមណ្ឌលដែលផ្តល់សេវាវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់។

- មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ត្រូវដាក់ពាក្យស្នើសុំការបញ្ជាក់ និងទទួលគុណភាពវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍មកក្រសួងទេសចរណ៍ ដោយមានភ្ជាប់មកជាមួយនូវរបាយការណ៍ស្វ័យវាយតម្លៃ និងឯកសារគាំទ្រចាំបាច់ដែលពាក់ព័ន្ធ។

- នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ នឹងចាត់មន្ត្រីជំនាញឱ្យពិនិត្យបឋមលើរបាយការណ៍ស្វ័យវាយតម្លៃ និងឯកសារគាំទ្រចាំបាច់ដែលពាក់ព័ន្ធទាំងនោះ និងផ្តល់ការណែនាំបន្ថែមដល់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពដែលបានដាក់ពាក្យស្នើសុំ ក្នុងករណីពិនិត្យឃើញថា នៅមានភាពខ្វះខាតលើចំណុចណាមួយនៃរបាយការណ៍ស្វ័យវាយតម្លៃ និងឯកសារភ្ជាប់ទាំងនោះ។

- បន្ទាប់ពីការវាយតម្លៃបឋមលើរបាយការណ៍ស្វ័យវាយតម្លៃ និងឯកសារគាំទ្រ ដែលស្ថាប័នបញ្ជូនមក នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ នឹងចាត់មន្ត្រីជំនាញចុះពិនិត្យ និងវាយតម្លៃផ្ទាល់នៅមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលស្នើសុំ ដោយជូនដំណឹងដល់មជ្ឈមណ្ឌលស្នើសុំមុន មិនលើសពី **៣០ ថ្ងៃ** បន្ទាប់ពីការវាយតម្លៃបឋមត្រូវបានបញ្ចប់។

- បន្ទាប់ពីការចុះវាយតម្លៃផ្ទាល់ មន្ត្រីជំនាញនៃនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ នឹងធ្វើការបូកសរុបលទ្ធផលនៃការចុះវាយតម្លៃ និងបង្ហាញជូនដល់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពដែលបានស្នើសុំ។

- ក្រសួងទេសចរណ៍ នឹងរៀបចំវិញ្ញាបនបត្របញ្ជាក់ និងទទួលស្គាល់គុណភាពវាយតម្លៃដល់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលបានបំពេញតាមពិន្ទុនៅក្នុងស្តង់ដាទទួលស្គាល់គុណភាពវាយតម្លៃខាងលើ។

### ៧.៤ វិញ្ញាបនបត្របញ្ជាក់គុណភាពវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍សម្រាប់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព

មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលបានបញ្ជាក់ និងទទួលស្គាល់គុណភាពវាយតម្លៃសមត្ថភាពពីក្រសួងទេសចរណ៍ នឹងទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ដែលមានគំរូនៅក្នុងឧបសម្ព័ន្ធ។

## VIII. ការវាយតម្លៃ និងទទួលស្គាល់សមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍

### ៨.១. ការវាយតម្លៃ និងទទួលស្គាល់សមត្ថភាពអ្នកជំនាញទេសចរណ៍

ដើម្បីប្រាកដថា អ្នកជំនាញទេសចរណ៍ទាំងអស់ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងការបំពេញការងារតាមជំនាញនីមួយៗ នៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ អ្នកបម្រើការងារក្នុងអាជីវកម្មសេវាកម្មទេសចរណ៍ទាំងអស់ ចាំបាច់ត្រូវមានសមត្ថភាពមូលដ្ឋាន ដែលជាសមត្ថភាពតម្រូវសម្រាប់អ្នកដែលបម្រើការងារនៅក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ទាំងអស់ត្រូវមាន។ អ្នកជំនាញទេសចរណ៍ទាំងចាស់ និង

ថ្មីទាំងអស់ ចាំបាច់ត្រូវមានការបញ្ជាក់លើសមត្ថភាពមូលដ្ឋានដែលបានតម្រូវ មុននឹងអាចចាប់ផ្តើមបំពេញការងារក្នុងការផ្តល់សេវាកម្មតាមជំនាញរបស់ខ្លួនបាននៅក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ។

អ្នកជំនាញទេសចរណ៍ យុវជន សិស្ស និស្សិត និងសាធារណជន ដែលមានបំណងចាប់យកអាជីពបម្រើការងារនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ ដែលមិនទាន់មានចំណេះដឹងលើសមត្ថភាពមូលដ្ឋាន ចាំបាច់ត្រូវស្វែងរកការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាពមូលដ្ឋានជាមុន ដើម្បីទទួលបានការទទួលស្គាល់ជាអ្នកជំនាញទេសចរណ៍ពេញលក្ខណៈសម្បត្តិ។ ដោយឡែក សម្រាប់អ្នកជំនាញទេសចរណ៍មានចំណេះដឹងលើសមត្ថភាពមូលដ្ឋាននេះ អាចធ្វើការស្នើសុំវាយតម្លៃសមត្ថភាពតែម្តង។

ការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាព ដើម្បីបញ្ជាក់ការទទួលស្គាល់សមត្ថភាពដល់អ្នកជំនាញទេសចរណ៍ និងអ្នកដែលចង់ចាប់អាជីពបម្រើការងារក្នុងវិស័យនេះ អាចធ្វើឡើងនៅនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដោយផ្ទាល់ ឬនៅតាមស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍។ ក្រៅពីការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាព ដែលរៀបចំឡើងនៅតាមកន្លែងផ្ទាល់ និងការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាព នេះក៏អាចធ្វើឡើងតាមប្រព័ន្ធអនឡាញរបស់ក្រសួងទេសចរណ៍ តាមរយៈអាសយដ្ឋានគេហទំព័រ www.tptd.org អាស្រ័យតាមសមត្ថភាព និងជំនាញនីមួយៗ។

ជាកាតព្វកិច្ច អ្នកជំនាញទេសចរណ៍ ចាំបាច់ត្រូវឆ្លងកាត់ការបណ្តុះបណ្តាល ជាពិសេសមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ ត្រូវធានាបុគ្គលិកបម្រើការងារក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួនទទួលបានការបណ្តុះបណ្តាល។ បន្ថែមលើសមត្ថភាពមូលដ្ឋាន ដែលជាសមត្ថភាពស្នូលសម្រាប់អ្នកជំនាញទេសចរណ៍ អ្នកជំនាញទេសចរណ៍ទាំងអស់ អាចបន្តចូលរួមវគ្គបណ្តុះបណ្តាលលើសមត្ថភាពផ្សេងៗ ស្របតាមស្តង់ដាសមត្ថភាពអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន ដើម្បីទទួលបានចំណេះដឹង និងជំនាញបន្ថែម សម្រាប់អភិវឌ្ឍខ្លួនក្លាយជាអ្នកជំនាញទេសចរណ៍ប្រកបដោយសមត្ថភាព ជំនាញ និងគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ និងអាស៊ាន។

ដើម្បីបង្កលក្ខណៈងាយស្រួល និងផ្តល់ឱកាសដល់អ្នកបម្រើការងារនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍របស់ខ្លួន ដើម្បីទទួលបានការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាពយ៉ាងទៀងទាត់ មូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ ត្រូវជំរុញធ្វើការចុះឈ្មោះបុគ្គលិករបស់ខ្លួនទៅក្នុងប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ www.tptd.org និងត្រូវរៀបចំឱ្យមានថ្នាក់បណ្តុះបណ្តាលសម្រាប់បុគ្គលិករបស់ខ្លួនឱ្យបានយ៉ាងហោចណាស់ ០២ វគ្គក្នុងមួយឆ្នាំ។ ដោយឡែក ដើម្បីងាយស្រួលក្នុងការបញ្ជាក់ទទួលស្គាល់សមត្ថភាពដល់អ្នកជំនាញទេសចរណ៍ អ្នកបម្រើការងារក្នុងវិស័យនេះទាំងអស់មានកាតព្វកិច្ច ត្រូវធ្វើការចុះឈ្មោះ និងធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់ខ្លួនទាក់ទងនឹងសមត្ថភាព និងជំនាញ ព្រមទាំងការងារ និងបទពិសោធន៍របស់ខ្លួននៅក្នុងប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ www.tptd.org នេះ។

**៨.២. លក្ខណវិនិច្ឆ័យវាយតម្លៃ និងទទួលស្គាល់សមត្ថភាពមូលដ្ឋានសម្រាប់អ្នកជំនាញទេសចរណ៍**

ស្តង់ដាសមត្ថភាពមូលដ្ឋានសម្រាប់បម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ មានឯកតាសមត្ថភាពស្នូលចំនួន ០៧ ដែលតម្រូវឱ្យមានសម្រាប់អ្នកបម្រើការងារក្នុងអាជីវកម្មសេវាកម្មទេសចរណ៍ទាំងអស់ ដែលរួមមាន៖ សេវាកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ សេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ សេវាកម្មរមណីយដ្ឋានទេសចរណ៍ សេវាកម្មមណ្ឌលកម្សាន្តមនុស្សពេញវ័យ សេវាកម្មម៉ាស្សាសុខភាព និងស្ប៉ា សេវាកម្មដឹកជញ្ជូនទេសចរណ៍តាមផ្លូវទឹក និងផ្លូវគោក សេវាកម្មការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ សេវាកម្មកីឡាទេសចរណ៍ សេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍ សេវាកម្មអ្នកបកប្រែបន្តពីមគ្គុទ្ទេសក៍ទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ដូចមានខាងក្រោម៖

| ស្តង់ដាសមត្ថភាពមូលដ្ឋានសម្រាប់បម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ | | |
|---|---|---|
| សមត្ថភាពតម្រូវសម្រាប់អ្នកបម្រើការងារក្នុងអាជីវកម្មសេវាកម្មទេសចរណ៍ | | |
| **អាជីវកម្ម/សេវាកម្ម** | **លេខសម្គាល់** | **សមត្ថភាពស្នូល** |
| គ្រប់អាជីវកម្មសេវាកម្មក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ | ១ | ធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយសហការី និងអតិថិជន |
| | ២ | ធ្វើការក្នុងបរិស្ថានសង្គមចម្រុះ |
| | ៣ | អនុវត្តនីតិវិធីសុខភាព និងសុវត្ថិភាពតាមអាជីព |
| | ៤ | អនុវត្តការងារស្របតាមនីតិវិធីអនាម័យនៅកន្លែងការងារ |
| | ៥ | អភិវឌ្ឍចំណេះដឹងលើឧស្សាហកម្មទេសចរណ៍ |
| | ៦ | បដិសណ្ឋារកិច្ច និងសេវាកម្មភ្ញៀវ |
| | ៧ | ទទួល និងដោះស្រាយការត្អូញត្អែររបស់ភ្ញៀវ |

ដើម្បីទទួលបានការទទួលស្គាល់ថា អ្នកជំនាញទេសចរណ៍ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអាចបំពេញការងារក្នុងវិស័យនេះបាន អ្នកបម្រើការងារទាំងអស់ ចាំបាច់ត្រូវមានសមត្ថភាពយ៉ាងហោចណាស់ ០៤ សមត្ថភាពក្នុងចំណោមសមត្ថភាពស្នូលទាំង ០៧។ អ្នកជំនាញទេសចរណ៍ ចាំបាច់ត្រូវស្វែងរកការបណ្តុះបណ្តាលលើសមត្ថភាពដែលខ្វះខាត រយៈពេលមិនលើសពី ០៣ ខែក្រោយ បន្ទាប់ពីបានចាប់ផ្តើមបំពេញការងារដំបូង ឱ្យបានគ្រប់សមត្ថភាពស្នូលទាំង ០៧ ដើម្បីមានលក្ខណៈសម្បត្តិពេញលេញក្នុងការបំពេញការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរនេះ។

**៨.៣. ការបន្សី និងវាយតម្លៃសមត្ថភាពអ្នកជំនាញទេសចរណ៍**

ការវាយតម្លៃ និងទទួលស្គាល់សមត្ថភាពមូលដ្ឋានរបស់អ្នកជំនាញទេសចរណ៍ទាំងអស់ នឹងត្រូវធ្វើឡើងដោយផ្អែកលើស្តង់ដាសមត្ថភាពមូលដ្ឋានសម្រាប់បម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរខាងលើ។

ក្នុងដំណើរការវាយតម្លៃ និងបញ្ជាក់សមត្ថភាពមូលដ្ឋាន អ្នកជំនាញទេសចរណ៍ ដែលស្នើសុំបញ្ជាក់ទទួលស្គាល់សមត្ថភាពមូលដ្ឋាន ចាំបាច់ត្រូវផ្តល់ភស្តុតាង បញ្ជាក់សមត្ថភាព ជំនាញ និងចំណេះដឹងទាក់ទងទៅនឹងសមត្ថភាពស្នូលដែលតម្រូវនៅក្នុងស្តង់ដាខាងលើ រួមមាន ឯកសារបញ្ជាក់បទពិសោធន៍ការងារទៅតាមមុខជំនាញនីមួយៗ វិញ្ញាបនបត្របញ្ជាក់សមត្ថភាព ដែលចេញដោយអ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ ដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍ និងឯកសារពាក់ព័ន្ធផ្សេងៗ។

ការទទួលស្គាល់កម្រិតសិក្សា និងវិញ្ញាបនបត្របញ្ជាក់ការសិក្សា នឹងធ្វើឡើងតាមរយៈការពិនិត្យ និងវាយតម្លៃលើវិញ្ញាបនបត្របញ្ជាក់ការសិក្សារបស់អ្នកបម្រើការងារមាន ដោយធៀបនឹងកម្មវិធីបណ្តុះបណ្តាល និងសមត្ថភាពស្នូល ដែលមាននៅក្នុងស្តង់ដាសមត្ថភាពមូលដ្ឋានសម្រាប់អ្នកជំនាញទេសចរណ៍។ ការវាយតម្លៃបញ្ជាក់សមត្ថភាពបន្ថែមក្រៅពីសមត្ថភាពមូលដ្ឋាន ដែលតម្រូវមាននៅក្នុងស្តង់ដាសមត្ថភាពមូលដ្ឋានសម្រាប់បម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ នឹងត្រូវធ្វើឡើងដោយផ្អែកលើស្តង់ដាសមត្ថភាពអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន និងមានការបន្ស៊ីនឹងក្របខណ្ឌគុណវុឌ្ឍិរបស់អ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន ផ្អែកលើយន្តការវាយតម្លៃ និងទទួលស្គាល់អ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន។

ក្នុងករណីអ្នកជំនាញទេសចរណ៍មានបទពិសោធន៍ការងារ និងមានចំណេះដឹងទាក់ទងទៅនឹងមុខជំនាញ ដែលស្នើសុំវាយតម្លៃបញ្ជាក់សមត្ថភាព ហើយមិនមានវិញ្ញាបនបត្របញ្ជាក់សមត្ថភាពណាមួយ អ្នកបម្រើការងារនោះអាចធ្វើការស្នើសុំ និងអាចស្វែងរកស្ថាប័នវាយតម្លៃសមត្ថភាព ដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍ ក្នុងនោះ អាចធ្វើការទំនាក់ទំនងដើម្បីស្នើសុំវាយតម្លៃសមត្ថភាពផ្ទាល់នៅនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងអាចទំនាក់ទំនងនៅតាមស្ថាប័នផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍។

ការវាយតម្លៃសមត្ថភាពអ្នកជំនាញទេសចរណ៍ នឹងអាចធ្វើឡើងដោយផ្ទាល់នៅនឹងកន្លែង និងតាមប្រព័ន្ធអនឡាញ អាស្រ័យទៅតាមប្រភេទសមត្ថភាព និងជំនាញ នៃមុខងារនីមួយៗ របស់អ្នកបម្រើការងារដែលបានស្នើសុំការវាយតម្លៃ ដោយអនុវត្តការវាយតម្លៃទៅលើចំណេះដឹងជាលក្ខណៈទ្រឹស្តី និងការវាយតម្លៃទៅលើការបង្ហាញលក្ខណៈជាការអនុវត្តផ្ទាល់។

ដើម្បីមានភាពងាយស្រួល និងពន្លឿនដល់ដំណើរការវាយតម្លៃសមត្ថភាព អ្នកជំនាញទេសចរណ៍ ត្រូវចុះឈ្មោះនៅក្នុងប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដែលមានអាសយដ្ឋានគេហទំព័រ www.tptd.org និងត្រូវផ្តល់ព័ត៌មានទាក់ទងនឹងប្រវត្តិការងារ និងការសិក្សា និងឯកសារពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ។ ការមិនបានចុះឈ្មោះ និងផ្តល់ព័ត៌មាន ព្រមទាំងឯកសារពាក់ព័ន្ធគ្រប់គ្រង នឹងអាចពន្យាដល់ដំណើរការស្នើសុំបញ្ជាក់សមត្ថភាព។

មូលដ្ឋានអាជីវកម្ម ដែលស្នើសុំបញ្ជាក់សមត្ថភាពអ្នកបម្រើការងារនៅក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួន ចាំបាច់ត្រូវជំរុញការចុះឈ្មោះបុគ្គលិករបស់ខ្លួន ទៅក្នុងប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលមានអាសយដ្ឋានគេហទំព័រ www.tptd.org ឱ្យបានគ្រប់ៗគ្នា។ ការធ្វើបែបនេះ នឹងជួយដល់

មូលដ្ឋានអាជីវកម្មនៅក្នុងការផ្តល់ការបណ្តុះបណ្តាល និងវាយតម្លៃទាំងសមត្ថភាពមូលដ្ឋាន និងសមត្ថភាពផ្សេងៗទៀតដល់បុគ្គលិករបស់ខ្លួន។

**៨.៤. ដំណើរការវាយតម្លៃ និងបញ្ជាក់សមត្ថភាពអ្នកជំនាញទេសចរណ៍**

ការវាយតម្លៃ និងបញ្ជាក់សមត្ថភាពសម្រាប់អ្នកជំនាញទេសចរណ៍ នឹងត្រូវធ្វើឡើង នៅពេលមានការស្នើសុំពីអ្នកបម្រើការងារផ្ទាល់ ឬតាមរយៈការស្នើសុំរបស់មូលដ្ឋានអាជីវកម្មទេសចរណ៍ដើម្បីវាយតម្លៃ និងបញ្ជាក់សមត្ថភាពរបស់បុគ្គលិកខ្លួន ដែលដំណើរការវាយតម្លៃ និងបញ្ជាក់សមត្ថភាពអ្នកជំនាញទេសចរណ៍ នឹងធ្វើឡើងតាមដំណាក់កាលដូចខាងក្រោម៖

- អ្នកស្នើសុំបញ្ជាក់សមត្ថភាព (អ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរ ដែលស្នើសុំវិញ្ញាបនបត្របញ្ជាក់សមត្ថភាព ឬស្នើសុំលិខិតបញ្ជាក់សមត្ថភាពមូលដ្ឋាន និងមូលដ្ឋានអាជីវកម្មទេសចរណ៍ ដែលស្នើសុំវិញ្ញាបនបត្របញ្ជាក់សមត្ថភាពដល់បុគ្គលិកខ្លួន ឬដែលស្នើសុំលិខិតបញ្ជាក់ចំនួនបុគ្គលិកឆ្លងកាត់ការបណ្តុះបណ្តាល និងមានសមត្ថភាពមូលដ្ឋាន) អាចធ្វើការស្នើសុំដោយភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធចាំបាច់ផ្សេងៗ (រួមមានប្រវត្តិរូបបុគ្គលិក លិខិតបញ្ជាក់បទពិសោធន៍ការងារ វិញ្ញាបនបត្របញ្ជាក់ការសិក្សាផ្សេងៗ និងបញ្ជីឈ្មោះបុគ្គលិក (សម្រាប់អ្នកស្នើសុំជាម្ចាស់មូលដ្ឋានអាជីវកម្ម) ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗ) មកកាន់នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍។ ការស្នើសុំបញ្ជាក់សមត្ថភាព អាចធ្វើឡើងតាមប្រព័ន្ធអនឡាញនៅលើអាសយដ្ឋានគេហទំព័រ www.tptd.org ដោយតម្រូវឱ្យអ្នកបម្រើការងារម្នាក់ៗ ត្រូវចុះឈ្មោះផ្តល់ព័ត៌មាន និងភ្ជាប់ឯកសារពាក់ព័ន្ធនៅលើគេហទំព័រនេះ។
- ផ្អែកលើព័ត៌មាន និងឯកសារភ្ជាប់របស់អ្នកស្នើសុំបញ្ជាក់សមត្ថភាព មន្ត្រីជំនាញនៃនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ នឹងចាប់ផ្តើមធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ដើម្បីបញ្ជាក់ការទទួលសមត្ថភាពជូនអ្នកបម្រើការងារ។
- ក្នុងករណី មន្ត្រីជំនាញពិនិត្យឃើញថា សមត្ថភាព និងជំនាញដែលស្នើសុំបញ្ជាក់នោះ មានលក្ខណៈអនុវត្ត និងទាមទារឱ្យមានការធ្វើការវាយតម្លៃការអនុវត្តផ្ទាល់ នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ នឹងចាត់មន្ត្រីជំនាញចុះពិនិត្យ និងវាយតម្លៃលើការអនុវត្តនៅកន្លែងជាក់ស្តែងបន្ថែម និងអាចណែនាំ និងតម្រង់ទិសដល់អ្នកស្នើសុំបញ្ជាក់សមត្ថភាព ទៅធ្វើការវាយតម្លៃ បញ្ជាក់សមត្ថភាពផ្អែកអនុវត្តនៅតាមស្ថាប័នបណ្តុះបណ្តាលជំនាញទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលទទួលបានការទទួលស្គាល់ជាកន្លែងវាយតម្លៃសមត្ថភាព ពីក្រសួងទេសចរណ៍។
- បន្ទាប់ពីការវាយតម្លៃបានបញ្ចប់ នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ នឹងធ្វើការជម្រាបអំពីលទ្ធផលនៃការបញ្ជាក់សមត្ថភាពអ្នកបម្រើការងារទៅដល់អ្នកស្នើសុំ មិនលើស **០៣ សប្តាហ៍** គិតចាប់ពីថ្ងៃបញ្ចប់ការវាយតម្លៃសមត្ថភាពចុងក្រោយ។ ការផ្តល់លទ្ធផលបញ្ជាក់សមត្ថភាពមានពីរទម្រង់ដូចខាងក្រោម៖

១ **ផ្តល់ជូនវិញ្ញាបនបត្របញ្ជាក់សមត្ថភាព** សម្រាប់អ្នកស្នើសុំជាអ្នកជំនាញទេសចរណ៍ ដែលស្នើសុំវិញ្ញាបនបត្របញ្ជាក់សមត្ថភាព ហើយត្រូវបានវាយតម្លៃឃើញថាមានសមត្ថភាពពិតប្រាកដ។

២ **ផ្តល់ជូនលិខិតបញ្ជាក់សមត្ថភាពមូលដ្ឋានសម្រាប់អ្នកជំនាញទេសចរណ៍** សម្រាប់អ្នកជំនាញទេសចរណ៍ ឬមូលដ្ឋានអាជីវកម្មទេសចរណ៍ ដែលស្នើសុំលិខិតបញ្ជាក់សមត្ថភាពមូលដ្ឋានសម្រាប់អ្នកជំនាញទេសចរណ៍។

**៨.៥. វិញ្ញាបនបត្របញ្ជាក់សមត្ថភាព និងលិខិតបញ្ជាក់សមត្ថភាពមូលដ្ឋាន**

វិញ្ញាបនបត្របញ្ជាក់សមត្ថភាព និងលិខិតបញ្ជាក់សមត្ថភាពមូលដ្ឋានមានគំរូបង្ហាញនៅក្នុងឧបសម្ព័ន្ធ។

**IX. យន្តការអនុវត្ត**

ការប្រើប្រាស់ **គោលការណ៍កាតព្វកិច្ច** ជាយន្តការក្នុងការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការទទួលស្គាល់គុណភាពបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញទេសចរណ៍ ពោលគឺ៖

១.អ្នកជំនាញទេសចរណ៍ មានកាតព្វកិច្ចត្រូវបំពេញសមត្ថភាពមូលដ្ឋាន ដើម្បីអាចបម្រើការងារនៅក្នុងវិស័យនេះបាន។ អ្នកជំនាញទេសចរណ៍ មិនទាន់មានសមត្ថភាពគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវនៃស្តង់ដា ចាំបាច់ត្រូវស្វែងរកការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាព ដែលការបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាពអាចធ្វើឡើងដោយអ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍ និងតាមរយៈប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍តាមអនឡាញ www.tptd.org។

២ មូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ ត្រូវធានាឱ្យបានថា អ្នកបម្រើការងារនៅក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួនត្រូវឆ្លងកាត់ការបណ្តុះបណ្តាល និង ឬ វាយតម្លៃសមត្ថភាពផ្អែកលើឯកតាសមត្ថភាពមាននៅក្នុងស្តង់ដាសមត្ថភាពមូលដ្ឋានសម្រាប់អ្នកជំនាញទេសចរណ៍ និងត្រូវជំរុញបណ្តុះបណ្តាលសមត្ថភាពបន្ថែមឱ្យបានជាប្រចាំយ៉ាងហោចណាស់ ០២ ដងក្នុងមួយឆ្នាំ ដែលការបណ្តុះបណ្តាលអាចរៀបចំឡើងក្រោមការសហការជាមួយនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៅនឹងកន្លែងផ្ទាល់ (In house training) និងត្រូវណែនាំដល់បុគ្គលិកធ្វើការចុះឈ្មោះសិក្សាតាមប្រព័ន្ធអនឡាញ E-Learning របស់ក្រសួងទេសចរណ៍តាមរយៈ https://www.tptd.org។ មូលដ្ឋានអាជីវកម្មទេសចរណ៍ក៏អាចបញ្ជូនបុគ្គលិករបស់ខ្លួន ដើម្បីទទួលការវាយតម្លៃសមត្ថភាព ពីនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៃក្រសួងទេសចរណ៍ ឬមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលមានការទទួលស្គាល់ពីក្រសួងទេសចរណ៍ ក្នុងករណី បុគ្គលិករបស់ខ្លួនមានចំណេះដឹងបទពិសោធន៍ និងធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាលលើសមត្ថភាពដែលតម្រូវនៅក្នុងស្តង់ដានេះរួចហើយ។

ជាយន្តការស្ថាប័នសម្រាប់តាមដាន និងជំរុញអនុវត្តគោលការណ៍ណែនាំនេះ នាយកដ្ឋានចំណុះឱ្យក្រសួងទេសចរណ៍ ដែលទទួលបន្ទុកលើការផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មទេសចរណ៍នីមួយៗ និងមន្ទីរទេសចរណ៍រាជធានី-ខេត្ត អាចចូលរួមត្រួតពិនិត្យលើការបណ្តុះបណ្តាលសមត្ថភាពរបស់បុគ្គលិកនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍នីមួយៗ មុនសម្រេចបន្ត ឬផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មទេសចរណ៍។ ដោយឡែក នាយកដ្ឋានបណ្តុះ

បណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ សហការជាមួយស្ថាប័នបណ្តុះបណ្ដាលជំនាញទេសចរណ៍ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ដែលជាដៃគូ និងទទួលស្គាល់ពីក្រសួងទេសចរណ៍ ស្ថាប័នពាក់ព័ន្ធទាំងផ្នែករដ្ឋ និងឯកជន និងប្រតិបត្តិករទេសចរណ៍ បណ្ដាញអ្នកជំនាញ និងសាស្ត្រាចារ្យ គ្រូបង្គោល ព្រមទាំងអ្នកវាយតម្លៃបង្គោល ជំរុញការវាយតម្លៃសមត្ថភាព និងផ្ដល់ការបណ្តុះបណ្ដាលទាំងការធ្វើផ្ទាល់នៅនឹងកន្លែង និងតាមរយៈប្រព័ន្ធអនឡាញ ការបណ្តុះបណ្ដាល និងវាយតម្លៃខាងក្នុង ព្រមទាំងតាមទម្រង់ផ្សេងៗទៀត។

**ឧបសម្ព័ន្ធ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និមិត្តសញ្ញាមជ្ឈមណ្ឌល** (LOGO)

**ពាក្យស្នើសុំ**

**បញ្ជាក់ និងទទួលស្គាល់គុណភាពវាយតម្លៃលើជំនាញទេសចរណ៍**

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ..........................................អក្សរឡាតាំង..........................................
ថ្ងៃ ខែ ឆ្នាំកំណើត..........................................ភេទ..........................សញ្ជាតិ..........................
អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ..........ផ្លូវលេខ............ភូមិ................................សង្កាត់/ឃុំ..............................
ខណ្ឌ/ស្រុក..........................................................រាជធានី/ខេត្ត..........................................................
មុខងារបច្ចុប្បន្ន.......................................................អង្គភាព/ស្ថាប័ន..............................................................
ទូរស័ព្ទ............................................ទូរសារ.................................អ៊ីម៉ែល..................................................
តំណាងអង្គភាព/ស្ថាប័ន/ក្រុមហ៊ុន/មជ្ឈមណ្ឌល..............................................................................................

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**កម្មវត្ថុ** ៖ សំណើសុំអនុញ្ញាតបញ្ជាក់ និងទទួលស្គាល់គុណភាពវាយតម្លៃលើជំនាញទេសចរណ៍
ដល់.....................................................................................................។

តបតាមកម្មវត្ថុដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទ/នាងខ្ញុំ មានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពស្នើសុំ **ឯកឧត្តមរដ្ឋមន្ត្រី** ផ្តល់ការអនុញ្ញាតបញ្ជាក់ និងទទួលស្គាល់គុណភាពវាយតម្លៃលើជំនាញទេសចរណ៍ដល់មជ្ឈមណ្ឌលរបស់ខ្ញុំបាទ/នាងខ្ញុំ ដើម្បីអាចចូលរួមជំរុញការវាយតម្លៃ និងបញ្ជាក់សមត្ថភាពដល់អ្នកជំនាញទេសចរណ៍នៅកម្ពុជា។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ......................ខែ..............ឆ្នាំ......................ស័ក ព.ស ២៥........

**សូមគោរពជូនភ្ជាប់មកជាមួយ**

ធ្វើនៅ.....................ថ្ងៃទី..........ខែ..........ឆ្នាំ២០.....

១-របាយការណ៍ស្វ័យវាយតម្លៃគុណភាពវាយតម្លៃបឋម .....០១ច្បាប់
២-អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនថតចម្លង.....០១ច្បាប់
៣-ឯកសារពាក់ព័ន្ធថតចម្លង......០១ច្បាប់ (ប្រសិនបើមាន)

..................................................

**ហត្ថលេខា ឈ្មោះ និងត្រា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**និមិត្តសញ្ញាស្ថាប័ន (LOGO)**

**ពាក្យស្នើសុំ**

**បញ្ជាក់ និងទទួលស្គាល់គុណភាពបណ្តុះបណ្តាលជំនាញទេសចរណ៍**

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ..........................................អក្សរឡាតាំង..........................................

